ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- សិស្សានុសិស្សជាឱសថស័ក្តិសិទ្ធបំផុតក្នុងការព្យាបាលរបួសផ្លូវចិត្ត
- ទិទាចងកំហឹងនិងការចាប់ផ្តើមបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១១៣ ខែឧសភា ឆ្នាំ២០០៩

# ស្វែងរកការពិត

លេខ១១៣ ខែឧសភា ឆ្នាំ២០០៩

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆សិស្សានុសិស្សជាឱសថស័ក្តិសិទ្ធបំផុតក្នុងការព្យាបាលរបួសផ្លូវចិត្ត ............១

**ផ្នែកឯកសារ**

◆ញ៉ែម រីម សន្តិសុខនៅឃុំកោះថ្កូវ ..................................................៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ភ័ស្តុតាងមិនអាចបដិសេធបានស្តីពីយុទ្ធសាស្ត្រឈ្លានពាន ........................៧

◆ចម្លើយកសិណសាក្សីរបស់ជនរងគ្រោះនៃមន្ទីរសន្តិសុខម-១៣ ............១០

◆ការកាត់ទោស ឌុច និងប្រតិកម្មរបស់អ្នកភូមិ.................................២០

◆ទិវាចងកំហឹងនិងការចាប់ផ្តើមបង្រៀនប្រវត្តិសាស្ត្រកម្ពុជា...................២៥

**ផ្នែកច្បាប់**

◆ការអត់ឱន : តើការអត់ឱនអាចទៅរួចដែរឬទេ? .........................២៧

**វេទិកាពិភាក្សាសាធារណៈ**

◆នួន ជា កាលពីក្មេងនៅទីក្រុងបាងកក (១៩៤២-១៩៥០) .........៣៧

◆អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា .................................៤៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ចាំថ្ងៃស្អែក ......................................................................៥៤



លោក គ្រីនថ៍ វិល្លៀមសុន ចែកសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ជូនសិស្សានុសិស្ស



## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** អេង កុកថាយ, ផេង ពង្សរ៉ាស៊ី, ស៊ីវ សាវីណា, ជី ទេវិទ្ធិ, អ៊ីជី មូរ៉ាស្សីម៉ា, វីរ័ត្ន ដួង, ប៉ាល់ វណ្ណារក្ស **អ្នកនិពន្ធនិងស្រាវជ្រាវ :** តាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា, ទេស ម៉ារីម **អ្នកបកប្រែៈ** ជា ដល្លា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# សិស្សានុសិស្សជាឱសថស័ក្តិសិទ្ធបំផុតក្នុងការព្យាបាលរបួសផ្លូវចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំកំពុងធ្វើយុទ្ធនាការចែកចាយសៀវភៅប្រវត្តិសាស្ត្រថ្មីមួយចំនួន៥សែនក្បាលស្តីពីរបបខ្មែរក្រហមដែលមានចំណងជើងថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ។ សៀវភៅប្រវត្តិសាស្ត្រនេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមថ្នាក់វិទ្យាល័យនិងអនុវិទ្យាល័យនៅឆ្នាំក្រោយ ។

យើងបានដឹងថា យុវជនយុវនារីនៅក្នុងស្រុកយើងពិតជាចង់ដឹងចង់ឮអំពីបញ្ហានៅសម័យខ្មែរក្រហមនេះ ហើយជាទូទៅរឿងរ៉ាវក្នុងរបបខ្មែរក្រហមនេះក៏ត្រូវបានប្រាប់ពីឪពុកម្តាយទៅកូនចៅរបស់ខ្លួនដែរ ។ ការបង្រៀនមុខវិជ្ជានេះនៅសាលា ធ្វើឲ្យយើងភ្លឺនិងយល់កាន់តែច្បាស់ថែមទៀត ហើយសម្រាប់ប្រទេសក្រោយជម្លោះដូចយើងនេះ ការស្វែងយល់ពីបញ្ហាប្រវត្តិសាស្ត្រគឺជារឿងមួយសំខាន់ ។ ការសិក្សាប្រវត្តិសាស្ត្រគឺជាការបំពេញអត្តសញ្ញាណនៃការរស់នៅរបស់យើងជាប្រជាពលរដ្ឋដែលជាអ្នកទទួលខុសត្រូវចំពោះអនាគតជាតិយើង ។ ទាល់តែយើងយល់ប្រវត្តិសាស្ត្រ ទើបយើងអាចកសាងជាតិយើងអាចដើរទៅមុខបាន ។ នៅកម្ពុជា វិទ្យាល័យនិងអនុវិទ្យាល័យទាំងអស់មាន១៣២១ ។ សរុបទៅសិស្សមានជិតមួយលាននាក់ ។ នេះជាកម្លាំងស្នូល ជាធនធានមួយសម្រាប់ប្រជាជាតិយើង ។ មូលហេតុហ្នឹងហើយបានជាយើងខិតខំធ្វើការជាមួយក្រសួងអប់រំតាំងពីជាច្រើនឆ្នាំមកហើយ ។




សៀវភៅនេះនឹងត្រូវបញ្ជ្រាបចូលទៅក្នុងមុខវិជ្ជាចំនួនបី គឺអក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា និងសីលធម៌សង្គម ដែលនេះមិនមែនជាលើកដំបូងទេដែលប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានោះ ។ តាមពិតរឿងរ៉ាវរបបខ្មែរក្រហមត្រូវបានដាក់ឲ្យបង្រៀនតាំងពីក្រោយឆ្នាំ១៩៧៩មកម្ល៉េះ ប៉ុន្តែវាមិនមែនរៀនបែបប្រវត្តិសាស្ត្រនោះទេ វាជាមេរៀននយោបាយ ហើយលក្ខណៈនៃការបង្រៀនក៏មានការខ្វះខាត ។ អ្វីដែលយើងធ្វើនៅពេលនេះគឺជាការពង្រឹងមុខវិជ្ជាប្រវត្តិសាស្ត្រនិងវិធីសាស្ត្រក្នុងការបង្រៀន ហើយធ្វើយ៉ាងម៉េចឲ្យធនធានមនុស្សជាងមួយលាននាក់នេះរីកធំធាត់ជាមួយការយល់ដឹងច្បាស់លាស់អំពីប្រវត្តិសាស្ត្ររបស់ខ្លួនក្នុងការដឹកនាំប្រទេសទៅថ្ងៃខាងមុខ ។

ក្នុងរយៈពេលជាង៣ឆ្នាំក្នុងរបបខ្មែរក្រហម ប្រជាពលរដ្ឋខ្មែរនាសម័យនោះបានទទួលរងនូវទារុណកម្មនិងការឈឺចាប់ដែលមិនអាចគណនាបាន ។ ដោយឡែក ទោះបីជាសៀវភៅប្រវត្តិសាស្ត្រនេះមានកម្រាស់តែ៩០ទំព័រ មិនអាចរៀបរាប់គ្របដណ្តប់ព្រឹត្តិការណ៍ទាំងអស់បានអស់ក៏ដោយ ប៉ុន្តែយើងនៅមានសៀវភៅមួយទៀតសម្រាប់គ្រូបង្រៀនដែលរៀបរាប់លម្អិតនិងណែនាំឲ្យធ្វើការពិភាក្សាទៅលើមេរៀននីមួយៗថែមទៀត ។ យើងមានបញ្ចូលចម្រៀង កំណាព្យ ជាការសម្តែងរវាងជនដៃដល់ និងជនរងគ្រោះនិងមានខ្សែវីដេអូ ។ យើងសង្ឃឹមថាសៀវភៅនេះគឺជាមូលដ្ឋានមួយសម្រាប់សិស្សបញ្ចប់ថ្នាក់វិទ្យាល័យអាចបន្តការស្រាវជ្រាវនៅថ្នាក់មហាវិទ្យាល័យទៀត ។ យើងក៏កំពុងពិចារណាថាតើត្រូវមានរយៈ

ពេលប៉ុន្មានម៉ោងទើបសិស្សានុសិស្សទាំងអស់នោះអាចរៀនប្រវត្តិសាស្ត្រនេះបាន ។ ម៉្យាងទៀត ទាក់ទងនឹងគរុកោសល្យ យើងក៏កំពុងគិតថាតើយើងត្រូវផ្តល់ចំណេះដឹងកម្រិតណាដល់សិស្សថ្នាក់ទី៩ ទី១០ ទី១១ និងថ្នាក់ទី១២ ។ ដូច្នេះសៀវភៅនេះថ្វីដ្បិតតែមានកម្រាស់មិនដល់១០០ទំព័រក្តី តែនៅក្នុងសៀវភៅគរុកោសល្យនៅមានមេរៀនច្រើនទៀត ។

បន្ថែមពីលើនេះទៀត យើងនឹងបំពាក់បំប៉នគ្រូបង្រៀនចំនួនជាង៣០០០នាក់ ដែលមកពីវិទ្យាល័យ និងអនុវិទ្យាល័យទាំង ១៣២១កន្លែង ។ ការបណ្តុះបណ្តាលនេះនឹងចាប់ផ្តើមពីខែក្រោយជាមួយគ្រូបង្គោល២៤នាក់ ដែលនឹងក្លាយទៅជាអ្នកមើលការខុសត្រូវការបង្រៀនក្នុងខេត្តនីមួយៗ ។ បន្ទាប់មកយើងរើសគ្រូពីស្រុក១៨៥នាក់ ។ ក្នុងស្រុកនីមួយៗមានគ្រូបង្គោលម្នាក់ ។ ក្នុងមួយវិទ្យាល័យយើងរើសគ្រូ៣នាក់ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល ។ នៅឆ្នាំក្រោយ មជ្ឈមណ្ឌលឯកសារកម្ពុជាមានផែនការចុះត្រួតពិនិត្យការបង្រៀនលើមុខវិជ្ជានេះថាតើលទ្ធផលយ៉ាងណា ។

ការបង្រៀននេះនឹងមិនធ្វើឲ្យមានការប៉ះពាល់ដល់ស្ថិរភាពសង្គមទេ ។ បញ្ហាខ្មែរក្រហមគឺជារឿងរបស់យើង ជាអត្តសញ្ញាណរបស់យើង ជារឿងរបស់ជាតិយើងនៅក្នុងទឹកដីរបស់យើង ។ ការទទួលស្គាល់ប្រវត្តិសាស្ត្រនេះ វាធ្វើឲ្យយើងរឹងមាំ ។ ដោយសាររឿងខ្មែរក្រហមជារឿងនយោបាយ ជារឿងសន្តិសុខ ម៉្លោះហើយមនុស្សជាទូទៅមានការខ្លាចរអានឹងចូលជិតនិងពូរឿងនេះ ហើយមិនចង់ទទួលស្គាល់រឿងនេះ ។ អ្វីដែលខ្ញុំខ្លាចនោះគឺថា យើងចង់បំភ្លេចហើយ តែបំភ្លេចមិនបាន ។ ខ្ញុំជឿថាការប្រឈមមុខនេះមានការលំបាក តែយើងត្រូវជម្នះនិងដោះស្រាយបញ្ហានេះ ។ តាមពិត អ្នកដែលមិនចង់រំឭករឿងខ្មែរក្រហមឡើងវិញមិនមែនជាក្រុមសិស្សានុសិស្សនោះទេ ។ ដូច្នេះសៀវភៅនេះមានទិសដៅតម្រង់ទៅក្រុមសិស្សានុសិស្សដែលជាកូនជាចៅ ។ យើងយល់ថាការបង្រៀនដល់សិស្សឬកូនចៅនេះ គឺជាវិធីសាស្ត្រនៃការផ្សះផ្សារបួសផ្លូវចិត្តនិងការផ្សះផ្សាជាតិ ។ យើងបានធ្វើការស្ទង់មតិ ហើយឃើញថាជាទូទៅឪពុកម្តាយនៅពេលពួកកូនសួរនាំរឿងប្រវត្តិសាស្ត្រ ពួកគាត់ហាក់ដូចជាសប្បាយចិត្ត ។ គាត់គិតថាកូនចៅជំនាន់ក្រោយដឹងពួ ទទួលស្គាល់ ឬថារដ្ឋបានទទួលស្គាល់ ។ ដូច្នេះឱសថសម្រាប់ព្យាបាលរបួសផ្លូវចិត្តដ៏មានប្រសិទ្ធភាពនេះ គ្មានមកពីទីកន្លែងណាទេគឺ នៅក្នុងផ្ទះតែម្តងគឺកូនចៅហ្នឹងឯង ។

**ឆាំង យុ**


សិស្សានុសិស្សតម្រង់ជួរដើម្បីទទួលសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ”

# ញ៉ែម រឹម : សន្តិសុខនៅឃុំកោះថ្កូវ

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខជាច្រើនដើម្បីធ្វើជាកន្លែងឃុំឃាំងអ្នកទោសដែលមានកំហុស ដោយបែងចែកទៅតាមកម្រិតស្រាលនិងកម្រិតធ្ងន់ ។ អ្នកដែលត្រូវជ្រើសយកមកធ្វើជាអ្នកយាមឬឈ្លប គឺសុទ្ធតែជាអ្នកដែលត្រូវបានខ្មែរក្រហមទុកចិត្ត ហើយអ្នកទាំងនោះត្រូវទទួលការបំពាក់បំប៉នឲ្យស្រឡាញ់អង្គការនិងមិនត្រូវធ្វើអ្វីប្រឆាំងនឹងបញ្ជារបស់អង្គការឡើយ ។ ដូច្នេះដើម្បីបំពេញភារកិច្ចរបស់ខ្លួនឲ្យបានល្អនិងទទួលបាននូវការទុកចិត្តពីអង្គការ គ្មានកម្មាភិបាលណាម្នាក់ហ៊ានប្រឆាំងឬតវ៉ានឹងបញ្ជារបស់អង្គការដែលបានកំណត់នោះទេ ។ ប៉ុន្តែខុសប្លែកពីអ្នកទាំងនេះ រឹម ដែលសព្វថ្ងៃរស់នៅសង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខណ្ឌប៉ៃលិន បែរជាក្លាហានហ៊ានតវ៉ាជាមួយគណៈឃុំដែលចុះមកត្រួតពិនិត្យមើលការងារ ដើម្បីឲ្យអ្នកទោសបានហូបឆ្អែត ទោះបីជានៅក្នុងរបបនោះគាត់មានតួនាទីត្រឹមតែជាអ្នកយាមអ្នកទោសក៏ដោយ ។



ញ៉ែម រឹម

រឹម គឺជាកូនទី៩ក្នុងចំណោមបងប្អូនចំនួន១២នាក់ (ប្រុស៦ និងស្រី៦) មានស្រុកកំណើតនៅភូមិស្តីពន្លិច ឃុំអំពិលទឹក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ កាលពីកុមារភាព រឹម ចេះអាននិងសរសេរអក្សរបានបន្តិចបន្តួចប៉ុណ្ណោះ ព្រោះតែគាត់មិនបានចូលរៀននៅសាលាដូចជាក្មេងដទៃទៀត ។ នៅពេលមានអាយុ១២ឆ្នាំ រឹម ត្រូវបានឪពុកម្តាយបញ្ជូនឲ្យទៅរស់នៅវត្តស្តីពន្លិចដើម្បីរៀនធម៌ ។ ទោះបីជា រឹម រស់នៅឆ្ងាយពីឪពុកម្តាយក៏ដោយ ក៏គាត់តែងតែឆ្លៀតពេលវេលានៅពេលថ្ងៃដើម្បីត្រឡប់មកជួយឃ្វាលគោឪពុកម្តាយនៅផ្ទះដែរ ហើយក្រោយពីបញ្ចប់ភារកិច្ចទើបត្រឡប់ទៅវត្តវិញ ។ ពេលទំនេរក្រៅពីការងារនេះ រឹម ត្រូវរៀនអានអក្សរដោយខ្លួនឯង តាមរយៈសៀវភៅដែលព្រះសង្ឃទិញឲ្យ ។ ដោយសារគិតឃើញថាកុំឲ្យ រឹម ពិបាកធ្វើដំណើរចុះឡើង មួយរយៈក្រោយមក ឪពុកម្តាយរបស់គាត់ក៏សម្រេចចិត្តឲ្យគាត់នៅបម្រើព្រះសង្ឃ និងធ្វើជាកូនសិស្សលោកដោយមិនចាំបាច់ត្រឡប់មកផ្ទះវិញ ។ នៅយប់មួយ រឹម ស្រាប់តែត្រូវពស់ចឹក ដោយសារតែគាត់បានដើរទៅទិញស្ករសនៅខាងក្រៅ ។ ពេលនោះព្រះសង្ឃទាំងអស់បានសម្រេចបញ្ជូន រឹម ទៅព្យាបាលនៅផ្ទះវិញ ។ ឪពុកម្តាយរបស់ រឹម ព្រួយបារម្ភពីសុវត្ថិភាពរបស់កូនជាខ្លាំង ហើយប្រញាប់ប្រញាល់ទៅអញ្ជើញគ្រូថ្នាំខ្មែរឲ្យមកពិនិត្យ ។ ក្រោយពីជាសះស្បើយពីជំងឺ ទើប រឹម ត្រឡប់ទៅរស់នៅវត្តស្តីពន្លិចវិញ ។

ក្រោយពីកងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះទាំងស្រុងក្នុងឆ្នាំ១៩៧៥ វត្តស្តីពន្លិចក៏ត្រូវបំផ្លាញចោលទាំងស្រុង រួចចាប់ផ្តើមផ្សឹកព្រះសង្ឃទៀត ។ ដោយសារតែការគោរពព្រះនិងឃើញរូបបដិមាព្រះត្រូវវាយបំបាក់ពាសពេញវត្ត ក្រោយពីកងទ័ពខ្មែរក្រហមចាកចេញ រឹម ក៏បានទៅលើកព្រះកេសព្រះយកទៅដាក់កន្លែងដើមនិងបោសសម្អាតទីធ្លាជុំវិញ ។ បន្ទាប់ពីមានព្រឹត្តិការណ៍នោះមក រឹម ក៏សម្រេចចិត្តត្រឡប់មករស់នៅស្រុកកំណើតជាមួយឪពុកម្តាយវិញ ។

### ចូលបដិវត្តន៍

មួយរយៈក្រោយមក គណៈឃុំឈ្មោះ តាតឹក ក៏បានចាត់តាំង រឹម ឲ្យធ្វើជាកងឈ្លបនៅភូមិកោះថ្កូវ ។ ដោយសារអង្គការនៅមិនទាន់បានរៀបចំការងារឲ្យបានច្បាស់លាស់ ដំបូង រឹម មានតួនាទីធ្វើស្រែ លើកទំនប់ និងដឹកប្រឡាយជាមួយប្រជាជន ។ ក្រោយពីគណៈឃុំ តឹក ត្រូវចាប់ខ្លួន កងរបស់ រឹម ក៏ត្រូវរំសាយនិងនាំគ្នារត់គេចខ្លួនទៅរស់នៅតំបន់ផ្សេងៗ ។ ចុងក្រោយ កងរបស់ រឹម នៅរស់តែបីនាក់ប៉ុណ្ណោះ រួមទាំងគាត់ផងដោយម្នាក់ឈ្មោះ រ៉ន និងម្នាក់ទៀតឈ្មោះ ឡូ ។

ក្រោយពីស្ថានភាពបានស្ងប់ស្ងាត់បន្តិច រឹម ក៏ត្រឡប់មកធ្វើជាឈ្លបភូមិដដែល តាមរយៈការជ្រើសរើសរបស់គណៈឃុំថ្មីដែលមកជំនួសតំណែងចាស់របស់ តឹក ។ លើកនេះ រឹម មានភារកិច្ច

យាមអ្នកទោសដែលអង្គការចោទប្រកាន់ថាក្បត់ និងមានកំហុសបន្តិចបន្តួច ដូចជាដកដំឡូងខ្លួនឯងហូប និងស្ងួងសំណាបដាច់ ដែលមានចំនួនប្រហែលពី៥០-៦០នាក់ (ទាំងប្រជាជនមូលដ្ឋាន និងអ្នក១៧ មេសា) ក្រោមការគ្រប់គ្រងរបស់ប្រធានឈ្លប ឈ្មោះ កាន់ និងអនុប្រធានឈ្មោះ តឹក ។ អ្នកទោសត្រូវបែងចែកជាពីរប្រភេទ គឺប្រភេទស្រាល (ត្រូវជាប់គុករយៈពេល១-២ខែ នឹងត្រូវបានដោះលែង) និងប្រភេទធ្ងន់ (ជាប់គុករយៈពេលយូរ ហើយថែមទាំងជាប់ខ្នោះជើងទៀត) ក្រោមការយាមកាមយ៉ាងតឹងរ៉ឹងរបស់កងឈ្លបប្រហែលជា១២-១៣នាក់ ដូចជាឈ្មោះ ណាល់ និង រ៉ាត (ជាជនដៃដល់) ប៉ុន អានី និងប៉ុន្មាននាក់ផ្សេងទៀតដែលគាត់មិនចាំឈ្មោះ ។

អ្នកទោសដែលចាប់មកទីនេះ ភាគច្រើនជាអ្នក១៧មេសា និងត្រូវបានចោទប្រកាន់ថាជាខ្មាំង ឬសេអ៊ីអា ដែលក្នុងចំណោមនោះក៏មានជនជាតិវៀតណាមដែរ ដោយជួនកាលសហករណ៍ជាអ្នកបញ្ជូនមក ជួនកាលទៀតកងរបស់គាត់ចុះទៅចាប់ដល់កន្លែងផ្ទាល់តែម្តង ប្រសិនបើអ្នកទោសនោះរឹងទទឹងមិនគោរពតាមការបញ្ជារបស់អង្គការ ។ រីម បានរៀបរាប់ថា ចំពោះអ្នកទោសដែលអង្គការចាប់មកដោយចោទថាជាខ្មាំង ឬសេអ៊ីអា គឺជាការពិត ព្រោះពេលទ័ពខាងគាត់ និងខាងតំបន់ប្រមូលគ្នាចុះទៅព័ទ្ធព្រៃដើម្បីចាប់ខ្លួន គឺឃើញខ្មាំងបង្កើតជាមូលដ្ឋានច្បាស់លាស់ដើម្បីបះបោរប្រឆាំង ។ «អ្នកទោសទាំងនេះត្រូវយកទៅសម្លាប់ទាំងអស់ពេលដែលអង្គការចាប់បាន» ។ ប៉ុន្តែបើអ្នកទោសជាជនជាតិវៀតណាមវិញ គឺត្រូវឃុំទុកតែរយៈពេលពីរ-បីថ្ងៃប៉ុណ្ណោះ ទើបបញ្ជូនទៅកន្លែងផ្សេង ។

មួយរយៈក្រោយមក អ្នកទោសនៅទីនេះមានចំនួនថយចុះ ដោយសារខាងភូមិភាគបញ្ជូនអ្នកទោសមួយចំនួនឲ្យទៅរស់នៅកន្លែងផ្សេង ។ រីម ក៏មិនបានដឹងថា អង្គការបញ្ជូនអ្នកទាំងនេះទៅកន្លែងណាដែរ ប៉ុន្តែពេលខ្លះគាត់ឮដំណឹងថា បញ្ជូនទៅដាក់នៅគុកទួលស្លែង ។ «ទោះបីជាខ្ញុំមិនបានដឹងថា គុកទួលស្លែងស្ថិតនៅកន្លែងណាក៏ដោយ ប៉ុន្តែអ្នកដែលត្រូវបញ្ជូនទៅទីនោះមិនដែលមានជីវិតត្រឡប់មកវិញទេ» ។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទោសដែលជាប់ឃុំនៅកន្លែងគាត់មិនដែលមានទោសរហូតយកទៅសម្លាប់ទេ ចំណែកអ្នកដែលស្លាប់នៅទីនេះ គឺព្រោះតែមិនមានអាហារហូបគ្រប់គ្រាន់និងមានជំងឺប៉ុណ្ណោះ ។

## មកស្រុកកំណើតសួរសុខទុក្ខឪពុកម្តាយ

ដោយសារតែបានចាកចេញពីផ្ទះអស់រយៈពេលជាច្រើនឆ្នាំ រីម ក៏បានសុំការអនុញ្ញាតពីអង្គការមកលេងផ្ទះ ។ មុនចេញដំណើរមក រីម បានឆ្លៀតពេលទំនេររកខស និងរបស់របរមួយចំនួនទៀតយកមកផ្ញើឪពុកម្តាយ ។ ពេលមកដល់ផ្ទះ ឪពុកម្តាយរបស់ រីម បានយកអង្ករដែលគាត់លួចសន្សំទុកតាំងពីយូរមកដាំបាយឲ្យគាត់ហូប ។ រីម អាណិតឪពុកម្តាយរបស់គាត់ជាខ្លាំង ព្រោះគាត់ទាំងពីរមិនហ៊ានយកអង្ករមកដាំហូបខ្លួនឯងទេ បែរជាយកមកដាំឲ្យគាត់ហូបទៅវិញ ។ ដូច្នេះ រីម បានបដិសេធថា «មិនបាច់ទេ ខ្លាចគេដឹង ហើយខ្ញុំក៏មិនហូបដែរ ម៉ែទុកពិសាខ្លួនឯងចុះ» ។

## ភារកិច្ចយាមអ្នកទោស

ពេលវិលត្រឡប់មកកងវិញ រីម មានភារកិច្ចដឹកនាំអ្នកទោសឲ្យធ្វើការដូចធម្មតា ដោយឆ្លាស់វេនបីថ្ងៃម្នាក់ជាមួយសមាជិកដទៃទៀត ជួនកាលរយៈពេលមួយសប្តាហ៍ម្តង ។ ទោះបីជា រីម បានបែងចែកការងារឲ្យអ្នកទោសជីកដី ឬលើកទំនប់ក្នុងមួយថ្ងៃឲ្យបានទទឹង២ម៉ែត្រ ជម្រៅ១ម៉ែត្រតាមបញ្ជារបស់អង្គការក៏ដោយ ប៉ុន្តែ រីម មិនដែលប្រតិបត្តិតាមបញ្ជានេះទាំងស្រុងទេ ជាក់ស្តែងពេលអ្នកទោសធ្វើការគាត់តែងតែបន្ធូរបន្ថយ ហើយថែមទាំងលួចយកបាយឬដំឡូងស្ងោរមកផ្ញើអ្នកទោសទាំងនេះផង ដោយធ្វើមិនឲ្យធ្លាក់លើដីង ។ លើសពីនេះទៅទៀត ពេលដែលដើរយាមយប់នៅម៉ោងប្រហែល១២យប់ រីម ឃើញអ្នកទោសកំពុងដុតមាន់ គាត់មិនបានស្តីបន្ទោសឲ្យទេ គ្រាន់តែប្រាប់ថា «ប្រសិនបើស៊ី ក៏ស៊ីទៅចុះ តែកុំឲ្យបែកការណ៍» ។ ដូច្នេះ អ្នកទោសទាំងនោះតែងតែសរសើរពីចិត្តសប្បុរសរបស់ រីម ថា «បងយើងមិនបានហូបទេ ព្រោះបើនៅក្រោមការគ្រប់គ្រងរបស់ ណាល់ មានតែសម្លុតថែមសូម្បីតែទៅជុះនោមក៏តឹងតែងដែរ» ។ រីម ត្រូវបានអ្នកទោសស្រឡាញ់រាប់អានគាត់គ្រប់គ្នា ព្រោះគាត់ចិត្តល្អ ថែមទាំងហ៊ានតវ៉ាជាមួយនឹងមេកងគាត់អំពីការហូបចុកថា «ខ្ញុំហូបសល់ ចេះតែចែកឲ្យគ្នាហូបទៅ មិនបាច់ជះចោលទេ ឲ្យគ្នាហូបទើបមានកម្លាំងកាប់ដីសូម្បីតែបងក៏អ៊ីចឹងដែរ បើគ្មានកម្លាំងគឺមិនអាចធ្វើការងារកើតទេ ។

បងឯងហូបបបររាល់ថ្ងៃ បងឯងចេះតែញូថាហេវ ចុះទម្រាំគ្នាហូបបានតិចជាង ហើយធ្វើការច្រើនទៀត» ។ បន្ទាប់មក មេកងបានណែនាំគាត់ថា ប្រសិនបើថ្នាក់លើដឹង នឹងមានរឿងហើយ ។ ថ្ងៃក្រោយមកទៀត ស្រាប់តែគណៈឃុំចុះមកសួរគាត់ថា «ដីកដំឡូងធ្វើអ្វី?» ។ ក្រោយពីប្រាប់ថាយកទៅស្ងោរហូប គណៈឃុំនោះមិនបានស្តីបន្ទោសឲ្យគាត់ទេ ថែមទាំងតបមកវិញថា «ដីកឲ្យបានច្រើនយកមកគាត់ហូបផង» ។ ក្រៅពីការងារនេះ រីម ត្រូវទៅទាក់ទងជាមួយទ័ពស្រុកនិងឈ្លបផ្សេងទៀត ដើម្បីដើរល្បាតតាមភូមិឃុំនិងស្រុក ។

នៅឆ្នាំដដែលនោះ ពេលដែលអង្គការចាប់ក្មេងស្រីគម្នាក់អាយុប្រហែលជា១៨ឆ្នាំយកមកដាក់កន្លែងរបស់គាត់ ដោយចោទថាជាខ្មែរខ្មាំង គាត់មិនបានធ្វើបាបក្មេងស្រីនេះទេ ថែមទាំងបានចែករបបអាហារមួយចំណែករបស់គាត់ទៅឲ្យទៅឲ្យក្មេងស្រីនេះទៀត ។ ប៉ុន្តែ ទោះបីជា រីម ព្យាយាមជួយក្មេងស្រីនេះយ៉ាងណាក៏ដោយ ក៏ចុងក្រោយក្មេងស្រីនេះនៅតែស្លាប់ដោយសារពុលពងគីង្គក់ ។ រីម អាណិតក្មេងស្រីនេះណាស់ ព្រោះគាត់មិនអាចជួយសង្គ្រោះបាន ។

## ជាប់គុកព្រោះធ្វេសប្រហែស

ដោយសារតែការគ្រប់គ្រងមានភាពធូររលុង ស្រាប់តែមានអ្នកទោសឈ្មោះ វ៉ន បានលួចរត់ចេញរួចពេលដែលកំពុងធ្វើពលកម្ម ។ បន្ទាប់ពីគាត់រាយការណ៍ប្រាប់អង្គការ រីម ត្រូវបានចាប់យកទៅដាក់ឃុំចំនួនបីថ្ងៃ ។ មុនពេលចាប់ខ្លួន គណៈឃុំបានយករំពាត់មកវាយ រីម ហើយនិយាយថា «ចាប់អាហ្នឹងយកមកដាក់ខ្នោះ ព្រោះអាហ្នឹងហើយដែលលួចដោះលែងអ្នកទោស» ។ ទោះបីជា រីម ព្យាយាមប្រាប់ពីមូលហេតុដែលអ្នកទោសរត់រួចយ៉ាងណាក៏ដោយ ក៏ពាក្យសម្តីរបស់គាត់មិនបានធ្វើឲ្យគេជឿដែរ ។ «ខ្ញុំមិនបានលែងអ្នកទោសទេ អ្នកទោសមានឱកាសរត់រួចដោយសារតែខ្ញុំអង្គុយងោកមួយសន្ទុះ» ។ រីម មានអារម្មណ៍ភ័យខ្លាចខ្លាំងណាស់ ព្រោះគិតថាមិនដឹងជាពេលណាទើបបានរួចពីគុក ។ រយៈពេលបីថ្ងៃក្រោយពីចាប់ខ្លួន វ៉ន បាន ទើបអង្គការដោះលែងគាត់ឲ្យធ្វើការដូចធម្មតាវិញ ។ រីម ក៏មិនដឹងថាហេតុអ្វីបានជាអ្នកទោសរត់ចេញពីគុកទេ ព្រោះគាត់គិតថា គាត់មិនដែលបានវាយធ្វើបាបលើអ្នកទោសឬរាយការណ៍អាក្រក់ពីអ្នកទោសណាម្នាក់ទេ ហើយពេលដែលគាត់មានអ្វីហូប គាត់តែងតែចែករំលែកទៅឲ្យអ្នកទាំងនោះជានិច្ចដូចជា ពេលមានដំឡូង ឬពោត គាត់តែងតែវេចដាក់ក្រមាយកទៅឲ្យ ថែមទាំងមិនប្រកាន់ថាអ្នកទោសនោះជាប្រជាជន១៧មេសា ឬប្រជាជនមូលដ្ឋានទេ ។

ក្រោយពី វ៉ន ត្រូវអង្គការធ្វើទារុណកម្មពីបទលួចរត់ ទ័ពស្រុកក៏បញ្ជូន វ៉ន មកដាក់ឃុំនៅកន្លែងគាត់គ្រប់គ្រងដដែល ។ ទោះបីជា វ៉ន បានលួចរត់បណ្តាលឲ្យ រីម ជាប់គុករយៈពេលបីថ្ងៃក៏ដោយ ក៏គាត់មិនមានគំនុំ និងខឹងជាមួយ វ៉ន ដែរ ហើយថែមទាំងបានសួរពីមូលហេតុដែលលួចរត់ទៀតផង ។ បន្ទាប់មក វ៉ន បានសារភាពកំហុសដែលបានលួចរត់បណ្តាលឲ្យគាត់ជាប់គុកថា «ខ្ញុំមិនគួរលួចរត់ បណ្តាលឲ្យបងជាប់ខ្នោះនោះទេ ។ ខ្ញុំឃើញមានតែបងឯងម្នាក់ប៉ុណ្ណោះដែលស្រួលជាងគេ ពេលមានចំណីយកមកឲ្យខ្ញុំហូប» ។ រីម មិនបានស្តីបន្ទោសឲ្យ វ៉ន ទេ ថែមទាំងណែនាំថា «ប្រសិនបើហែ្អងភ្ញាក់ខ្លួនហើយ ឈប់ធ្វើបែបហ្នឹងទៀត» ។ នៅទីនេះ អ្នកទោសដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ រីម ភាគច្រើនមិនសូវទទួលការលំបាកទេ ដោយក្នុងចំណោមនោះមានអ្នកទោសម្នាក់បានរៀបរាប់ថា «ពេលខ្ញុំធ្វើការជាមួយគេ គេវាយខ្ញុំស្ទើរតែរៀងរាល់ថ្ងៃ ពេលធ្វើការជាមួយបង គឺបងចិត្តល្អណាស់ ប្រសិនបើមានចំណីយកមកចែកខ្ញុំហូបទៀត» ។ បន្ទាប់មក វ៉ន បានសន្យាជាមួយគាត់ថា ឈប់លួចរត់ទៀតហើយ ។ រីម បញ្ជាឲ្យ វ៉ន ធ្វើការដូចធម្មតាវិញ ។ ដោយសារខ្លាចមានអ្នកទោសលួចរត់ជាលើកទីពីរទៀត ចុងក្រោយ រីម បាននិយាយទៅកាន់អ្នកទោសទាំងនោះថា «ត្រូវគោរពតាមបញ្ជារបស់អញ ប្រសិនបើបាត់កម្លាំង អញនឹងជាប់គុកដោយសារពួកហែ្អងហើយ» ។

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានកត់ឈ្មោះរបស់ រីម ឲ្យមកវាយជាមួយកងទ័ពវៀតណាមវិញ ។ ពេលនោះ អ្នកទោសដែលនៅក្រោមការគ្រប់គ្រងរបស់ រីម ព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្លួនជាខ្លាំង ព្រោះខ្លាចអ្នកដែលមកជំនួសធ្វើបាបពួកគាត់ ។ «ប្រសិនបើបងចាកចេញ យើងទាំងអស់គ្នានឹងត្រូវឈ្លបផ្សេងទៀតធ្វើបាបហើយ» ។ តាមពិត រីម ក៏មិនចង់ចាកចេញពីទីនេះដែរ ប៉ុន្តែនេះជាភារកិច្ចដែលអង្គការចាត់តាំង គាត់មិនអាចប្រឆាំង

នឹងបញ្ហាបានទេ ។ មុនចាកចេញ រឹម បានផ្តែផ្តាំឲ្យអ្នកទោសដែលនៅក្រោមការគ្រប់គ្រងរបស់គាត់ថា «យើងប្រុងប្រយ័ត្នខ្លួនទៅ គេឲ្យធ្វើអី ត្រូវធ្វើហ្នឹង មិនត្រូវរឹងរូសជាមួយគេទេ កុំឲ្យគេធ្វើបាប» ។ ចុងក្រោយ រឹម បានប្រាប់អ្នកទោសទាំងនោះថា «អ្នកធ្វើល្អបានល្អ អ្នកធ្វើអាក្រក់បានអាក្រក់» ។

នៅឆ្នាំ១៩៩២ រឹម បានរៀបការជាមួយប្រពន្ធឈ្មោះ អ៊ឹ សេង អាយុ៤៥ឆ្នាំ មានស្រុកកំណើតនៅកំពត ស្រុកអង្គរជ័យ ។ សព្វថ្ងៃ រឹម មានកូនបីនាក់ (ប្រុស២ ស្រី១) ។ រឹម ប្រកបមុខរបរធ្វើជាអ្នកលេងភ្លេងការ ។

**គាត លក្ខិណា**

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺសម្រាប់ប្រជាជនកម្ពុជា

នាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនូវសុន្ទរកថាដ៏វែងមួយកាលពីថ្ងៃទី៣១ ខែមីនា ក្នុងឱកាសបើកសម្ពោធផ្លូវមួយខ្សែនៅក្រុងព្រះសីហនុ ។ ក្នុងចំណោមប្រធានបទទាំងអស់ដែលគាត់បានធ្វើការពិភាក្សាគឺសុទ្ធតែទាក់ទងនឹងបុណ្យរំឭកខួបនៃការស្នើសុំ និងកិច្ចពិភាក្សាថ្ងៃដំបូងបង្អស់របស់តុលាការកាត់ក្តីខ្មែរក្រហម ។ យុត្តិធម៌ត្រូវបានឲ្យនិយមន័យប្លែកៗ ហើយពាក្យថា យុត្តិធម៌គឺជាគោលគំនិតមួយដែលទាមទារឲ្យមានការពិភាក្សាវែកញែកនៅក្នុងបរិយាកាសបណ្ឌិតសភា ។ និយមន័យនៃពាក្យយុត្តិធម៌របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន គឺមានលក្ខណៈធំទូលាយ ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានទឹកចិត្តសប្បុរសដោយបានផ្តល់នូវជម្រើសមួយដ៏ល្អក្នុងការប្រារព្ធនូវបុណ្យរំឭកខួបថ្ងៃទី៣០ ខែមីនា ដែលជាថ្ងៃដំបូងនៃដំណើរការកាត់ក្តីធ្វើជាថ្ងៃមួយតំណាងឲ្យការចងចាំនិងយុត្តិធម៌ តាមរយៈការក្រើនរំឭក «ថ្ងៃទី២០ ខែឧសភា ជាថ្ងៃនៃការចងគំនុំ» ។ ថ្ងៃទី៣០ ខែមីនា ដែលជាថ្ងៃនៃការចាប់ផ្តើមដំណើរការអង្គសវនាការរបស់ ឌុច ហើយក៏ជាថ្ងៃនៃការវាយប្រហារដោយការបោកគ្រាប់បែកដៃក្នុងបាតុកម្មប្រឆាំងមួយដែលធ្វើឡើងកាលពីឆ្នាំ១៩៩៧ដែរ ។ នេះជាចំណាប់អារម្មណ៍មួយដែលថាព្រឹត្តិការណ៍ដ៏ចម្បងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដើម្បីឲ្យស្របជាមួយនឹងថ្ងៃដទៃទៀត ។ ជាឧទាហរណ៍មួយផ្សេងទៀត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជ្រើសយកថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ជាថ្ងៃធ្វើការចោទប្រកាន់លើ ឌុច ដែលជាថ្ងៃមួយស្របនឹងថ្ងៃបើកសម្ពោធការប្រកួតកីឡាអូឡាំពិច នៅទីក្រុងប៉េកាំងផងដែរ ។

ខ្ញុំសូមបន្ថែមលើនេះផងដែរថា តុលាការកាត់ក្តីខ្មែរក្រហមជាដំណើរការស្វែងរកយុត្តិធម៌មួយដែលមិនធ្លាប់មានពីមុនមកនៅក្នុងប្រទេសកម្ពុជា និងជាវេទិកាមួយដែលរាល់កិច្ចខិតខំប្រឹងប្រែងផ្សេងៗក្នុងការស្វែងរកនូវយុត្តិធម៌ដ៏ពិតប្រាកដបានចាប់ផ្តើមធ្វើការអភិវឌ្ឍរបស់ខ្លួន ។ តុលាការកាត់ក្តីខ្មែរក្រហមនេះក៏ជាវេទិកាមួយដែលធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជាអាចនឹងត្រៀមខ្លួនរួចជាស្រេចក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីប្រែក្លាយកម្ពុជាទៅជាសង្គមដ៏ស្អាតស្អំមួយ ។ ភាពជោគជ័យនៃតុលាការកាត់ក្តីនេះអាចនឹងផ្តល់ជាប្រយោជន៍ដ៏សំខាន់និងជាលើកដំបូងដល់កម្ពុជា ។ ផ្ទុយទៅវិញ បរាជ័យអាចប្រហែលនឹងក្លាយជាលទ្ធផលមួយដែលមនុស្សមួយចំនួនចង់ឃើញ ប៉ុន្តែលទ្ធផលបែបនេះនឹងផ្តោតទៅលើកំហុសឆ្គងរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការរក្សានូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ហើយនឹងនាំមកនូវផលអវិជ្ជមាននៃទស្សនៈអន្តរជាតិមកលើប្រទេសកម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺសម្រាប់ប្រជាជនកម្ពុជា ហើយនឹងក្លាយជាកេរមរតករបស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ។ ការសម្រេចបានដោយជោគជ័យនឹងនាំមកនូវសេចក្តីសរុបជារួមនៃដំណើរការកាន់កាប់អំណាចរបស់ខ្មែរក្រហម ដោយរំលាយការកាន់កាប់អំណាចនេះជាអង្គការនយោបាយនិងយោធា ដោយទទួលស្គាល់សមាជិកចាស់ពីរបបនេះ ពីសង្គមនិងនាំនូវយុត្តិធម៌ជូនដល់ជនរងគ្រោះ ។ ប្រជាជនកម្ពុជាមិនអាចស្វែងរកយុត្តិធម៌ដោយខ្លួនឯងបានទេ ។ ប្រជាជនកម្ពុជាត្រូវការការគាំទ្រពីរាជរដ្ឋាភិបាលដើម្បីសម្រេចនូវគោលបំណងនេះ ។ ខ្ញុំបានទុកកិច្ចពិភាក្សាវែកញែកនេះជាចំហសម្រាប់ដំណើរការកាត់ទោសបន្តទៀត ។

**អេង គុកថាយ**

# ភ័ស្តុតាងមិនអាចបដិសេធបានស្តីពីយុទ្ធសាស្ត្រឈ្លានពាន របស់វៀតណាមដែលជាអ្នកខាតទីនិយម និងអ្នកលេបយកទឹកដីកម្ពុជា

ចាប់ពីថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ នៅពេលដែលកងទ័ពបដិវត្តន៍និងប្រជាជនកម្ពុជាបានធ្វើឲ្យសត្រូវវៀតណាមទទួលបរាជ័យ និងបានបណ្តេញចេញពីទឹកដីកម្ពុជា សត្រូវវៀតណាមបានបន្តបាញ់កាំភ្លើងយន្ត ផ្លោងគ្រាប់ បញ្ជូនក្រុមស៊ើបការណ៍ និងក្រុមកុម្មង់ដូ ដើម្បីប្រមូលព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជាជាសម្ងាត់និងអនុវត្តការរំលោភឈ្លានពានចូលក្នុងទឹកដីកម្ពុជាជារៀងរាល់ថ្ងៃ ។ ទន្ទឹមនឹងនេះដែរ សត្រូវវៀតណាមបានធ្វើពុតជាស្រែកថា វៀតណាមចង់បាន «ចំណងមិត្តភាពដ៏ពិសេស» «សាមគ្គីភាពដ៏ពិសេស» ជាមួយកម្ពុជា និងចង់បង្កើត «កិច្ចចរចាលើបញ្ហាព្រំដែន» ក្នុងគោលបំណងកាត់បន្ថយកម្លាំងបដិវត្តន៍ឃ្លាំមើលពីសំណាក់ប្រជាជននិងកងទ័ពបដិវត្តន៍កម្ពុជា ។ ប៉ុន្តែប្រជាជននិងកងទ័ពបដិវត្តន៍កម្ពុជាដែលបានស្គាល់ច្បាស់ពីចរិតពុតត្បុត និងភាពមិនស្មោះត្រង់របស់វៀតណាមបានដាក់កម្លាំងបដិវត្តន៍ឃ្លាំមើលជាប្រចាំ និងបានវាយប្រហារលើសត្រូវវៀតណាមឲ្យទទួលបរាជ័យរាល់លើកនៅពេលដែលទ័ពវៀតណាមទាំងនោះចូលលុកលុយ ឈ្លានពាន និង ប្រមូលយកព័ត៌មាននៅក្នុងទឹកដីកម្ពុជា ។

ឆ្លងតាមចម្លើយសារភាពរបស់ ហ៊ុញ វ៉ាន់ហ័រ ជាប្រធានកងវរសេនាតូចលេខ៨ កងពលធំលេខ៧ ដែលត្រូវបានចាប់ខ្លួនដោយកងទ័ពបដិវត្តន៍កម្ពុជា នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ នៅភូមិព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ បានបង្ហាញយ៉ាងច្បាស់ថា ការស្រែកបែបនេះនិងសកម្មភាពការទូតដែលវៀតណាមហៅថា «កិច្ចចរចាលើបញ្ហាព្រំដែន» គឺសុទ្ធតែជាផែនការឧក្រិដ្ឋកម្មដែលធ្វើឡើងក្នុងគោលបំណងធ្វើឲ្យប្រជាជននៅលើពិភពលោកយល់ច្រឡំ និងធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យដាច់ចេញពីពិភពលោក ព្រមទាំងដើម្បីបិទបាំងនូវរាល់ការរំលោភឈ្លានពានរបស់ខ្លួនមកលើរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមពិត វៀតណាមមិនព្រមបោះបង់មហិច្ឆតាលេបយកទឹកដីកម្ពុជានិងគោលនយោបាយរបស់ខ្លួន ដោយបង្ខំឲ្យកម្ពុជាចូលជាសមាជិក «សហព័ន្ធឥណ្ឌូចិន» ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនដើម្បីធ្វើឲ្យវៀតណាមងាយស្រួលក្នុងការលេបយកទឹកដីកម្ពុជាក្នុងរយៈពេលមួយជាក់លាក់ ។

ដើម្បីសម្រេចនូវមហិច្ឆតានេះ សត្រូវវៀតណាមបានប្រើប្រាស់មធ្យោបាយកំសាកបំផុត ដោយប្រើលុយ មុខតំណែង និងឋានន្តរសក្តិ ដើម្បីបំពុលនិងសូកប៉ាន់ភ្នាក់ងាររបស់ខ្លួន ឬប្រើមធ្យោបាយគំរាមកំហែង ដោយបាញ់សម្លាប់នរណាដែលបដិសេធមិនគោរពតាមពាក្យសម្តីរបស់ខ្លួន ។ នេះគឺជា «គុណធម៌» របស់កងទ័ពវៀតណាម ។

**ចម្លើយសារភាពរបស់ ហ៊ុញ វ៉ាន់ហ័រ ប្រធានកងពលធំលេខ៧**

ខ្ញុំបាទឈ្មោះ ហ៊ុញ វ៉ាន់ហ័រ អាយុ២៨ឆ្នាំ ជាប្រធានកងពលលេខ២ កងអនុសេនាតូចលេខ១ អនុសេនាធំលេខ៥ កងវរសេនាតូចលេខ៥ កងវរសេនាធំលេខ៣ និងកងពលធំលេខ៧ ។ ខ្ញុំកើតនៅភូមិវិញដុង ឃុំវិញតេ ស្រុកចូវភូ ខេត្តអានយ៉ាង ។

ក្នុងឆ្នាំ១៩៧៤ លោកឧត្តមសេនីយ៍ ហ៊ុញ វ៉ាន់ថុង បានណែនាំខ្ញុំឲ្យចូលធ្វើជាកងទ័ព ។

ក្នុងឆ្នាំ១៩៧៥ ខ្ញុំត្រូវបានបញ្ជូនឲ្យមកបម្រើការក្នុងកងពលធំលេខ៧ តាមរយៈលោកឧត្តមសេនីយ៍ ធុង ។

ក្នុងឆ្នាំ១៩៧៦ ខ្ញុំស្នាក់នៅ មីឌុក លោកមេបញ្ជាការ ង្វៀន វ៉ាន់ឌីន បានបង្រៀនខ្ញុំអំពីរឿងនយោបាយ ។ លោកមេបញ្ជាការបាននិយាយថា «បក្សកុម្មុយនីស្តវៀតណាម គឺជាបងធំសហព័ន្ធកម្ពុជា» ។

ក្នុងអំឡុងពេលសិក្សា លោកមេបញ្ជាការ ង្វៀង វ៉ាន់ឌីន បានប្រាប់ខ្ញុំថា បក្សកុម្មុយនីស្តវៀតណាមនឹងវាយយកប្រទេសកម្ពុជាធ្វើជាកម្មសិទ្ធិ ដើម្បីឲ្យប្រជាជនវៀតណាមទាំងអស់បានចូលមករស់នៅនិងប្រមូលយកទ្រព្យសម្បត្តិរបស់កម្ពុជា ។ ដូច្នេះប្រទេសវៀតណាមនឹងមិនមានផ្ទៃដីតូចដូចជាពេលដែលខ្លួនបាន

ជួបប្រទះជាច្រើនឆ្នាំកន្លងមកនេះទេ ។

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៧៧ លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន មេបញ្ជាការកងពលធំលេខ៧ បានដឹកនាំកងទ័ពទៅកាន់ជ្រលងភ្នំ ទ្រីញ បៀន និង ភូកឿង ហើយបានវាយសម្រុកចូលមកក្នុងប្រទេសកម្ពុជាអស់រយៈពេល៤ថ្ងៃ ។ នៅថ្ងៃទី២៦ ខែមិថុនា កងទ័ពកម្ពុជាបានធ្វើការវាយបកទៅវិញ ហើយបានបង្ខំឲ្យវរសេនីយ៍ឯក ត្រាន វ៉ាន់លួន ដកទ័ពចេញពីទឹកដីកម្ពុជានៅថ្ងៃទី២៨ ។ កងពលធំលេខ៧ បានត្រឡប់ទៅកាន់ ចូវដុក និង បោះទីតាំងនៅទីនោះវិញ ។

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧ លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បានប្រមូលកងពលធំលេខ៧ ឲ្យចូលលុកលុយភ្នំដិន ស្ថិតក្នុងទឹកដីកម្ពុជា (N. of T. ) ។ មុនពេលកងវរសេនាធំចំនួនបួនត្រូវបណ្តេញឲ្យត្រឡប់ទៅវិញតាមរយៈការវាយប្រហារយ៉ាងខ្លាំងក្លារបស់កងទ័ពកម្ពុជា កងវរសេនាធំចំនួនបួននេះបានធ្វើសកម្មភាពលុកលុយភ្នំដិនអស់រយៈពេលបួនថ្ងៃ ។

ប៉ុន្មានថ្ងៃក្រោយមក លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បានសុំឲ្យខ្ញុំទៅស៊ើបយកព័ត៌មាននៅក្នុងទឹកដីកម្ពុជា ។ ប្រសិនបើបេសកកម្មនេះបានសម្រេច ខ្ញុំនឹងបានឡើងតំណែងជាពលបាល ។










*នៅក្នុងរូបថតកាលពីមុនដែលមិនទាន់បោះពុម្ពផ្សាយដែលទទួលបាននៅខែមុនពីបណ្ណសារដ្ឋានផ្លូវការរបស់វៀតណាមដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ទាហានខ្មែរក្រហមបីនាក់ត្រូវបានចាប់ខ្លួនដោយកងទ័ពវៀតណាមនៅអំឡុងពេលនៃការវាយឆ្មក់ចូលព្រំដែននៅឆ្នាំ១៩៧៧ ផ្តល់ចម្លើយសារភាព ។ ពីឆ្វេងទៅស្តាំ ៖ ញ៉ឹម សារ៉ន អាយុ២៧ឆ្នាំ នៅខេត្តស្វាយរៀង ត្រូវបានចាប់ខ្លួននៅថ្ងៃទី៩ ខែកក្កដា នៅខេត្តតាយនិញ របស់វៀតណាម កន្លែងដែលខ្មែរក្រហមប្រឡាក់ឈាមវាយលុកនៅខែកញ្ញានៅឆ្នាំនោះ ។ សំ សារិន អាយុ២៦ឆ្នាំ នៅខេត្តព្រៃវែងត្រូវបានចាប់ខ្លួននៅទីតាំងដូចគ្នានៅថ្ងៃ ៤ ខែតុលា ។ អ៊ឹម ចាន់ថន អាយុ២៧ឆ្នាំ នៅខេត្តស្វាយរៀង ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី៤ ខែវិច្ឆិកា បានអះអាងថាបានចូលរួមបដិវត្តន៍កម្ពុជានៅឆ្នាំ១៩៧៣ ហើយបានដឹកនាំកងទ័ពខ្មែរក្រហមទៅកាន់ភាគខាងត្បូងពីផ្លូវជាតិលេខ១ ទៅដល់វៀតណាម កន្លែងដែលគាត់រងរបួសនៅក្នុងការតស៊ូ ដោយយោងទៅតាមកំណត់ត្រាផ្លូវការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បាននិយាយនៅថ្ងៃសុក្រថា រូបភាពបានជួយបកស្រាយពន្យល់ពីរបៀបដែលវៀតណាមយល់ពីការមិនពេញចិត្តរបស់ខ្មែរក្រហមមុនពេលមានជម្លោះទ្រង់ទ្រាយធំនៅឆ្នាំ១៩៧៨ ។ គាត់បាននិយាយថា «វាបានជួយពន្យល់ជាច្រើនអំពីទំនាក់ទំនងរបស់វៀតណាម និងខ្មែរក្រហមនៅពេលនោះ» ។ គាត់និយាយទៀតថា «វាប្រៀបដូចជាការវាយគ្នារបស់បងនិងប្អូន ហើយនៅទីបញ្ចប់ទើបគេដឹងថាគេទាំងពីរមានឪពុកម្តាយខុសគ្នា» ។ នៅឯតុលាការខ្មែរក្រហមនៅថ្ងៃច័ន្ទនេះ ណាយ៉ាន់ ចាន់ដា អ្នកប្រវត្តិសាស្ត្រ ហើយក៏ជាអ្នកការសែតនឹងផ្តល់កសិណសាក្សីអំពីជម្លោះប្រដាប់អាវុធដែលវៀតណាមនិងអ្នកផ្តាច់ខ្លួនពីខ្មែរក្រហមផ្តួលរំលំប៉ុល ពតនៅឆ្នាំ១៩៧៩ ។*

លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បានសួរខ្ញុំអំពីរឿងនេះចំនួនពីរលើក ។ ខ្ញុំបានលួចចូលមកក្នុងទឹកដីកម្ពុជា រួចបានឃើញកងទ័ពកម្ពុជាស្ថិតនៅចម្ងាយពីរគីឡូម៉ែត្រពីព្រំដែន ។ ខ្ញុំក៏បានត្រឡប់ទៅវិញនៅក្នុងថ្ងៃដដែលដើម្បីរាយការណ៍ជូនលោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន ។

នៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ១៩៧៨ លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បានបញ្ជូនខ្ញុំ និង ង្វៀន វ៉ាន់ង្វៀ ឲ្យទៅស៊ើបការណ៍នៅក្នុងទឹកដីកម្ពុជាដែលមានចម្ងាយពីរគីឡូម៉ែត្រពីព្រំដែន ។ ខ្ញុំ និង ង្វៀន វ៉ាន់ង្វៀ ត្រូវពិនិត្យមើលទីតាំងទាំងអស់របស់កងទ័ពកម្ពុជា និងកម្លាំងទ័ពកម្ពុជានៅតាមទីតាំងនីមួយៗដោយត្រួតពិនិត្យចំនួនរថក្រោះនិងទីតាំងដាក់រថក្រោះ ចំនួនកាំភ្លើងធំនិងចម្ងាយដាក់តាំងកាំភ្លើងធំទាំងនោះពីខ្សែព្រំដែន ។ លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បានបន្ថែមទៀតថា យើងត្រូវតែពុះពារយកឈ្នះលើការធ្វើទារុណកម្ម មិនសារភាព និងមិនត្រូវឲ្យកម្ពុជាដឹងពីរឿងសម្ងាត់របស់បក្សកុម្មុយនីស្តវៀតណាមទេ ដូចជាទីតាំងបោះជំរំរបស់កងទ័ពវៀតណាម និងគម្រោងការវាយប្រហារមកលើកម្ពុជា ។ លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បានប្រាប់ខ្ញុំ និង ង្វៀន វ៉ាន់ង្វៀ ឲ្យនិយាយកុហកកងទ័ពកម្ពុជាថា យើងជាប្រជាជនក្រីក្រដែលចូលមករកត្រីដូរយកអង្ករ ។ ប្រសិនបើការស៊ើបការណ៍មានភាពច្បាស់លាស់ និងពេញលេញ កងទ័ពវៀតណាមនឹងវាយលុកប្រទេសកម្ពុជាគ្រប់ខេត្ត ស្រុក និងភូមិ នៅខែមីនា ឆ្នាំ១៩៧៨ ។ លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បានឲ្យយើងដឹងអំពីការបង្កើតរាជរដ្ឋាភិបាលថ្មីនៅកម្ពុជាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាមក្នុង «សហព័ន្ធឥណ្ឌូចិន» ។ ស្របពេលជាមួយគ្នានេះ យើងនឹងមានភាពសប្បាយរីករាយ ។ លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បាននិយាយថា ប្រសិនបើបេសកកម្មនេះបានសម្រេច យើងនឹងបានឡើងតំណែងជាឧត្តមសេនីយ៍ ដែលអាចទទួលបានប្រាក់ខែបន្ថែម និងការសុំច្បាប់ពិសេស ។ លោកវរសេនីយ៍ឯក បាននិយាយបន្ថែមទៀតថា «រីឯបក្សកុម្មុយនីស្តវៀតណាមយើងបានធ្វើកិច្ចចរចាមួយ ដើម្បីដោះស្រាយបញ្ហាព្រំដែន ។ ទាំងនេះគ្រាន់តែជាបញ្ឆោនយោបាយតែប៉ុណ្ណោះ ហើយយើងធ្វើដូច្នេះគឺដើម្បីឲ្យពិភពលោកជឿថា យើងស្រឡាញ់សន្តិភាព ហើយភាគីកម្ពុជាវិញជាអ្នកឈ្លានពានប្រទេសវៀតណាម ។ ដូច្នេះពិភពលោកនឹងងាកមកគាំទ្រប្រទេសវៀតណាមយើង ។ តាមរយៈឱកាសនេះ យើងនឹងអាចវាយប្រហារនិងយកប្រទេសកម្ពុជាធ្វើជាកម្មសិទ្ធិដើម្បីសម្រេចគោលការណ៍ «សហព័ន្ធឥណ្ឌូចិន» របស់ហូជីមិញ និងបក្សកុម្មុយនីស្តវៀតណាម ។ សម្រាប់កិច្ចចរចាវិញ យើងធ្លាប់មានបទពិសោធន៍ជាមួយសហរដ្ឋអាមេរិកម្តងរួចមកហើយ» ។

បន្ទាប់ពីប្រជុំរួច យើងទាំងពីរនាក់ ខ្ញុំ និង ង្វៀន វ៉ាន់ង្វៀ បានត្រៀមខ្លួនរួចជាស្រេច សម្រាប់បេសកកម្មរបស់យើង ។

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំបានឆ្លងព្រែកដីកវិញតេ និងលួចចូលមកក្នុងទឹកដីកម្ពុជា ដែលឃ្លាតឆ្ងាយពីព្រំដែនប្រហែលមួយគីឡូម៉ែត្រ ។ នៅទីនោះ ខ្ញុំបានឃើញកងទ័ពកម្ពុជាបោះជំរំនៅចម្ងាយពីរគីឡូម៉ែត្រពីព្រំដែន ។ ដោយខ្លាចកងទ័ពកម្ពុជាឃើញ ខ្ញុំក៏ត្រឡប់មកវិញ រួចរាយការណ៍ដល់លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន ប៉ុន្តែលោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បាននិយាយថា ខ្ញុំ និង ង្វៀន វ៉ាន់ង្វៀ ត្រូវតែត្រឡប់ទៅយកព័ត៌មានម្តងទៀត ដើម្បីបានព័ត៌មានច្បាស់ជាងនេះនិងដើម្បីពិនិត្យមើលឲ្យបានច្បាស់ជាងនេះ ។

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បានបង្គាប់ឲ្យខ្ញុំ និង ង្វៀន វ៉ាន់ង្វៀ ទៅស៊ើបយកព័ត៌មានក្នុងទឹកដីកម្ពុជាម្តងទៀត ដែលមានចម្ងាយប្រហែលជាបួនគីឡូម៉ែត្រ ស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់បំផុត ។ លើកនេះ លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បាននិយាយថា យើងត្រូវតែស៊ើបយកព័ត៌មាននេះឲ្យបាន ពីព្រោះបេសកកម្មនេះមានសារសំខាន់ខ្លាំងណាស់ ប៉ុន្តែខ្ញុំនិយាយថា យើងមិនអាចចូលទៅក្នុងទឹកដីនេះបានទេ ពីព្រោះកងទ័ពកម្ពុជាយាមនៅគ្រប់ព្រៃទាំងអស់ ហើយយើងមិនទាន់បានដឹងថាទីតាំងជំរំទ័ពកម្ពុជានៅកន្លែងណានៅឡើយទេ ។ លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បាននិយាយថា ប្រសិនបើខ្ញុំ និង ង្វៀន វ៉ាន់ង្វៀ បដិសេធមិនព្រមទៅ នោះមានន័យថាយើងមិនគោរពតាមបញ្ជារបស់កងទ័ព បញ្ជារបស់ជាតិ នៅពេលដែលប្រទេសជាតិត្រូវការយើង ។

(តទៅទំព័រទី៨៥)

# ចម្លើយកសិណសាក្សីរបស់ជនរងគ្រោះនៃមន្ទីរសន្តិសុខ ម-១៣ និង សេចក្តីសារភាពរបស់ ឌុច

ចាប់តាំងពីការស្រាវជ្រាវលើកដំបូងរបស់ខ្ញុំទៅលើមន្ទីរសន្តិសុខម-១៣ កាលពីថ្ងៃទី២៨-៣០ ខែមេសា ឆ្នាំ២០០៣ មក ខ្ញុំមិនដែលមានមហិច្ឆតាអ្វីក្រៅពីចង់ឲ្យការស្រាវជ្រាវនេះក្លាយទៅជាឯកសារប្រវត្តិសាស្ត្រ និងការចងចាំពីអ្វីដែលបានកើតឡើងកាលពីអតីតកាលឡើយ ។ រយៈពេល៦ឆ្នាំគត់បន្ទាប់ពីការស្រាវជ្រាវឯកសារនេះបានក្លាយទៅជាភស្តុតាងមួយក្នុងការភ្ជាប់អតីតប្រធានមន្ទីរសន្តិសុខ ម-១៣ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅនឹងការគ្រប់គ្រងមន្ទីរសន្តិសុខ ស-២១ ដែលបានប្រព្រឹត្តទៅក្នុងអំឡុងឆ្នាំ១៩៧៦-១៩៧៩ នៅក្នុងអង្គសវនាការដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ ផ្តើមចេញពីការធ្វើបទសម្ភាសន៍ផ្ទាល់តាមរបៀបនៃការធ្វើសម្ភាសន៍បែបប្រវត្តិសាស្ត្ររវាងខ្ញុំជាមួយអតីតកងការពារនិងអតីតអ្នកទោសនៅមន្ទីរសន្តិសុខ ម-១៣ ចាន់ វឿន និង ចាន់ ខន បានត្រូវកោះហៅឲ្យមកធ្វើសាក្សីឆ្លើយបំភ្លឺនៅក្នុងអង្គសវនាការអំពីប្រវត្តិសកម្មភាពការងាររបស់ខ្លួន ព្រមទាំងជាកសិណសាក្សីពីបទឧក្រិដ្ឋដែល ឌុច បានសាងឡើងក្នុងរយៈពេលដែលខ្លួននៅគ្រប់គ្រងអំណាចជាប្រធានមន្ទីរសន្តិសុខ ម-១៣ ។


អ្នកភូមិក្នុងឃុំអមលាំង

នៅមុខអង្គជំនុំជម្រះសាលាដំបូង ឌុច បានទទួលស្គាល់ស្ទើរគ្រប់រឿងរ៉ាវទាំងអស់ដែលបានកើតឡើងនៅក្នុងមន្ទីរសន្តិសុខ ម-១៣ ទោះជា ឌុច លើកឡើងថាជាការអនុវត្តបញ្ជាពីថ្នាក់លើក៏ដោយ ។ ប៉ុន្តែអ្វីដែលធ្វើឲ្យមានការចាប់អារម្មណ៍ខ្លាំងជាងគេនោះគឺ ឌុច បានបដិសេធ ចាន់ វឿន ថាមិនមែនជាកងការពារមន្ទីរសន្តិសុខ ម-១៣ ។ ចំណែក ចាន់ ខន វិញ ឌុច បានលើកឡើងត្រង់ៗថា ពិតជាកងការពារនៅមន្ទីរសន្តិសុខ ម-១៣ ដែលខ្លួនបានជ្រើសរើសដោយផ្ទាល់មែន ។ ខ្ញុំនៅចងចាំថា នៅពេលដែលខ្ញុំធ្វើកិច្ចសម្ភាសន៍ដំបូងរយៈពេលជិតមួយម៉ោងជាមួយ ចាន់ វឿន កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣ នៅភូមិកុមាររមាស ឃុំអមលាំង ស្រុកថ្ពង គាត់បានបញ្ជាក់ថា គាត់ពិតជាក្មេងម្នាក់ក្នុងចំណោមក្មេងៗឯទៀតដែល ឌុច សម្រិតសម្រាំងយកធ្វើជាកងការពារនៅមន្ទីរសន្តិសុខម-១៣ ។ ចាន់ វឿន មិនហ៊ានប្រកែកជាមួយ ឌុច នៅក្នុងអង្គសវនាការចំពោះការមិនទទួលស្គាល់ខ្លួនជាកងការពារមន្ទីរសន្តិសុខ ម-១៣ ឡើយ ប៉ុន្តែ វឿន នៅតែនិយាយការពិតដូចដែលខ្លួនបានស្បថមុននឹងចូលធ្វើជាសាក្សីថា គាត់គឺជាកងការពារនៅមន្ទីរសន្តិសុខ ម-១៣ ពិតមែន ។ វឿន បានដឹងរឿងរ៉ាវជាច្រើនទាក់ទងនឹងសកម្មភាពឧក្រិដ្ឋរបស់ ឌុច ដូចក្នុងករណី ឌុច បានបាញ់សម្លាប់ជនរងគ្រោះដោយផ្ទាល់ដៃនៅមន្ទីរសន្តិសុខម-១៣ ។ ប៉ុន្តែ ឌុច បានសារភាពថាខ្លួនមិនដែលបានសម្លាប់អ្នកទោសណាម្នាក់ដោយផ្ទាល់ដៃទេ គឺគ្រាន់តែជាអ្នកបញ្ជាដ៏ម៉ឺងម៉ាត់ម្នាក់ ។ ទាក់ទិននឹងការបដិសេធរបស់ ឌុច ចំពោះ

វឿន ថាមិនមែនជាកងការពារនៅមន្ទីរសន្តិសុខ ម-១៣ ឌុច បានលើកហេតុផលថា គាត់មិនដែលមានកងការពារដែលមានតួនាទីជាកម្មាភិបាលសេដ្ឋកិច្ចផង និងកងការពារផងទេ ព្រមទាំងលើកឡើងថាពុំមានមន្ទីរសេដ្ឋកិច្ចនៅក្នុងមន្ទីរសន្តិសុខ ម-១៣ឡើយ ។

ប្រជាជនខ្មែរទូទាំងប្រទេសសុទ្ធតែបានដឹងពីដំណើរការជំនុំជម្រះនៅសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅលើករណីជនត្រូវចោទលេខ០០១ ឬករណី ឌុច ។ នៅពេលនេះ រឿងរ៉ាវនៅមន្ទីរសន្តិសុខ ម-១៣ បានលេចឮពេញត្រចៀកនៃជនកម្ពុជាទូទាំងប្រទេស ។ រឿងរ៉ាវប្រវត្តិសាស្ត្រនៅមន្ទីរសន្តិសុខ ម-១៣ ដែលខ្ញុំបានដឹងតាំងពី៦ឆ្នាំមុន និងនៅពេលនេះ វាជារឿងរ៉ាវពិតដែលបានកើតឡើងតាំងពី៣៨ឆ្នាំមុនម៉្លេះ ។ អ្វីដែលជាការពិតនិងជាការក្លែងបន្លំតាមរយៈសេចក្តីសារភាពរបស់ ឌុច គឺមានតែជនរងគ្រោះផ្ទាល់ប៉ុណ្ណោះដែលអាចវាយតម្លៃនិងកំណត់នូវរឿងរ៉ាវទាំងនេះបាន ហើយមានតែតុលាការទេ ដែលជាអ្នកសម្រេចថា តើ ឌុច ត្រូវទទួលទោសកម្រិតណាចំពោះអំពើឧក្រិដ្ឋរបស់ខ្លួន ។ សាធារណជនខ្មែរទូទៅ អ្នកសារ-ព័ត៌មានជាតិនិងអន្តរជាតិពិតជាវិលវល់ចំពោះភាពខុសគ្នារវាងសេចក្តីសារភាពរបស់ ឌុច និងចម្លើយរបស់សាក្សី ។ តើអ្នកទាំងនោះគួរជឿលើអ្វីដែល ឌុច និយាយប្រាប់តុលាការ ឬគួរជឿលើសាក្សី ចាន់ វឿន, ចាន់ ខន និង អ៊ុច ស៊ន ឬ ហ្រង់ស័រ ប៊ីហ្សូ? ទោះជាយ៉ាងនេះក្តី ប្រជាជនមូលដ្ឋានដែលធ្លាប់ឆ្លងកាត់ហេតុការណ៍នេះធ្លាប់ឃើញសកម្មភាពឃោរឃៅរបស់ ឌុច ក្នុងពេលដែល ឌុច នៅជាប្រធានមន្ទីរសន្តិសុខម-១៣ និងអ្នកដែលរស់នៅក្បែរមន្ទីរសន្តិសុខម-១៣ គឺជាអ្នកដឹងច្បាស់ជាងគេថាអ្វីដែលជាការពិតនិងអ្វីជាការមិនពិត ។ ដើម្បីជាសាក្ខីភាពចំពោះរឿងរ៉ាវទាំងអម្បាលមាណ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនចំនួន២០០នាក់ មកពីភូមិចំនួន៥គឺ ភូមិកុមារមាស ភូមិថ្នគប់ ភូមិទំនាប ភូមិថ្នល់បំបែក និងភូមិតាកោង ក្នុងឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ឲ្យចូលរួមស្តាប់ដំណើរការសួរដេញដោលរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះរឿងរ៉ាវនៅមន្ទីរសន្តិសុខ ម-១៣ ។

រយៈពេលជាង៣០ឆ្នាំបានកន្លងផុតទៅ ចម្ងល់ជាច្រើនទាក់ទងនឹងការបង្កើតមន្ទីរសន្តិសុខ ម-១៣ និងការសម្លាប់មនុស្សយ៉ាងសាហាវនៅទីនោះ បានត្រូវដោះស្រាយតាមផ្លូវច្បាប់តាមរយៈអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្វីដ្បិតតែ ឌុច បានឆ្លើយសំណួរជាច្រើនដែលចោទសួរដោយសហចៅក្រម សហព្រះរាជអាជ្ញានិងសហមេធាវី ប៉ុន្តែ ឌុច នៅតែធ្វើឲ្យប្រជាជនទូទាំងប្រទេសមានចម្ងល់កាន់តែខ្លាំងពាក់ព័ន្ធទៅនឹងការឆ្លើយសារភាពមិនអស់សេចក្តី ជាពិសេស ឌុច មិនបានធ្វើឲ្យប្រជាជននៅឃុំអមលាំងកោតសរសើរពីការទទួលទោសកំហុសរបស់ខ្លួននៅចំពោះមុខអង្គសវនាការឡើយ ។ មេភូមិថ្នគប់ឈ្មោះ ស្រី ឈឿន បានប្រាប់ថាប្រជាជនក្នុងភូមិរបស់គាត់មានអារម្មណ៍មិនសូវល្អចំពោះការឆ្លើយសារភាពភូតកុហករបស់ ឌុច ថាគ្មានអ្នកទោសណាម្នាក់ស្លាប់ដោយសារទឹកជំនន់ទេ ។ មេភូមិនិយាយដូច្នេះថា «ការពិត ឌុច និងកងការពារមិនអាចជញ្ជូនអ្នកទោសដែលជាប់ក្នុងរណ្តៅអស់ឡើយពេលដែលទឹកជំនន់មកដល់» ។ ភួង ចាន់ហ៊ីម ជាអនុភូមិកុមារមាស កាន់តែឈឺចាប់ថែមទៀតនៅពេលដែលគាត់បានស្តាប់ និងមើលឃើញផ្ទាល់នូវការឆ្លើយមិនពិតរបស់ ឌុច ចំពោះការស្លាប់របស់អ្នកទោស និងការបដិសេធ ចាន់ វឿន ថាមិនមែនជាកងការពារនៅមន្ទីរសន្តិសុខ ម-១៣ ។ ស្រី ឈឿន បាននិយាយប្រាប់ថា គាត់បានជជែកលែងជាមួយ ចាន់ វឿន ហើយ ចាន់ វឿន បានសម្តែងការខឹងសម្បាយ៉ាងខ្លាំងចំពោះ ឌុច រហូតស្ទើរតែស្ទុះទៅវាយ ឌុច នៅក្នុងអង្គជំនុំជម្រះពេលដែល ឌុច ព្យាយាមបដិសេធគាត់ថាមិនមែនជាកងការពារនៅមន្ទីរសន្តិសុខ ម-១៣ ។ ក្រៅពី ស្រី ឈឿន និង ភួង ចាន់ហ៊ីម ខ្ញុំបានសម្ភាសន៍ប្រជាជនចំនួន១៥នាក់ផ្សេងទៀតក្នុងចំណោមប្រជាជនទាំងចំនួន២០០នាក់ ដែលបានចូលរួមស្តាប់និងបានទៅមើលផ្ទាល់ពីការកាត់សេចក្តីទៅលើករណី ឌុច ។ គ្រប់ចម្លើយដែលបានផ្តល់ឲ្យ គឺថា ឌុច នៅតែជាមនុស្សដែលពុំមានភាពទទួលខុសត្រូវចំពោះទង្វើដែលខ្លួនបានធ្វើចំពោះប្រជាជនឃុំអមលាំង ។ អ្នកភូមិថ្នល់បំបែកម្នាក់ឈ្មោះ កង គួរ អាយុ៦៧ឆ្នាំ បានសម្តែងអាការៈខឹងសម្បានឹង ឌុច យ៉ាងខ្លាំង ។ គាត់ចង់ឲ្យ ឌុច ស្លាប់ភ្លាមៗ ដូចដែល ឌុច បានបញ្ជាឲ្យកងការពារមកចាប់ប្តីរបស់គាត់យកទៅសម្លាប់នៅក្នុងបរិវេណមន្ទីរសន្តិសុខ ម-១៣ អ៊ីចឹង ។ គួរ និយាយដូច្នេះថា

«ឌុច ឆ្លើយមិនទាន់អស់ពីអំពើយង់ឃ្នងរបស់ខ្លួនចំពោះប្រជាជន នៅក្នុងឃុំអមលាំងឡើយ ។ ខ្ញុំចង់វាយ ឌុច ដោយផ្ទាល់ដៃ» ។ ចំណែក កង សុខកាយ អាយុ៣២ឆ្នាំ ជាប្រជាជនរស់នៅភូមិទំនាប បានប្រាប់ពីអារម្មណ៍របស់ខ្លួនចំពោះ ឌុច ថាគាត់ពុំមានកំហឹងអ្វីបន្តិចជាមួយ ឌុច ឡើយ ព្រោះគាត់មិនមែនជាជនរងគ្រោះ ហើយគ្រួសាររបស់គាត់ក៏មិនដែលធ្លាប់ត្រូវ ឌុច និងកងការពារធ្វើបាបដែរ ។ នេះជាលើកទីមួយហើយដែល សុខកាយ បានស្គាល់មុខនិងបានស្តាប់សេចក្តីសារភាពរបស់ ឌុច ។ សុខកាយ ជឿជាក់លើអ្វីដែល ឌុច បាននិយាយថាជាការពិត ។ ក្នុងនាមជាអ្នកនាំផ្លូវប្រជាជនរស់នៅភូមិស្រុកផ្សេងទៅកាន់បរិវេណមន្ទីរសន្តិសុខ ម-១៣ ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ សុខកាយ បានប្រាប់ថា គាត់បានត្រឹមតែឃើញជាក់ស្តែងនូវរណ្តៅបីបួន ស្រះទឹក ស៊ីង និងម្ហូប ព្រមទាំងនំចំណីរបស់សាច់ញាតិខ្មោចដែលបានស្លាប់ក្រោមស្នាដៃរបស់ ឌុច ដាក់សែនព្រេនដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ទៅប៉ុណ្ណោះ ។ ប៉ុន្តែពេលនេះគាត់បានដឹងច្រើនជាងមុនព្រមទាំងបានស្គាល់មុខ ឌុច យ៉ាងច្បាស់ទៀតផង ។ ដែល ធឿន ជាអ្នកភូមិទំនាបបានប្រាប់ថា គាត់បានឃើញឆ្កែពាំពោះវៀនមនុស្សមកស៊ីនៅកៀនជញ្ជាំងខ្ទមរបស់គាត់ដោយផ្ទាល់ភ្នែកនាពេលព្រលឹមស្រាងៗក្នុងថ្ងៃមួយកាលពីអំឡុងឆ្នាំ១៩៧២ ។ ទាក់ទិនទៅនឹងរឿងនេះ ឌុច បានឆ្លើយបដិសេធចំពោះការបំភ្លឺរបស់ចាន់ វឿន ដែលថាគាត់ធ្លាប់បានឃើញឆ្កែពាំក្បាល ដៃឬជើងរបស់សាកសពមកស៊ីក្បែររោងបាយ ថាពុំមានរឿងបែបនេះកើតឡើងនៅមន្ទីរម-១៣ឡើយ ។ ឌុច ពន្យល់ដូច្នេះថា មន្ទីរ ម-១៣ ពុំដែលកប់សាកសពផ្តេសផ្តាសបណ្តាលឲ្យឆ្កែអូសខ្មោចស៊ីតាមចិត្តនោះទេ ។ ធឿន ជាក្មេងស្រីតូចម្នាក់រស់នៅជាមួយម្តាយឈ្មោះចន្ធា លើដីស្រែមួយកន្លែងជាប់នឹងបរិវេណមន្ទីរសន្តិសុខ ម-១៣ ប្រហែល២០០ម៉ែត្រ កាលពីឆ្នាំ១៩៧២ ។ ផន ភាព ជាជំនួយការភូមិម្នាក់បានត្អូញត្អែរថា «ឌុច គួរតែនិយាយឲ្យអស់ពីអ្វីដែលជាការពិតកាលពីគាត់នៅគ្រប់គ្រងអំណាច មិនគួរនៅលាក់លៀមរឿងរ៉ាវខ្លះៗទេ ទោះជាគាត់ទទួលទោសកំហុសទាំងអស់ក៏ដោយ» ។

ខាងក្រោមនេះគឺជាការដកស្រង់សម្តីផ្ទាល់របស់អ្នកភូមិទាំង១៧នាក់ ÷



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍អ្នកភូមិក្នុងឃុំអមលាំង

**១) ម៉ាក មឿន អាយុ៦៨ឆ្នាំ ជាប្រជាជនរស់នៅភូមិថ្មគប់ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំឃើញរូបភាពគាត់ (ឌុច) បេញមកនិយាយជាមួយតុលាការ ។ ខ្ញុំស្គាល់គាត់តាំងពីឆ្នាំ១៩៧១មកម្ល៉េះ ។ អារម្មណ៍របស់ខ្ញុំគឺថា ខ្ញុំសប្បាយចិត្តពេលដែលបានមកឃើញតុលាការជាលើកដំបូង ហើយបានឃើញមុខរបស់ ឌុច នៅពេលនេះទៀត ។ ម្យ៉ាងទៀត ខ្ញុំចង់ឲ្យតុលាការកាត់ទោសគាត់ឲ្យដាច់ស្រេចក្នុងពេលឆាប់ៗ ព្រោះគាត់បានធ្វើអំពើអាក្រក់ច្រើនណាស់មកលើប្រជាជន ។ ខ្ញុំអត់មានអារម្មណ៍អ្វីក្រៅពីចង់ឲ្យតុលាការកាត់ទោសគាត់ទេ ។ ខ្ញុំជឿជាក់លើតុលាការ ។ ខ្ញុំអស់កង្វល់អ្វីទៀតហើយពីរឿងរកយុត្តិធម៌ឲ្យអ្នកដែលបានស្លាប់ទៅក្រោមស្នាដៃរបស់ ឌុច» ។

**២) ស្រី ឈឿន អាយុ៤១ឆ្នាំ មេភូមិថ្មគប់ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំមានអារម្មណ៍សោយក្នុងខ្លួន ពេលដែលបានដឹងថាតុលាការនាំយក ឌុច ទៅកាត់ទោស ។ ប្រសិនបើមិនបាននាំយកគាត់ទៅកាត់ទោសទេ ខ្ញុំនៅតែមានអារម្មណ៍វិលវល់រហូត ។ ខ្ញុំសប្បាយចិត្តណាស់ដោយឃើញតុលាការសួរដេញដោល ឌុច ពីអំពើឧក្រិដ្ឋរបស់គាត់ ។ ខ្ញុំបានស្គាល់ ឌុច ម្តងទៀត ហើយចាំមុខគាត់ឡើងវិញ ។ អ្វីដែល ឌុច បាននិយាយមិនទាន់អស់សេចក្តីទេនៅចំពោះមុខតុលាការ ដោយនៅមានលាក់លៀមពីសកម្មភាពដែលគាត់



បានធ្វើខ្លះទៀត ដូចក្នុងករណីគាត់បានបដិសេធ វឿន នៅ (ភូមិ) កុមារមាសថាមិនមែនជាកងការពាររបស់មន្ទីរ ម-១៣ ។ តាមពិត វឿន ពិតជាកងការពារនៅមន្ទីរ ម-១៣មែន ។ ខ្ញុំបានជជែកជាមួយ ចាន់ វឿន ពីការបដិសេធថាគាត់មិនមែនជាកងការពារនៅមន្ទីរម-១៣ ។ ចាន់ វឿន ប្រាប់ថា គាត់ខឹង ឌុច ខ្លាំងណាស់ចំពោះការបដិសេធនេះ ហើយគាត់ចង់ស្ទុះទៅវាយ ឌុច នៅក្នុងតុលាការទៀតផង ។ ខ្ញុំមិនដឹងថានៅមន្ទីរ ម-១៣ មានមនុស្សស្លាប់ប៉ុន្មាននាក់ទេ ប៉ុន្តែបើតាមខ្ញុំស្តាប់ការជជែកគ្នាជាមួយចាស់ៗក្នុងភូមិ គឺមានចំនួនច្រើនជាង៣០០នាក់ ។ ខ្ញុំមានសំណូមពរថា សូមកុំឲ្យ ឌុច រួចខ្លួនឲ្យសោះ ឲ្យតុលាការធ្វើយ៉ាងណាកាត់ទោស ឌុច ឲ្យបានដើម្បីឲ្យអ្នកដែលស្លាប់ទៅទទួលបានភាពយុត្តិធម៌ផង» ។

**៣) យិន នាង អាយុ៤១ឆ្នាំ ជាប្រជាជនរស់នៅភូមិថ្មគប់ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំគិតថា តុលាការសព្វថ្ងៃនេះ ពិតជាអាចរកយុត្តិធម៌ជូនអ្នកដែលស្លាប់ទៅនៅមន្ទីរម-១៣បាន ព្រោះជាតុលាការមួយដែលត្រឹមត្រូវ ។ ខ្ញុំគិតថាអ្វីដែល ឌុច និយាយនៅមិនទាន់អស់សេចក្តីនៅឡើយទេ» ។

**៤) ពែន ផាត់ អាយុ៤១ឆ្នាំ ជាប្រជាជនរស់នៅភូមិថ្មគប់ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំមិនដែលស្គាល់ ឌុច ពីមុនមកទេ ទើបតែស្គាល់នៅពេលទៅមើលនៅតុលាការប៉ុណ្ណោះ ប៉ុន្តែខ្ញុំធ្លាប់បានឮឪពុកខ្ញុំនិយាយប្រាប់ថា ឌុច សាហាវណាស់ ។ ខ្ញុំយល់ឃើញថា តុលាការនេះពិតជាអាចរកយុត្តិធម៌ជូនអ្នកដែលស្លាប់ទៅបាន ។ ខ្ញុំចង់ឲ្យតុលាការបន្តកាត់ទោស ឌុច តទៅទៀត ព្រោះខ្ញុំគិតថា ការនិយាយរបស់គាត់នៅមានភូតភរច្រើន» ។

**៥) យ៉ា ហឿន អាយុ៥០ឆ្នាំ ជាប្រជាជនរស់នៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«នេះជាលើកទី១ហើយ ដែលខ្ញុំបានចូលមើលតុលាការកាត់ទោស ឌុច ។ ខ្ញុំធ្លាប់ស្គាល់ ឌុច តាំងពីខ្ញុំនៅតូចៗ ហើយមិនហ៊ានមើលមុខគាត់ផង ។ នៅពេលដែលខ្ញុំបានទៅដល់តុលាការ និងបានមើលមុខគាត់ម្តងទៀត ខ្ញុំរឹតតែនៅចាំមុខគាត់ ។ ខ្ញុំពុំមានចំណាប់អារម្មណ៍អ្វីទេ ប៉ុន្តែខ្ញុំសប្បាយពេលដែលខ្ញុំបានទៅឃើញគាត់ (ឌុច) កំពុងតែត្រូវបានតុលាការកាត់ទោស» ។

**៦) ផន ភាព អាយុ៤០ឆ្នាំ ជាជំនួយការភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំតក់ស្លុតពេលដែលឃើញមុខ ឌុច ។ ថ្វីត្បិតតែខ្ញុំមិនដែលឃើញនិងមិនដែលស្គាល់គាត់ពីមុនមក ប៉ុន្តែពេលដែលខ្ញុំឃើញមុខគាត់ ខ្ញុំខ្លាច ។ ខ្ញុំចង់ឲ្យមានការកាត់ទោសបន្តទៀត ។ បើសិនជា ឌុច រួចខ្លួន វាអយុត្តិធម៌ណាស់សម្រាប់អ្នកដែលបានស្លាប់ទៅ ។ ខ្ញុំជឿជាក់ថា ប្រជាជនដែលធ្លាប់មានសាច់ញាតិរបស់ខ្លួនស្លាប់ក្រោមស្នាដៃរបស់ ឌុច ពិតជាមានការឈឺចាប់ចំពោះអំពើឃោរឃៅរបស់ ឌុច ។ ខ្ញុំមិនដឹងថា ឌុច និយាយកុហក ឬអត់ទេ ប៉ុន្តែតាមរយៈការនិយាយតៗគ្នាពីសំណាក់អ្នកភូមិចាស់ៗ បានឲ្យដឹងថា ឌុច និយាយនៅមានកុហកច្រើន» ។ ខ្ញុំចង់ឲ្យ ឌុច និយាយការពិតទាំងអស់ចេញមក ដើម្បីឲ្យប្រជាជនទាំងអស់គ្នាអស់ចិត្ត» ។ ខ្ញុំយល់ឃើញថា ប្រសិនបើប្រជាជននៅក្នុងឃុំអមលាំងនេះសួរគាត់ (ឌុច) ម្នាក់មួយម៉ាត់ៗ គាត់ (ឌុច) ប្រាកដជាខ្យល់គរស្លាប់ ។ នៅពេលត្រឡប់មកពីមើលការកាត់ក្តីនេះវិញ ប្រជាជនច្រើននាក់ណាស់បានជជែកគ្នាថាតើហេតុអ្វីបានជាគេ (តុលាការ) មិនអនុញ្ញាតឲ្យពួកគាត់សួរសំណួរទៅកាន់ ឌុច ដោយផ្ទាល់ ជាពិសេសមនុស្សចាស់ៗដែលធ្លាប់ស្គាល់ ឌុច ច្បាស់កាលពីសម័យនោះ ។

**៧) កង សុខកាយ អាយុ៣២ឆ្នាំ ជាប្រជាជនរស់នៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំមិនដែលស្គាល់ ឌុច ទេ ទើបតែស្គាល់នៅពេលបានទៅមើលតុលាការថ្ងៃមុននេះ ។ ខ្ញុំមិនដែលបានដឹងរឿងរ៉ាវដែលកើតឡើងនៅមន្ទីរម-១៣ នេះកាលពីមុនមកទេ ប៉ុន្តែស្ទើរតែរាល់ឆ្នាំខ្ញុំជាអ្នកបើកបរគោយន្តជូនដំណើរបងប្អូនសាច់ញាតិរបស់ខ្មោចដែលបានស្លាប់នៅមន្ទីរ ម-១៣ ទៅធ្វើបុណ្យ ឬសែនម្ហូបអាហារ

នៅរដូវបុណ្យប្រពៃណីជាតិ ។ អ្នកទាំងនោះច្រើនមកពីស្រុកខេត្តកំពង់ស្ពឺ ។ ចំពោះការមកមើលដំណើរការសាលាក្តីនេះ ខ្ញុំហាក់ដូចជាមិនមានអ្វីប្លែកទេ ហើយក្នុងចិត្តខ្ញុំក៏ពុំមានកំហឹងចំពោះ ឌុច ដែរ ព្រោះខ្ញុំមិនបានឆ្លងកាត់នូវទង្វើដែលគាត់បានធ្វើ ។ សម្រាប់ខ្ញុំវាធម្មតា ទោះបីជាគាត់ (ឌុច) ធ្លាប់កាប់សម្លាប់ចំពោះគេមែន ប៉ុន្តែចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំទៅមើលតុលាការនេះគឺគ្រាន់តែស្តាប់ ចង់ដឹងសាច់រឿង និងចង់មើលមុខគាត់តែប៉ុណ្ណោះ ។ នៅទីនោះ ខ្ញុំឃើញមានរណ្តៅដែលប្រើប្រាស់ជាគុក មិនមែនរណ្តៅកប់មនុស្សទេ ។ ប៉ុន្តែអ្នកទោសដែលស្លាប់នៅក្នុងរណ្តៅទាំងនេះ គឺស្លាប់ដោយសារទឹកលិច ។ ខ្ញុំទៅមើលតុលាការនេះ គឺចង់ស្តាប់ប្រវត្តិរបស់គាត់ពិតថាតើគាត់ធ្វើអ្វីខ្លះ? និងថាតើគាត់សារភាពពីទោសកំហុសរបស់គាត់ដែរឬអត់?

**៨) មាស ម៉ន អាយុ៦០ឆ្នាំ ជាប្រជាជនរស់នៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំមិនមានអារម្មណ៍អ្វីទេ ស្រេចលើតុលាការជាអ្នកកាត់ក្តី ។ ប៉ុន្តែនៅពេលដែលខ្ញុំស្តាប់ត្រង់សួរចម្លើយអ្នកទោស ហើយមានការចាប់រំលោភអ្នកទោស ព្រមទាំងធ្វើទារុណកម្មបែបយកឈើទៅរុកទ្វារមាស ខ្ញុំឈឺចាប់ណាស់ ។ ក្រៅពីហ្នឹងទៅ ខ្ញុំមិនសូវឈឺចាប់ប៉ុន្មានទេ» ។

**៩) ហែម យី អាយុ៦០ឆ្នាំ ជាប្រជាជនរស់នៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំយល់ថា ឌុច សារភាពមិនទាន់អស់នៅឡើយទេ ប៉ុន្តែគាត់បានសារភាពច្រើនដែរហើយ ។ ប៉ុន្តែ ចាន់ វឿន ពិតជាកងការពារមន្ទីរ ម-១៣ មែន ។ ចាន់ ខន ក៏អ៊ីចឹងដែរ ។ ខ្ញុំមិនដឹងថាហេតុអ្វីបានជា ឌុច បដិសេធ ចាន់ វឿន ។ ខ្ញុំរស់នៅទីនេះតាំងពីមុនឆ្នាំ១៩៧១ម្ល៉េះ ហើយខ្ញុំបានឃើញ ឌុច តាំងពីមកដល់ដំបូង ។ ខ្ញុំធ្លាប់ចូលទៅកាន់មន្ទីររបស់ ឌុច ដោយផ្ទាល់ ពេលដែលខ្ញុំនាំអ្នកទោសចូលទៅទីនោះ ប៉ុន្តែខ្ញុំមិនបានចូលទៅជ្រៅក្នុងមន្ទីរទេ ។ ចំពោះអ្នកទោសដែលស្លាប់នៅទីនោះ ខ្ញុំមិនហ៊ានសន្និដ្ឋានទេ ប៉ុន្តែនៅពេលបែកខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានទៅដកដំឡូងដែលដាំជុំវិញមន្ទីរមកហូប ។ ប៉ុន្តែដំឡូងទាំងនោះ ហូបមិនកើតទេ ព្រោះស្អុយក្លិនខ្មោចជាប់នឹងដំឡូង ។ កុំស្មានថា ឌុច លើកដៃសំពះមករកយើងប៉ុណ្ណឹងថាអាចលើកលែងទោសបាន គឺអត់ទេ ។ ដូចអ្នកទោសលើកដៃសំពះគាត់ច្រើនជាងហ្នឹង គាត់មិនលែងគេផង ។ អត់ទោសមិនបានទេ» ។

**១០) ដែល ធឿន អាយុ៤១ឆ្នាំ ជាប្រជាជនរស់នៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំមានអារម្មណ៍សប្បាយផង ភ័យផង ពេលដែលខ្ញុំបានទៅមើលតុលាការ ។ ខ្ញុំមិនដែលបានស្គាល់ ឌុច ពីមុនមកទេ ប៉ុន្តែខ្ញុំធ្លាប់ដឹងថាមានអ្នកទោសជាច្រើនបានមកដល់មន្ទីរដែលស្ថិតនៅក្បែរស្រែម៉ែខ្ញុំ ។ ខ្ញុំក៏ធ្លាប់បានឃើញឆ្កែពាំពោះវៀនមនុស្សមកស៊ីក្បែរខ្ទមរបស់ខ្ញុំ នៅពេលព្រលឹមថ្ងៃមួយក្នុងឆ្នាំ១៩៧២ ។ ខ្ញុំក៏បានឃើញគេប្រមូលខោអាវអ្នកទោសមកដាក់លើទូលក្បែរខ្ទមរបស់ខ្ញុំ ពេលដែលទឹកជំនន់លិចមន្ទីរ ។ ខ្ញុំគិតថា ឌុច គួរតែកាត់ទោសបន្តទៀត» ។

**១១) ស ផុន អាយុ៥៣ឆ្នាំ ជាប្រជាជនរស់នៅភូមិថ្នល់បំបែក ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំមិនមានអារម្មណ៍អ្វីទេជាមួយ ឌុច ព្រោះខ្ញុំមិនដែលស្គាល់គាត់ ។ កាលនោះខ្ញុំធ្វើជាកងចល័តជាមួយ យាយមាស និងយាយម៉ែន ។ ខ្ញុំទើបតែស្គាល់ ឌុច នៅពេលដែលខ្ញុំទៅមើលតុលាការថ្ងៃមុននេះ» ។

**១២) កង គួរ អាយុ៦៧ឆ្នាំ ជាប្រជាជនរស់នៅភូមិថ្នល់បំបែក ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំមានការឈឺចាប់ណាស់ ពេលដែលបានឃើញមុខ ឌុច ម្តងទៀត ។ ខ្ញុំបាត់ប្តីដោយសារ ឌុច ហ្នឹង ។ អារម្មណ៍របស់ខ្ញុំពេលនេះ គឺចង់ឲ្យ ឌុច ឆាប់ស្លាប់ដូចប្តីខ្ញុំ ប្អូនខ្ញុំ មាខ្ញុំអ៊ីចឹង ។ ខ្ញុំមិនចង់ឲ្យ (ឌុច) នៅរស់ទៀតទេ ។ ខ្ញុំសប្បាយណាស់ ពេលដែលតុលាការចាប់ ឌុច មកកាត់ទោស ។ ខ្ញុំចង់វាយ ឌុច ដោយផ្ទាល់ដៃតែម្តងនៅក្នុងតុលាការហ្នឹង ។ ឌុច ឥឡូវនេះ ខុសពី ឌុច កាលពីពេលមុន ។ កាលមុន ឌុច ធាត់ និងធំជាងហ្នឹង ហើយទឹកមុខគាត់ក៏ខុសពីមុនដែរ ។ ខ្ញុំថា ឌុច ឆ្លើយមិនអស់សេចក្តីពីអ្វីដែលគាត់បានធ្វើពីពេលមុនទេ ព្រោះ ឌុច ជាមនុស្សដែលឃោរឃៅសម្បើមណាស់ ។ អ្នកភូមិទាំងអស់គ្នាក្នុងភូមិនេះចង់ឲ្យតុលាការកាត់ទោស ឌុច ឲ្យឆាប់រហ័សបំផុត ។ ខ្ញុំយល់ហើយថា ចៅក្រមនិយាយឲ្យ

ប្រជាជនយល់ច្បាស់និងពន្យល់ថាត្រូវធ្វើតាមច្បាប់ ប៉ុន្តែកំហឹងរបស់ប្រជាជនពិតជាមិនដូចចៅក្រមទេ ប្រជាជនមិនចង់ឲ្យតាមច្បាប់ទេ គឺចង់ឲ្យតែឆាប់ៗ» ។

**១៣) វ័ន្ត ខុន អាយុ៥៦ឆ្នាំ ជាប្រជាជនរស់នៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំឈឺចាប់ណាស់ចំពោះអំពើរបស់ ឌុច ថ្វីដ្បិតតែខ្ញុំមិនដែលស្គាល់ ឌុច ពីមុនមក ប៉ុន្តែបងប្អូនរបស់ខ្ញុំបីនាក់បានស្លាប់ក្នុងជំនាន់នោះ ។ ខ្ញុំយល់ថា ឌុច គួរតែត្រូវកាត់ទោសបន្តទៀត ព្រោះសម្ដីដែលគាត់និយាយចេញមកវាឃោរឃៅណាស់ទៅហើយ» ។

**១៤) កង គិត អាយុ៥៦ឆ្នាំ ជាប្រជាជនរស់នៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំចង់ទៅមើលការកាត់ទោសនេះម្ដងទៀត ដើម្បីឲ្យឃើញជាក់ស្ដែង ។ បានទៅមើលការកាត់ក្ដីនេះ ខ្ញុំត្រេកអរណាស់ ហើយខ្ញុំក៏ឈឺចាប់ណាស់ដែរនៅពេលរំឭករឿងនេះឡើងវិញ ព្រោះបងប្អូនខ្ញុំត្រូវគេវាយចោល ហើយកប់នៅស្រែខ្មោច ។ ឌុច មិនបានមកចាប់បងប្អូនខ្ញុំដោយផ្ទាល់ទេ ប៉ុន្តែគាត់បានប្រើឈ្លបឲ្យមកចាប់ទៅ ដោយចោទថាបងប្អូនខ្ញុំជាគិញសម្ងាត់ ។ ខ្ញុំយល់ថាអ្វីដែល ឌុច បានសារភាពនៅចំពោះមុខតុលាការ ពិតជាខុសពីអ្វីដែលគាត់បានអនុវត្តនៅក្នុងមន្ទីររបស់គាត់ ។ ឌុច ឆ្លើយសារភាពមិនទាន់អស់ទេ ព្រោះមានអ្នកទោសច្រើនណាស់បានស្លាប់ដោយសារទឹកជំនន់ ។ ប៉ុន្តែ ឌុច ថាអត់មានអ្នកស្លាប់ទេ ។ ឌុច ឆ្លើយរបៀបនេះប្រសិនជាគាត់នៅក្រៅតុលាការវិញ ប្រជាជនយើងនាំគ្នាវាយសម្លាប់ទៅហើយ ប៉ុន្តែគាត់នៅក្នុងតុលាការ គេមិនហ៊ានធ្វើអ្វីគាត់ទេ ។ ខ្ញុំចង់ឲ្យតុលាការកាត់ទោសប្រហារជីវិត ឌុច ឲ្យដូចខ្លួនបានធ្វើចំពោះប្រជាជនអ៊ីចឹង» ។

**១៥) ស៊ុំ សុខ អាយុ៤៨ឆ្នាំ ជាប្រជាជនរស់នៅភូមិតាកោង ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំមានអារម្មណ៍ខឹងនឹងមេដឹកនាំធំៗរបស់ខ្មែរក្រហម ប៉ុន្តែខ្ញុំពុំមានអារម្មណ៍ខឹងនឹង ឌុច ទេ ព្រោះខ្ញុំមិនដែលបាននៅជិតគាត់ ។ ខ្ញុំយល់ថា តុលាការនេះពិតជាមានភាពយុត្តិធម៌មែន ។ បើតាមខ្ញុំមើលទៅ ឌុច គឺមានលក្ខណៈស្លូតបូតគ្រាន់បើដែរ ប៉ុន្តែការពិតរបស់គាត់នៅខាងក្រៅប្រហែលជាកាចជាងនេះ ។ ខ្ញុំមិនដែលបានស្គាល់ ឌុច ពីមុនមកទេ គឺបានឮតែតាមពាក្យអ្នកភូមិនិយាយតៗគ្នាប៉ុណ្ណោះថាគាត់ជាមនុស្សសាហាវព្រៃផ្សៃ» ។

**១៦) ស៊ីវ សារិត អាយុ៤៣ឆ្នាំ ជាប្រជាជនរស់នៅភូមិតាកោង ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំមិនដែលស្គាល់មន្ទីរ ម-១៣ ទេ ។ មូលហេតុដែលខ្ញុំទៅមើលការកាត់ទោសនេះ គឺដោយសារចង់ដឹង ថាតើ ឌុច បានធ្វើអ្វីខុសខ្លះ ។ តាមពិតទៅ ខ្ញុំក៏មានកំហឹងឈឺចាប់ដែរចំពោះការសម្លាប់ប្រជាជនក្នុងរបប៣ឆ្នាំ ៨ខែ ២០ថ្ងៃ ។ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាអ្នកដឹកនាំជំនាន់នោះចូលចិត្តធ្វើអ្វីដែលខុសពីជំនាន់នេះ ។ នៅពេលដែលខ្ញុំបានឃើញមុខគាត់ (ឌុច) នៅក្នុងតុលាការ ខ្ញុំមានចិត្តខឹងដែរ គឺខឹងកាលពីជំនាន់បីឆ្នាំហ្នឹង ខ្ញុំឃើញគេចាប់ចង និងសម្លាប់មនុស្សដោយមិនមានហេតុផលច្បាស់លាស់ ។ ខ្ញុំមិនខឹងតែ ឌុច ម្នាក់ទេ គឺខឹងមេដឹកនាំទាំងអស់ ។ ខ្ញុំចង់ឲ្យតុលាការកាត់ក្ដីឲ្យយុត្តិធម៌បំផុត» ។

**១៧) ភួង ចាន់ហ៊ីម អាយុ៤៨ឆ្នាំ ជាអនុភូមិកុមាររមាស ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

«ខ្ញុំត្រេកអរណាស់ពេលដែលបានឃើញមុខ ឌុច នៅក្នុងតុលាការ ។ ក្នុងមួយជីវិតនេះ ខ្ញុំមិនដែលឃើញព្រឹត្តិការណ៍នេះពីមុនមកទេ ។ ខ្ញុំឈឺចាប់នៅពេលដែលរំឭករឿងនេះឡើងវិញ ។ ខ្ញុំធ្លាប់បានឃើញកងការពារនៅមន្ទីរម-១៣ ចូលមកចាប់អ្នកភូមិក្បែរផ្ទះខ្ញុំទាំងប្ដីប្រពន្ធទៅយកសម្លាប់កាលពីឆ្នាំ១៩៧២ ។ តា ឌុច គាត់បាននិយាយថា អ្នកទោសច្រើនចាប់យកពីភូមិទំនាប ភូមិថ្មគប់ និងភូមិត្រពាំងគ្រោប ។ ខ្ញុំអត់ជឿអ្វីដែលគាត់និយាយបែបនេះទេ ព្រោះមានអ្នកទោសច្រើនណាស់មកពីទិសខាងលិចដែលត្រូវបញ្ជូនចូលមន្ទីរម-១៣ ភាគច្រើន ។ ឌុច និយាយមិនពិតទេនៅក្នុងតុលាការ ដូចជាអ្នកទោសដែលស្លាប់ចំនួនត្រឹមតែ២០០-៣០០នាក់ ។ តាមពិតមានអ្នកទោសច្រើនណាស់ដែលស្លាប់ដោយសារទឹកលិច ។ ខ្ញុំមិនដឹងចំនួនអ្នកទោសស្លាប់មានចំនួនប៉ុន្មានឡើយ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាមានចំនួនច្រើនជាង៣០០នាក់ ។ ក្រៅពីអ៊ុំ ស៊ន ដែលជាសាក្សីក្នុងតុលាការនេះដែរ គឺគ្មាននរណាម្នាក់បានរួចរស់ជីវិតឡើយ» ។

**ផេង ពង្សរ៉ាស៊ី**

# ពិធីចែកសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" នេ







# ាវិទ្យាល័យហ៊ុនសែនអង្គស្នួល ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩





















# ការកាត់ទោស ឌុច និងប្រតិកម្មរបស់អ្នកភូមិ

សវនាការកាត់ទោស ឌុច បានចាប់ផ្តើមធ្វើនៅចុងខែមីនា ឆ្នាំ២០០៩ ហើយដំណើរការនៃការកាត់ក្តីបានបន្តអស់រយៈពេលជាងបីសប្តាហ៍មកហើយ ។ ឥឡូវនេះ តុលាការកំពុងតែពិនិត្យមើលសក្ខីកម្មនិងភស្តុតាងដែលទាក់ទងទៅនឹងមន្ទីរសន្តិសុខស-២១ របស់ខ្មែរក្រហម ដែលសព្វថ្ងៃត្រូវបានស្គាល់ជាទូទៅថាជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ បន្ទាប់ពីការពិភាក្សាអំពីអតីតគុកម-១៣ នៅឃុំអមលាំង ក្នុងខេត្តកំពង់ស្ពឺ តុលាការនឹងចាប់ផ្តើមធ្វើការពិនិត្យមើលទៅលើសក្ខីកម្មទាំងឡាយទាក់ទងទៅនឹងការបង្កើតមន្ទីរស-២១ និងអតីតមន្ទីរសន្តិសុខនៅតាខ្មៅ ។ ចៅក្រមដែលជាអធិបតីនៅក្នុងសាលាក្តីខ្មែរក្រហមព្យាយាមធ្វើឲ្យដំណើរការនេះមានលក្ខណៈងាយស្រួលសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការតាមដានដំណើរការនៃការកាត់សេចក្តី ដោយបានធ្វើការបែងចែកបញ្ហាទាំងឡាយយកមកពិភាក្សាជាផ្នែកៗ ។ ធ្វើដូច្នេះដំណើរការនៃការកាត់សេចក្តីនឹងប្រព្រឹត្តទៅដោយរលូននិងឆាប់រហ័ស ។

ដោយឈរនៅចំពោះមុខសាលាក្តី ឌុច បានពិភាក្សាអំពីការបង្កើតមន្ទីរស-២១ ។ ចៅក្រម សហព្រះរាជអាជ្ញា ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីខាងចុងចោទត្រូវបានអនុញ្ញាតឲ្យសួរសំណួរទៅ ឌុច ។ ឌុច បានប្រាប់សាធារណជនអំពីប្រវត្តិនៃការបង្កើតមន្ទីរស-២១ ។ គុកនេះគឺរើចេញមកពីគុកមួយនៅតាខ្មៅដែលពីដើមគឺជាមន្ទីរពេទ្យមួយ ។ ឌុច បាននិយាយថា គុកនេះដើមឡើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ណាត ហើយ ឌុច ជាអនុប្រធាន ។ ឌុច បានពន្យល់យ៉ាងលម្អិតអំពីរបៀបដែលគាត់និងក្រុមរបស់គាត់បានប្រែក្លាយអតីតសាលាទួលស្លែងមួយនេះទៅជាគុក ។ ក្នុងអំឡុងពេលនៃការកាត់សេចក្តី ឌុច បានផ្តល់សក្ខីកម្មថាតើអ្នកណាខ្លះជាអ្នកផ្តួចផ្តើមគំនិតក្នុងការបង្កើតមន្ទីរស-២១ អ្នកណាខ្លះរួមចំណែកក្នុងការដឹកនាំមន្ទីរនេះ អ្នកណាខ្លះត្រូវបានជ្រើសរើសយកមកធ្វើការនៅក្នុងមន្ទីរស-២១និងវិធីសាស្ត្រធ្វើទារុណកម្មអ្វីខ្លះត្រូវបានយកមកប្រើប្រាស់នៅក្នុងមន្ទីរនេះ ។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ដំណើរការនៃការកាត់សេចក្តីបានឈានទៅដល់ដំណាក់កាលមួយដែលសហព្រះរាជអាជ្ញានិងមេធាវីតំណាងឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់អាចឆ្លាស់គ្នាចោទសួរសំណួរទៅ ឌុច បាន ។ ឆ្លើយតបទៅនឹងសំណួរទាំងឡាយ ឌុច បានរំឭកអំពីរយៈកាលដែលគាត់ និង ណាត ធ្វើការរៀបចំមន្ទីរស-២១ ។ អ្នកទាំងពីរទទួលគំនិតយោបល់ពីថ្នាក់លើរបស់ខ្លួនក្នុងការជ្រើសរើសមនុស្សសម្រាប់ចាប់ខ្លួន ការបង្កើតបទបញ្ញត្តិសម្រាប់ប្រើប្រាស់នៅក្នុងគុកនិងការបង្កើតវិធីសាស្ត្រក្នុងការសួរចម្លើយនិងធ្វើទារុណកម្មអ្នកទោស ។ រឿងរ៉ាវដែល ឌុច បានឆ្លើយបំភ្លឺនៅក្នុងតុលាការមានសារសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេសសម្រាប់អ្នកទាំងឡាយណាដែលជាជនរងគ្រោះនៃរបបខ្មែរក្រហម ។ ទោះបីជាពាក្យទាំងឡាយរបស់ ឌុច មិនមែនជាការពិតក៏ដោយ ក៏ប្រជាជនកម្ពុជាទទួលបានឱកាសមួយក្នុងការសិក្សាអំពីរយៈកាលនៃរបបខ្មែរក្រហមដែរ ។

ដើម្បីអនុញ្ញាតឲ្យអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមមានឱកាសក្នុងការវាយតម្លៃដំណើរការនៃការកាត់សេចក្តីនិងមានឱកាសក្នុងការវិនិច្ឆ័យចម្លើយសារភាពរបស់ ឌុច ដោយផ្ទាល់ខ្លួន មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញអ្នកភូមិចំនួនមួយរយនាក់ពីឃុំពោធិ៍បាន ក្នុងស្រុកកោះធំដើម្បីចូលរួមស្តាប់ការកាត់សេចក្តី ។ ណាត ដែលជាប្រធានកងវរសេនាធំ៧០៣ គឺជាប្រធានគុកនៅតាខ្មៅនិងអតីតមន្ទីរសន្តិសុខស-២១ ។ អ្នកដែលនៅរស់រានមានជីវិតភាគច្រើនពីស្រុកកោះធំធ្លាប់ព្រួតិ ឈ្មោះ ណាត ហើយអ្នកខ្លះទៀតស្គាល់ ណាត ផ្ទាល់ថែមទៀតផង ។ ទោះជាយ៉ាងនេះក្តី ភាគច្រើននៃអ្នកទាំងនេះមិនដែលស្គាល់ ឌុច ទេ ។

មានតែអ្នកដែលធ្លាប់ជាបុគ្គលិកនៅមន្ទីរស-២១ប៉ុណ្ណោះដែលស្គាល់ ឌុច ។ ដោយសារតែប្រជាជនភាគច្រើនពីស្រុកកោះធំចង់ចាំ ណាត ហើយមួយចំនួនគឺជាអតីតបុគ្គលិកបម្រើការនៅមន្ទីរស-២១នោះ អ្នកភូមិនៅស្រុកកោះធំបានក្លាយទៅជាក្រុមគោលដៅមួយដែលយើងជ្រើសរើសឲ្យមកចូលរួមស្តាប់ការកាត់សេចក្តី ។ ទោះបីជាភាគច្រើននៃអ្នកភូមិទាំងនេះមិនដែលស្គាល់ ឌុច ក្តី ក៏ការចូលរួមសង្កេតដំណើរការនៃការកាត់សេចក្តីអាចជាវិធីដ៏ល្អមួយក្នុងការជួយពួកគាត់សិក្សាស្វែងយល់អំពី ឌុច ។ យោងទៅតាមការសង្កេតរបស់អ្នកភូមិ ចម្លើយសារភាពរបស់ ឌុច រួមមានការនិយាយពិតខ្លះនិងមិនពិតខ្លះ ។ មួយចំនួននៃអ្នកទាំងនេះដែលបានផ្តល់បទសម្ភាសន៍បានឲ្យយោបល់ថា ឌុច កំពុងតែព្យាយាមលាក់បាំងនូវការពិតមួយចំនួន ហើយបង្វែរការស្តីបន្ទោសទៅលើ ណាត ដែលជាប្រធានរបស់គាត់នៅពេលនោះ ។ លោក ជឹម វ៉ាង អ្នកភូមិមកពីភូមិព្រៃកគារ័ត្ន បានផ្តល់យោបល់ថា ឌុច កំពុងតែព្យាយាមការពារខ្លួនឯង ហើយដាក់ការទទួលខុសត្រូវទៅលើ ណាត ដែលបានស្លាប់បាត់ទៅហើយ ។

បន្ទាប់មកទៀត ឌុច បានឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងសំណេរដោយដៃរបស់គាត់នៅលើឯកសាររបស់អ្នកទោស ។ ឌុច បានឆ្លើយប្រាប់ទៅសហព្រះរាជអាជ្ញាថា ណាត គឺជាអ្នកផ្តល់គំនិតចម្បងនេះ ហើយគាត់ប្រើប្រាស់គំនិតនេះក្នុងការសរសេរចំណារនៅលើចម្លើយសារភាពរបស់អ្នកទោស ។ អ្នកភូមិម្នាក់អាយុ៥៥ឆ្នាំបានប្រាប់ក្រុមរបស់គាត់ថា ឌុច គឺជាមនុស្សដែលមិនអាចទុកចិត្តបាន ។ ជ្រឹប ស្រើម និយាយថា «ខ្ញុំមិនជឿនូវអ្វីៗទាំងអស់ដែលគាត់បាននិយាយទេ ។ រាល់ការពិតទាំងឡាយនឹងធ្វើឲ្យគាត់ទៅជាមនុស្សអាក្រក់ ហើយគាត់ជិតទាស់ទៅនឹងការពិតទាំងនោះ» ។

ផ្នែកមួយទៀតនៃសក្ខីកម្មរបស់ ឌុច បានបង្ហាញថា ការសម្រេចចិត្តថាតើវិធីសាស្ត្រធ្វើទារុណកម្មមួយណាគួរយកមកប្រើប្រាស់ទៅលើអ្នកទោសគឺជាការសម្រេចចិត្តរបស់ ឌុច ផ្ទាល់ ។ ទោះជាយ៉ាងនេះក្តី ឌុច មិនមែនធ្វើការសម្រេចចិត្តតែឯងនោះទេ ។ គាត់បានពិភាក្សានិងសម្រេចជ្រើសរើសយកវិធីសាស្ត្រធ្វើទារុណកម្មជាមួយ ណាត ។ គាត់បានពន្យល់អំពីវិធីសាស្ត្រពីរយ៉ាងដែលប្រើប្រាស់សម្រាប់សួរចម្លើយនិងធ្វើទារុណកម្មអ្នកទោសដោយប្រើប្រាស់ដំបងឈើវាយអ្នកទោសនិងឆក់ខ្សែភ្លើង ។ គាត់ក៏បានសារភាពផងដែរថា ថង់ប្លាស្ទិកត្រូវបានយកមកប្រើដើម្បីធ្វើទារុណកម្មអ្នកទោសម្តងម្កាលនៅក្នុងរយៈកាលដំបូងនៃប្រតិបត្តិការនៅក្នុងគុក ។ ទោះជាយ៉ាងនេះក្តី ឌុច បានបដិសេធយ៉ាងតឹងតែងចំពោះការចោទប្រកាន់ដែលថា គាត់បានបញ្ជាឲ្យចងអ្នកទោសព្យួរជើងឡើងលើដាំក្បាលចុះក្រោមហើយជ្រមុជទៅក្នុងទឹក ។ គាត់បានបដិសេធចំពោះការចោទប្រកាន់នេះ ហើយបាននិយាយថា វិធីសាស្ត្រធ្វើទារុណកម្មរបៀបនេះមិនមានប្រើប្រាស់នៅមន្ទីរស-២១នោះទេ ។

លោក ឡាច ម៉ៅ អាយុ៥៥ឆ្នាំ មិនជឿទាំងស្រុងចំពោះអ្វីដែល ឌុច បាននិយាយអំពីវិធីសាស្ត្រសួរចម្លើយនៅមន្ទីរស-២១ទេ ។ គាត់និយាយថា វិធីសាស្ត្រទាំងនោះដូចជាស្រាលពេកសម្រាប់មន្ទីរសន្តិសុខសម្ងាត់ខ្ពស់មួយដូចជាមន្ទីរស-២១នេះជាដើម ។ ម៉ៅ គឺជាកងទ័ពខ្មែរក្រហមម្នាក់ដែលក្រោយមកត្រូវបានចាប់ខ្លួនបញ្ជូនទៅគុកមួយនៅជ្រៃញ៉ោ ។ គាត់បានពណ៌នាអំពីរបៀបដែលខ្មែរក្រហមធ្វើទារុណកម្មគាត់ ។ ពួកគេបានដកក្រចកដៃ ហើយដាក់ខ្នោះជើងគាត់ ។ គាត់និយាយថា «បើការអះអាងរបស់ ឌុច គឺជាការពិត នោះជាវិធីសាស្ត្រធ្វើទារុណកម្មនៅមន្ទីរសន្តិសុខថ្នាក់មូលដ្ឋានដូចជាគុកជ្រៃហូញ៉ោនេះមានលក្ខណៈសាហាវជាង ដែលរឿងនេះមិនអាចទៅរួចទេ» ។ ចាយ រ៉ុ ដែលមកពីឃុំជាមួយគ្នាក៏ជឿដែរថា ឌុច មិនបានបង្ហាញពីការពិតទាំងអស់អំពីការធ្វើទារុណកម្មអ្នកទោសទេ ។ រ៉ុ ត្រូវបានចាប់ខ្លួននិងធ្វើទារុណកម្មនៅក្នុងគុកកោះកន្ធាយអស់រយៈពេលប្រហែលមួយខែ ។ ក្បាលរបស់ រ៉ុ ត្រូវគ្របនឹងថង់ប្លាស្ទិករយៈពេលពីរបីនាទី រហូតដល់គាត់សន្លប់បាត់ស្មារតី ។ រ៉ុ ខឹងយ៉ាងខ្លាំងនៅពេលគាត់ ឃើញ ឌុច ជាលើកទីមួយ ។ រ៉ុ និយាយដោយកំហឹងថា «ប្រសិនបើខ្ញុំមានឱកាសជួប ឌុច ដោយផ្ទាល់ ខ្ញុំនឹងសួរគាត់ថាតើអង្គការយកអង្ករ ហើយនិងផលិតផលកសិកម្មដទៃទៀតទៅណា ។ ខ្ញុំចង់ដឹងថាហេតុអ្វីបានជាពួកគេទុកឲ្យប្រជាជនអត់ឃ្លាន ហើយហេតុអ្វីបានជាពួកគេចាប់មនុស្សដាក់គុក ដោយគ្រាន់តែលួចអង្ករដើម្បីបំពេញក្រពះប៉ុណ្ណោះ» ។ ផ្ទុយទៅនឹងការអះអាងរបស់ ឌុច ដែលថាមិនមាន

ការធ្វើទារុណកម្មដូចជាការដកក្រចកដៃនៅមន្ទីរស-២១ អ្នកភូមិអាយុ៤៨ឆ្នាំម្នាក់អះអាងថា ភាសារបស់ ឌុច គឺជាការភូតកុហក ។ បើតាមសម្តីរបស់គាត់ ទុយ គិន ដែលបានចូលរួមស្តាប់ការកាត់សេចក្តីនៅក្នុងថ្ងៃជាមួយគ្នាដែរនោះ គឺធ្លាប់ធ្វើការនៅក្នុងកងសួរចម្លើយ ហើយជាអ្នកទទួលខុសត្រូវក្នុងការដកក្រចកដៃអ្នកទោសក្នុងពេលសួរចម្លើយ ។

ស្ទើរតែគ្មានអ្នកណាម្នាក់នៅក្នុងក្រុមមួយដែលមានអ្នកភូមិចំនួន១៣នាក់ ហើយដែលទទួលការសម្ភាសន៍បានដឹងថា ណាត គឺជាប្រធានមន្ទីរស-២១មួយរយៈ ហើយភាគច្រើនមានការភ្ញាក់ផ្អើលនៅពេលបានដឹងអំពីរឿងនេះ ។ កែវ ហេង មកពីឃុំពោធិ៍បានមានការភ្ញាក់ផ្អើលពេលឮ ឌុច និយាយពីឈ្មោះ ណាត ក្នុងពេលស្តាប់ការកាត់សេចក្តី ។ ហេង មិនជឿថា ណាត ដែលគាត់ធ្លាប់ស្គាល់គឺជាមនុស្សតែមួយដែល ឌុច បាននិយាយ ។ ហេង បានរំឭកឡើងវិញថា គាត់ស្គាល់ ណាត តាមរយៈបងប្រុសរបស់គាត់ដែលធ្វើការនៅក្នុងកងពលតែមួយដែល ណាត ជាប្រធាន ។ វាក៏ជាលើកទីមួយដែរ ដែល ស៊ិន ចាយ បានដឹងថា ណាត ត្រូវបានផ្លាស់ឲ្យមកធ្វើការនៅមន្ទីរស-២១ ។ ចាយ ស្គាល់ ណាត ជាយូរមកហើយ នៅពេលដែលគាត់នៅជាសមាជិកម្នាក់នៅក្នុងកងពល៧០៣ ។ គាត់បានរំឭកអំពីពេលវេលាដែលគាត់បានឃើញ ណាត នៅឯម្តុំស្ពានជ្រោយចង្វារ គឺភ្លាមៗបន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ ។

ជាទូទៅ អ្នកដែលផ្តល់បទសម្ភាសន៍ទាំងអស់បានបង្ហាញពីការពេញចិត្តចំពោះកិច្ចការរបស់តុលាការ ហើយមានការសប្បាយចិត្តដែលបានឃើញការកាត់ក្តីអតីតប្រធានគុកម្នាក់កំពុងតែដំណើរការទៅមុខ ។ ទោះជាយ៉ាងនេះក្តី មួយចំនួនមានការមិនពេញចិត្តចំពោះចម្លើយសារភាពរបស់ ឌុច ដែលតាមការសង្កេតរបស់ពួកគាត់ ចម្លើយសារភាពនោះមានការពិតខ្លះ តែមិនមែនទាំងស្រុងទេ ។ យោងតាមការសង្កេតរបស់អ្នកផ្តល់បទសម្ភាសន៍មួយចំនួន ឌុច មិនបានទទួលយកឧក្រិដ្ឋកម្មទាំងអស់ដែលគាត់បានប្រព្រឹត្តនៅមន្ទីរស-២១ឡើយ ។ ផ្ទុយទៅវិញ គាត់បានព្យាយាមកាត់បន្ថយទម្ងន់ ហើយដាក់ការទទួលខុសត្រូវទៅលើថ្នាក់លើរបស់គាត់ ។

ដើម្បីយល់ដឹងឲ្យបានគ្រប់ជ្រុងជ្រោយអំពីគំនិតរបស់អ្នកភូមិអំពី ឌុច និងដំណើរការនៃការកាត់សេចក្តីនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ខាងក្រោមនេះគឺជាសេចក្តីដកស្រង់មួយចំនួនពីអ្នកផ្តល់បទសម្ភាសន៍ចំនួន១២នាក់ដែលបានចូលរួមស្តាប់ការកាត់សេចក្តី ។

## ១) ព្រេច ស្រឹម ភេទប្រុស អាយុ៥៥ឆ្នាំ

ខ្ញុំមិនធ្លាប់ស្គាល់ ឌុច ទេមុនពេលខ្ញុំមកតាមដានសវនាការ ។ ខ្ញុំយល់ឃើញថា សម្តីរបស់គាត់មិនគួរឲ្យទុកចិត្តបានឡើយ ។ គាត់ធ្លាប់គ្រប់គ្រងពន្ធនាគារ ហេតុអ្វីបានជាគាត់មិនដឹងអ្វីសោះ? បើតាមទស្សនះរបស់ខ្ញុំ គាត់ត្រូវតែផ្តន្ទាទោស ។ ប្រសិនបើមិនអ៊ីចឹងទេ ក្មេងជំនាន់ក្រោយនឹងយកគំរូតាមនៅពេលអនាគត ។ ខ្ញុំមានសេចក្តីរីករាយដែលបានមកទស្សនាសវនាការដោយផ្ទាល់ ។ ខ្ញុំគិតថា សវនាការនេះជួយឲ្យប្រជាជនកម្ពុជាមានអារម្មណ៍ធូរស្បើយពីការឈឺចាប់ ។ ខ្ញុំនៅតែចង់មកតាមដានដំណើរការនេះ ហើយចង់ឃើញថា ឌុច នឹងនិយាយអ្វីនៅក្នុងសវនាការបន្ទាប់មកទៀត ។

## ២) ចឹម វ៉ាង ភេទប្រុស អាយុ២៩ឆ្នាំ

ខ្ញុំបានឮឈ្មោះ ឌុច ប៉ុន្តែមិនដែលឃើញគាត់ដូចដែលខ្ញុំបានឃើញកាលពីម្សិលមិញឡើយ ។ ខ្ញុំគិតថា ឌុច នៅតែព្យាយាមបិទបាំងការពិត ។ អ្វីដែលខ្ញុំចាប់អារម្មណ៍ខ្លាំងបំផុតគឺគាត់បដិសេធឆ្លើយទៅនឹងសំណួររបស់មេធាវី ។ ដោយសារគាត់ក្លាហានក្នុងការបដិសេធឆ្លើយទៅនឹងសំណួរនោះហើយ ខ្ញុំសន្និដ្ឋានថា គាត់គឺជាបុរសខ្លាំងម្នាក់ដែលមិនខ្លាចក្នុងការប្រឈមមុខនឹងសវនាការ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនជឿគាត់ដែរនៅពេលដែលគាត់បាននិយាយថា គាត់ដឹងការពិតតែមួយចំនួនប៉ុណ្ណោះ ។

## ៣) កែវ ហេង ភេទស្រី អាយុ៥៣ឆ្នាំ

តាមរយៈសវនាការ ខ្ញុំដឹងថា ឌុច ជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំខ្មែរក្រហមជាច្រើនទៀត ។ ខ្ញុំបានស្គាល់ ណាត ជាយូរមកហើយ ប៉ុន្តែខ្ញុំមិនដែលឮឈ្មោះ ឌុច ទេ ។ ខ្ញុំមិនចាប់អារម្មណ៍នឹងសម្តី របស់ ឌុច ឡើយ ។ ការសើចរបស់គាត់ហាក់ដូចជាធ្វើឲ្យអារម្មណ៍របស់ប្រជាជនឈឺចាប់ ។ ខ្ញុំឆ្ងល់ណាស់ពេលខ្លះហេតុអ្វីបានជាគាត់មិនឆ្លើយនឹងសំណួររបស់មេធាវី ។ ខ្ញុំមានសេចក្តីរំភើបនៅពេលបានមកទស្សនាសាលសវនាការនិងតាម

ដានដំណើរការសវនាការ ។ ខ្ញុំគិតថា សវនាការនេះអាចធ្វើជាគំរូដល់ក្មេងជំនាន់ក្រោយ ហើយទប់ស្កាត់ការរំលោភសិទ្ធិមនុស្សនៅពេលអនាគត ។

### ៤) ជឿន ឡេង ភេទស្រី អាយុ៥២ឆ្នាំ

ខ្ញុំគិតថា វាជារឿងត្រឹមត្រូវដែលត្រូវកាត់ទោសមេដឹកនាំខ្មែរក្រហម ។ សវនាការបានផ្តល់ឲ្យខ្ញុំនូវគន្លឹះខ្លះថាតើ ឌុច ជាមនុស្សយ៉ាងម៉េច ។ ខ្ញុំភ្ញាក់ផ្អើលដោយបានឃើញឥរិយាបថរបស់ ឌុច នៅក្នុងបន្ទប់សវនាការ ។ ឌុច ហ៊ានស្តីបន្ទោសមេធាវី (ដើមបណ្តឹងរដ្ឋប្បវេណី) ដោយផ្ទាល់ ។ នេះចង្អុលបង្ហាញថា គាត់មិនខ្លាចសវនាការឡើយ ។ ខ្ញុំពេញចិត្តមេធាវី (ដើមបណ្តឹងរដ្ឋប្បវេណី) ដែលបានសួរ ឌុច នូវសំណួរផ្ទាល់ដែលធ្វើឲ្យមានការលំបាកក្នុងការបដិសេធមិនឆ្លើយតប ។

### ៥) ឡេង សៀង ភេទស្រី អាយុ៥០ឆ្នាំ

ខ្ញុំចង់ឮ ឌុច ទទួលបានការកាត់ទោស ពីព្រោះខ្ញុំឈឺចាប់ខ្លាំងណាស់ក្នុងអំឡុងរបបខ្មែរក្រហម ។ ខ្ញុំចង់ឃើញថាតើ ឌុច មានមុខមាត់យ៉ាងម៉េច ។ ខ្ញុំបានប្រាប់កូនៗរបស់ខ្ញុំថាតើមានការលំបាកបែបណាក្នុងការរស់នៅក្រោមរបបខ្មែរក្រហម ។ ប៉ុន្តែវាមានរយៈកាល៣០ឆ្នាំមកហើយ ។ នៅពេលខ្ញុំដឹងថាមានសាលាក្តីខ្មែរក្រហម វាជួយបន្ធូរបន្ថយការឈឺចាប់របស់ខ្ញុំ ។

### ៦) សឹម ភេទប្រុស អាយុ៦៦ឆ្នាំ

គោលបំណងរបស់ខ្ញុំតែមួយគត់ចំពោះការធ្វើដំណើរនេះគឺចង់ឃើញថាជនត្រូវចោទមានមុខមាត់យ៉ាងម៉េច ។ ខ្ញុំចង់បានចម្លើយមួយពីសវនាការថាហេតុអ្វីបានជាខ្មែរក្រហមបញ្ជាឲ្យមានការសម្លាប់ប្រជាជនស្លូតត្រង់ ។ ខ្ញុំបាត់បង់សមាជិកគ្រួសារទាំងអស់ក្នុងរបបខ្មែរក្រហម ។ ខ្ញុំត្រូវតស៊ូរស់នៅតែម្នាក់ឯង ។ ខ្ញុំមិនជឿពាក្យសម្តីរបស់ ឌុច ១០០ភាគរយឡើយ ពីព្រោះគាត់មិនបានទទួលស្គាល់ការពិតមួយចំនួនដែលភ្ជាប់គាត់ទៅនឹងការសម្លាប់ដោយផ្ទាល់ ។ ប៉ុន្តែខ្ញុំជឿថា ជនរងគ្រោះនឹងធូរស្បើយខ្លះនៅពេលឃើញ ឌុច និយាយនៅក្នុងសវនាការ ។ចុងក្រោយនេះ ខ្ញុំរីករាយណាស់ដែលបានឮ ឌុច លាតត្រដាងការពិតក្នុងសវនាការ ។

### ៧) ឡាច ម៉ៅ ភេទប្រុស អាយុ៥៥ឆ្នាំ

ខ្ញុំធ្លាប់ជាទាហានខ្មែរក្រហមម្នាក់នៅក្រោមបញ្ជារបស់ ហ៊ូ នឹម និង ហ៊ូ យន់ ។ ខ្ញុំចង់ឃើញសវនាការ ហើយស្តាប់នូវអ្វីដែល ឌុច បាននិយាយ ។ ខ្ញុំត្រូវបានចាប់ឃុំឃាំងនិងធ្វើទារុណកម្មនៅក្នុងពន្ធនាគារខ្មែរក្រហម ។ ទាហានជាច្រើននាក់ផ្សេងទៀតត្រូវបានចាប់ខ្លួននិងបញ្ជូនទៅពន្ធនាគារ ។ ខ្ញុំមិនជឿ ឌុច នៅពេលគាត់និយាយថាមានវិធីធ្វើទារុណកម្មអ្នកទោសតែ២-៣វិធីប៉ុណ្ណោះ ។ នៅក្នុងគុក ខ្លួនខ្ញុំផ្ទាល់ត្រូវបានធ្វើទារុណកម្មដោយដកក្រចកដៃ ។ ខ្ញុំមិនពេញចិត្តនឹងចម្លើយសារភាពរបស់ ឌុច ទេ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ខ្ញុំសង្ឃឹមថា វានឹងបន្ធូរបន្ថយអារម្មណ៍ឈឺចាប់របស់ប្រជាជន ។ ខ្ញុំបានស្គាល់ ណាត ។ គាត់គឺជាមេបញ្ជាការកងពលលេខ១១និង១២ ។ បន្ទាប់ពីសង្គ្រាម (ឆ្នាំ១៩៧៥) ខ្ញុំបានឮថាគាត់ត្រូវបានតែងតាំងជាអ្នកការទូតប្រចាំប្រទេសអូស្ត្រាលី ។ ប៉ុន្តែមិនដែលទទួលដំណឹងពីគាត់ម្តងទៀតឡើយ ចាប់តាំងពីពេលនោះមក ។

### ៨) ហម ណេង ភេទប្រុស អាយុ៥៨ឆ្នាំ

ខ្ញុំចាប់អារម្មណ៍ទៅលើសវនាការ ។ វាជាលើកដំបូងរបស់ខ្ញុំដែលបានមកទស្សនាបន្ទប់សវនាការនិងសាលកាត់សេចក្តី ។ ខ្ញុំមិនដែលឃើញ ឌុច ពីមុនមកទេ ។ ខ្ញុំគ្រាន់តែដឹងថា គាត់គឺជាប្រធានគុកទួលស្លែងនៅពេលខ្ញុំបានចូលស្តាប់សវនាការ ។ ទោះបីយ៉ាងនេះក៏ដោយ ខ្ញុំមិនជឿសម្តីរបស់ ឌុច ទាំងស្រុងឡើយ ។ ខ្ញុំជឿថា សវនាការនេះនឹងនាំយុត្តិធម៌ជូនជនរងគ្រោះដូចដែលខ្ញុំអាចឃើញផ្ទាល់ភ្នែក ។ ខ្ញុំក៏សង្ឃឹមផងដែរថា តុលាការនេះនឹងកាត់បន្ថយកំហឹងរបស់ជនរងគ្រោះ ។

### ៩) ឆាយ រី ភេទប្រុស អាយុ៤៦ឆ្នាំ

ខ្ញុំយល់បានផ្នែកខ្លះនៃសវនាការប៉ុណ្ណោះ ។ ខ្ញុំពេញចិត្តនៅពេលឃើញ ឌុច ទទួលបានការកាត់សេចក្តី ។ ខ្ញុំដឹងថា យើងមិនអាចនាំយកជីវិតរបស់ជនរងគ្រោះដែលបានស្លាប់ទៅហើយមកវិញបានទេ ប៉ុន្តែយើងអាចព្យាយាមឲ្យអស់ពីសមត្ថភាពដើម្បីទប់ស្កាត់ជំនាន់របស់យើងកុំឲ្យប្រព្រឹត្តខុសទៀត ។ ខ្ញុំត្រូវបានឃុំឃាំងក្នុងពន្ធនាគារក្នុងរបបខ្មែរក្រហម ដោយសារខ្ញុំឃ្លានខ្លាំងពេក ហើយបានលួចអង្ករពីអង្គការហូប ។ ខ្ញុំជាប់ក្នុងពន្ធនាគារជាមួយអ្នកទោសចំនួន២០-៣០នាក់ផ្សេងទៀត ។ យើងទាំងអស់គ្នាត្រូវបានដាក់ខ្នោះជើងជាមួយនឹងរនុកដែក ។ ជួនកាល ជើង

របស់យើងត្រូវរបួសដោយសារពួកគេសិករនុកដែកចូលក្នុងខ្នោះជើងដោយគ្មានប្រាប់យើងជាមុន ។

### ១០) គីម សាញ ភេទប្រុស អាយុ៦៨ឆ្នាំ

ជាលើកដំបូងបំផុតរបស់ខ្ញុំដែលបានមកទស្សនាសវនាការ ខ្ញុំយកចិត្តទុកដាក់ទៅលើអ្វីដែលចៅក្រម សហព្រះរាជអាជ្ញា និងមេធាវីបាននិយាយនិងសួរ ឌុច អំពីមន្ទីរស-២១ ។ ខ្ញុំមិនបានដឹងថា ឌុច ជាអ្នកនរណាទេពីមុនមក ។ ទើបតែនៅឯសាលសវនាការ ខ្ញុំបានឮ ឌុច ឆ្លើយសារភាពចំពោះអំពើឃោរឃៅដែលគាត់បានប្រព្រឹត្តក្នុងអំឡុងពេលកាន់អំណាចនៅមន្ទីរស-២១ ។ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជា ឌុច យល់ស្របជាមួយអង្គការដោយប្រព្រឹត្តអំពើសាហាវចំពោះអ្នកទោសបែបនេះ ។ ខ្ញុំសង្កេតឃើញ ថា ឌុច ជាមនុស្សវៃឆ្លាតមិនគួរណាក្លាយជាឃាតករសោះ ។ នៅពេលខ្ញុំបានឮចម្លើយសារភាពរបស់ ឌុច ខ្ញុំអាចបន្ធូរបន្ថយកំហឹងរបស់ខ្ញុំ ។ ខ្ញុំសង្ឃឹមថា សាលាក្តីអាចស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ ខ្ញុំក៏ចង់ឲ្យសាលាក្តីធ្វើការងារឲ្យបានលឿនជាងនេះ ។

### ១១) ស៊ិន ឆាយ ភេទប្រុស អាយុ៥៩ឆ្នាំ

ខ្ញុំមិនបានដឹងថា ឌុច ជាអ្នកណាឡើយមុនពេលមកចូលរួមសាលាក្តីខ្មែរក្រហម ប៉ុន្តែខ្ញុំធ្លាប់ឮឈ្មោះរបស់គាត់ក្នុងរបបខ្មែរក្រហម ខណៈពេលដែលខ្ញុំធ្វើជាទ័ពនៅក្នុងកងពលលេខ៧០៣ ។ ខ្ញុំចង់ឃើញសាលាក្តីខ្មែរក្រហមពីព្រោះខ្ញុំចង់ឃើញមុខរបស់ ឌុច និងស្តាប់នូវអ្វីដែលគាត់ឆ្លើយសារភាពក្នុងអំឡុងពេលសវនាការ ។ ខ្ញុំសម្គាល់ឃើញថា ឌុច គឺជាមនុស្សក្អេងក្អាង ប៉ុន្តែគាត់គួរតែទទួលខុសត្រូវចំពោះអ្វីដែលគាត់បានធ្វើក្នុងអំឡុងពេលធ្វើការនៅមន្ទីរស-២១ ។ ណាត គឺជាមេបញ្ជាការកងពលរបស់ខ្ញុំ ។ ខ្ញុំបានស្គាល់និងជួបគាត់នៅស្ពានជ្រោយចង្វារបន្ទាប់ពីជ័យជម្នះ (របស់ខ្មែរក្រហម) នៅខែមេសា ឆ្នាំ១៩៧៥ ។ ខ្ញុំមិនបានដឹងថាគាត់ត្រូវបានផ្ទេរឲ្យកាន់ការងារជាប្រធានមន្ទីរស-២១នៅឆ្នាំ១៩៧៥ទេ ។ នេះជាលើកទី១ហើយដែលខ្ញុំបានឮដូច្នេះនៅពេលខ្ញុំតាមដានសវនាការនៅថ្ងៃទី២៩ ខែមេសា ។ ខ្ញុំពិតជាចង់ឃើញសវនាការលើសពី១ដង ។ ខ្ញុំនៅតែខឹងចំពោះរបបខ្មែរក្រហម ។ ទោះបីជាដំណើរការរបស់អង្គជំនុំជម្រះកំពុងប្រព្រឹត្តទៅក៏ដោយ ក៏ខ្ញុំនៅតែខឹងមេដឹកនាំខ្មែរក្រហម ។ ខ្ញុំចង់ឲ្យអង្គជំនុំជម្រះធ្វើការឲ្យខ្លាំងជាងនេះដើម្បីប្រមែប្រមូលភស្តុតាងនិងសាក្សីក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសនិងដាក់ទោសទណ្ឌ ។ សមាជិកគ្រួសាររបស់ខ្ញុំស្ទើរតែទាំងអស់ត្រូវបានសម្លាប់ដោយកម្មាភិបាលថ្នាក់ក្រោមនៅតាមឃុំ ប៉ុន្តែខ្ញុំមិនខឹងពួកគេទេ ដោយសារខ្ញុំដឹងថាពួកគេទទួលបញ្ជាពីកម្មាភិបាលខ្មែរក្រហមថ្នាក់ខ្ពស់ ។ នៅចុងបញ្ចប់ ខ្ញុំជឿថា អង្គជំនុំជម្រះអាចស្វែងរកយុត្តិធម៌ជូនជនរងគ្រោះទាំងអស់ដែលទទួលរងការឈឺចាប់ពីរបបខ្មែរក្រហម ។

### ១២) ឡុច លាង ភេទប្រុស អាយុ៤៨ឆ្នាំ

នៅពេលបានស្តាប់អង្គជំនុំជម្រះពេញមួយថ្ងៃ ខ្ញុំសង្កេតឃើញថា ចម្លើយសារភាពរបស់ ឌុច មួយចំនួនពិត ហើយមួយចំនួនទៀតមិនពិត ។ ការពិតគឺជនរងគ្រោះមិនត្រូវបានដោះលែងឡើយ នៅពេលដែលពួកគេបញ្ជូនទៅមន្ទីរស-២១ ដែលជាការបង្កើតរបស់មជ្ឈិមបក្សនិងគោលបំណងរបស់មន្ទីរនេះ និងប្រភេទ៤នៃការធ្វើទារុណកម្ម៤យ៉ាង ។ រឿងដែលមិនពិតគឺ ឌុច បដិសេធថាមិនមានវិធីសាស្ត្រធ្វើទារុណកម្មដោយដកក្រចកដៃ ។ ទុយ គិន គឺជាអតីតកម្មាភិបាលដែលទទួលខុសត្រូវក្នុងការដកក្រចកដៃរបស់ជនរងគ្រោះនៅក្នុងអង្គភាពសួរចម្លើយនៅមន្ទីរស-២១ ។ គិន ក៏បានស្ថិតនៅក្នុងសាលសវនាការនៅថ្ងៃទី២៩ ខែមេសាជាមួយអ្នកភូមិជាច្រើនទៀតដែរ ។

**ស៊ុំ សាទីណា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# ទិវាចងកំហឹងនិងការចាប់ផ្តើមបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

«ទិវាចងកំហឹង» ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំនៅថ្ងៃទី២០ ខែឧសភា ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហមកាលពីឆ្នាំ១៩៧៩មកម្ល៉េះ ។ ជាទូទៅ គេឃើញមានមនុស្សរាប់រយនាក់ ដែលរួមមានទាំងប្រជាពលរដ្ឋ កូនសិស្ស និងព្រះសង្ឃបាននាំគ្នាចូលរួមប្រារព្ធទិវានេះយ៉ាងកុះករ ។ សម្រាប់ឆ្នាំនេះ «ទិវាចងកំហឹង» ក៏ត្រូវបានគេរៀបចំប្រារព្ធឡើងមិនខុសពីឆ្នាំមុនៗប៉ុន្មានឡើយ ។ ប៉ុន្តែសម្រាប់ឆ្នាំនេះ ព្រឹត្តិការណ៍សំខាន់ៗចំនួនពីរបានកើតឡើងនៅទន្ទឹមនឹងពេលប្រារព្ធពិធីនេះ ។ ទី១) នៅពេលនេះ តុលាការខ្មែរក្រហមបុអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានឈានដល់ដំណាក់កាលសំខាន់មួយនៅក្នុងការបញ្ចប់និទ្ទណ្ឌភាពនៃរបបខ្មែរក្រហម ពោលគឺការកាត់ទោស ឌុច ជាអតីតមេគុកទួលស្លែង ដែលបានធ្វើទារុណកម្ម និងសម្លាប់ពលរដ្ឋកម្ពុជាអស់យ៉ាងហោចណាស់ក៏១ម៉ឺន៤ពាន់នាក់ដែរ ។ ទីពីរគឺការចាប់ផ្តើមពង្រីង និងអភិវឌ្ឍន៍ឲ្យកាន់តែប្រសើរជាងមុននូវការបង្រៀនប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យនៅតាមសាលាវិទ្យាល័យ និងអនុវិទ្យាល័យចំនួន១៣២១នៅទូទាំងប្រទេសកម្ពុជា ។

នៅឆ្នាំនេះ យើងឃើញមានមនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់រហូតដល់ទៅរាប់ពាន់នាក់នៅក្នុងសម្លៀកបំពាក់កាន់ទុក្ខបានចូលរួមប្រារព្ធពិធីនេះ ដែលរួមមានភាគច្រើនជាមន្ត្រីរាជការបុគ្គលិកតាមបណ្តាក្រសួងមន្ទីរ ប្រជាពលរដ្ឋ និស្សិត និងព្រះសង្ឃនៅឯបរិវេណវាលពិឃាតជើងឯក ។ នៅជុំវិញបូជនីយដ្ឋានដែលផ្ទុកទៅដោយគ្រោងឆ្អឹងជនរងគ្រោះ ប្រជាពលរដ្ឋបានដាក់កម្រងផ្កា និងអុជធូបគោរព និងរំឭកដល់វិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហម ។ ប្រជាពលរដ្ឋខ្លះបានបង្ហូរទឹកភ្នែកនឹកឃើញដល់បទពិសោធន៍ជូរចត់របស់ខ្លួននិងក្រុមគ្រួសារដែលបានជួបប្រទះនៅពេលនោះ ។ ដើម្បីរំឭកដល់ការចងចាំ គេឃើញមានការសម្តែងរបស់សិស្សសាលាវិចិត្រសិល្បៈក្នុងសម្លៀកបំពាក់ខ្មៅកំពុងធ្វើបាបនិងសម្លាប់ប្រជាជនដូចកាលពីជំនាន់ខ្មែរក្រហមអ៊ីចឹង ។

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩នេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡាបានចាប់ផ្តើមនូវគម្រោងចែកចាយសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)» ចំនួនប្រមាណ២៥ម៉ឺនក្បាលរបស់ខ្លួន ទៅឲ្យសិស្សថ្នាក់ទី៩ ១០ ១១ និង១២ នៅទូទាំងប្រទេសកម្ពុជា ។ ជាការចាប់ផ្តើម មជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំបានចែកចាយសៀវភៅចំនួន២៥០០ក្បាលទៅឲ្យអនុវិទ្យាល័យ និងវិទ្យាល័យចំនួន១៣សាលានៅក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល ។ ពិធីនេះត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩ នៅក្នុងវិទ្យាល័យហ៊ុនសែនអង្គស្នួល ក្រោមអធិបតីភាពរបស់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ លោកគ្រីនថ៍ វិល្លៀម សុន ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការខក្រិដ្ឋកម្មសង្គ្រាម និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។



ការសម្តែងដើម្បីរំឭកឡើងវិញនូវការធ្វើបាប និងកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហម

ជាកិច្ចចាប់ផ្តើមបើកពិធីចែកចាយសៀវភៅនេះ លោកជំទាវ ទន់ សាអ៊ីម បានមានប្រសាសន៍ថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា

ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ចងក្រង សរសេរសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះឡើង បន្ថែមទៅលើអ្វីដែលមានស្រាប់នៅក្នុងកម្មវិធីសិក្សាផ្នែកប្រវត្តិសាស្ត្រនេះ ។ ចំណែក លោកគ្លីនថ៍ វិល្លៀមសុន បានជំរុញឲ្យសិស្សានុសិស្សទាំងអស់ខិតខំយកចិត្តទុកដាក់ ស្វែងយល់ និងចងចាំប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមនេះ ព្រោះវាមានសារសំខាន់ណាស់ក្នុងការការពារកុំឲ្យមានការសម្លាប់រង្គាលបែបនេះកើតឡើងនៅលើទឹកដីកម្ពុជាម្តងទៀត ។ លោកឆាំង យុ ក៏បានលើកទឹកចិត្តដល់សិស្សានុសិស្សឲ្យព្យាយាមរៀនសូត្រ ព្រោះវាមានសារសំខាន់ដល់ការកសាងប្រទេសនៅពេលអនាគត និងបានជំរុញឲ្យសិស្សានុសិស្សទាំងអស់ធ្វើទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជាដោយផ្ទាល់ ប្រសិនបើមានបំណងចង់ស្វែងយល់ឲ្យបានកាន់តែជ្រៅជ្រះបន្ថែមទៀត ។

ការចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងទិវាចងកំហឹងនេះ គឺជាការចែកចាយលើកដំបូងជាផ្លូវការ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជានឹងបន្តចែកចាយសៀវភៅនេះទៅឲ្យសិស្សានុសិស្សនៅទូទាំងប្រទេស ។ នៅក្នុងកិច្ចការចែកចាយសៀវភៅប្រវត្តិសាស្ត្រនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើឡើងជាពីរដំណាក់កាល ហើយយើងកំពុងតែបំពេញការងារនៅក្នុងដំណាក់កាលទីមួយ ពោលគឺចែកចាយសៀវភៅចំនួន២៥ម៉ឺនក្បាលនៅទូទាំងប្រទេស ។ នៅក្នុងដំណាក់កាលទីពីរ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំមានគម្រោងនឹងចែកចាយសៀវភៅប្រវត្តិសាស្ត្រនេះចំនួន២៥ម៉ឺនក្បាលបន្ថែមទៀត ។

នៅក្នុងកិច្ចការអប់រំអំពីអំពើប្រល័យពូជសាសន៍នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលនូវការគាំទ្រ និងសហការយ៉ាងជិតស្និទ្ធពីក្រសួងអប់រំ យុវជន និងកីឡា ។ ក្រៅពីការបោះពុម្ព និងចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់នូវការកសាងសមត្ថភាពដល់គ្រូបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រ សីលធម៌-ពលរដ្ឋវិជ្ជា និងអក្សរសាស្ត្រ ចំនួនបីពាន់នាក់នៅទូទាំងប្រទេសកម្ពុជាអំពីវិធីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសរសេរបញ្ចប់រួចរាល់ហើយនូវសៀវភៅណែនាំគ្រូបង្រៀនអំពីរបៀបនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ ។ ការបង្រៀនលើកទីមួយនឹងចាប់ផ្តើមធ្វើនៅក្នុងខែមិថុនា ឆ្នាំ២០០៩ ខាងមុខនេះ ។ បន្ទាប់ពីសកម្មភាពទាំងនេះ ការបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងចាប់ផ្តើមឡើងជាផ្លូវការនៅទូទាំងប្រទេស ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានមោទនភាពយ៉ាងខ្លាំងនៅក្នុងការងារបំពេញកិច្ចការដ៏ធំធេងនេះជាមួយរាជរដ្ឋាភិបាលកម្ពុជា និងជាពិសេសជាមួយក្រសួងអប់រំ យុវជន និង កីឡា ។ **ឌី ខេមរិទ្ធិ**



ប្រជាជនទស្សនាជើងឯក ថ្ងៃទី២០ ឧសភា ២០០៩



លោក ជំទាវ ទន់ សាអ៊ីម ចែកសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ជូនសិស្សានុសិស្ស

# ការអត់ឱនទោសៈ តើការអត់ឱនអាចទៅរួចដែរឬទេ ហើយតើអាចបង្រៀនឱ្យចេះអត់ឱនបានដែរឬទេ?

*...ការអត់ឱនទោសគឺជារឿងទាក់ទងនឹងគំនិត អាចធ្វើបាន អាស្រ័យទៅលើវប្បធម៌ និងស្ថានភាពបុគ្គលម្នាក់ៗ ។ ដូច្នេះវាជារឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះម្នាក់ៗ...*

## ១) សេចក្តីផ្តើម

ចំណាប់អារម្មណ៍ទៅលើការអត់ឱនទោសដែលខ្ញុំមានមិនមែនកើតចេញមកពីបទពិសោធន៍ដែលបញ្ជាក់អំពីសមត្ថភាពរបស់ខ្ញុំក្នុងការលើកលែងទោសបាននោះទេ ប៉ុន្តែដោយសារខ្ញុំមានកំណើតមកពីប្រទេសកម្ពុជានេះឯងដែលអាចធ្វើឲ្យខ្ញុំធ្វើការអត់ឱនទោសឲ្យបាន ។ ប្រទេសខ្ញុំបានឆ្លងកាត់នូវសង្គ្រាមរ៉ាំរ៉ៃអស់ជាច្រើនទសវត្សរ៍ និងទទួលរងនូវឧក្រិដ្ឋកម្មខ្លោចផ្សាជាទីបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ឬហៅថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ។ ដោយសារតែជនរងគ្រោះមានចំនួនយ៉ាងច្រើន ហើយជនដៃដល់ក៏មានចំនួនច្រើនបន្តួរដែរ ការធ្វើការអត់ឱនទោសគឺជាក្តីបារម្ភមួយរបស់សង្គមកម្ពុជាទាំងមូល ប្រសិនបើកម្ពុជាចង់អនុវត្តការងារនេះ ។

ការអត់ឱនទោសគឺជាកិច្ចការមួយដែលពិបាកនិងសម្រេចបានណាស់ ។ ប្រជាជនកម្ពុជាទូទៅពិភាក្សាពីបញ្ហានេះទាំងលក្ខណៈស្រពេចស្រពិល ។ ពេលខ្លះ ការអត់ឱនទោសហាក់បីដូចជាផ្លូវមួយដ៏ត្រង់ ដែលមើលទៅដូចជាមានលក្ខណៈងាយស្រួលនឹងយល់ ហើយនិងអាចធ្វើការទស្សន៍ទាយបាន ។ ក្រោយមក មនុស្សចាប់ផ្តើមនិយាយអំពីការលើកទោសដល់ជនកំណាចមួយចំនួនដូចជាពេជ្ឈឃាតរបស់ពួកណាហ្ស៊ី ដូចដែលបានបកស្រាយនៅក្នុងសៀវភៅរបស់អ្នករួចរស់មានជីវិតពីរបបណាហ្ស៊ីម្នាក់ឈ្មោះ សាយម៉ុន វ៉ាយសិនថល ដែលមានចំណងជើងថា ផ្កាឈូករ័ត្ន ។ មនុស្សគ្រប់គ្នាក៏ចាប់ផ្តើមអត់ឱនទោសដល់ក្រុមជនផ្តាច់ការរបស់ប្រទេសអាហ្សង់ទីន កម្មាភិបាលខ្មែរក្រហម មន្ត្រីរបបអាប៉ារថេត របស់ប្រទេសអាហ្វ្រិកខាងត្បូង អ្នកដែលពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍របស់ប្រទេសរ៉្វាន់ដា ពេជ្ឈឃាតនិងឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់និងដឹងច្បាស់ថាបានប្រព្រឹត្តបទឧក្រិដ្ឋ ដោយមានគោលបំណងច្បាស់លាស់និងមានលក្ខណៈជាប្រពន្ធ័ ។ វីរជនដ៏ឆ្នើមមួយចំនួនដែលដែលបានធ្វើការលើកលែងទោសមានដូចជាលោក អាប៊ីសប ដេមិន ទូទូ ដែលមានជំនឿថាមានតែការអត់ឱនទោសមួយប៉ុណ្ណោះ ទើបអាចស្តាបនាប្រទេសអាហ្វ្រិកខាងត្បូងបាន ។ បុគ្គលម្នាក់ទៀតគឺសម្តេច ប៉ាប ចនប៉ូល ទីពីរ ដែលបានធ្វើការអត់ឱនទោសដល់បុរសម្នាក់ឈ្មោះ ម៉េម៉េត អាលី អាកា បន្ទាប់ពីបុរសនោះព្យាយាមធ្វើឃាតរូបគាត់ ។ យេស៊ូគ្រិស្តគឺមនុស្សម្នាក់ទៀតដែលនិយាយពីការអត់ឱនទោសជាទូទៅតាមស្ថានភាពជាច្រើន រួមទាំងបុគ្គលជាច្រើនទៀត ។ ការអត់ឱនទោសគឺជារឿងមួយដែលពិបាកនឹងយល់ ហើយក៏មានការច្របូកច្របល់ផងដែរ ។

នៅក្នុងអត្ថបទនេះ ខ្ញុំនឹងធ្វើការឆ្លើយទៅនឹងសំណួរថា «តើអាចបង្រៀនឲ្យមានការអត់ឱនទោសបានដែរឬទេ?» ប្រសិនបើមានការងាយស្រួលក្នុងការលើកលែងទោស ដូច្នេះការអត់ឱនទោសក៏ត្រូវតែអាចបង្រៀនឲ្យធ្វើបានដែរ ។ ទីមួយ ខ្ញុំពិចារណាទៅលើភាពដែលអាចធ្វើទៅបានក្នុងការលើកលែងទោសតាមរយៈការស៊ើបអង្កេតករណីមួយចំនួនដែលមនុស្សគ្រប់រូបអាចនឹងធ្វើការលើកលែងទោសបាន ហើយខ្ញុំនឹងផ្តោតលើការលើកលែងទោសតាមបែបសាសនា ។ ទីពីរ ខ្ញុំនឹងអង្កេតមើលថាតើការលើកលែងទោសអាចធ្វើទៅបានដោយវិធីណា ហើយខ្ញុំនឹងសម្លឹងរកមើលដែនកំណត់និងគុណភាពនៃការអប់រំពីការលើកលែងទោស និងការផ្តល់ប្រឹក្សា ។

## ២) តើអាចបង្រៀនមនុស្សឲ្យចេះអត់ឱនទោសបានដែរឬទេ?

ជាទូទៅ ការអត់ឱនទោសមានសារសំខាន់ខ្លាំងណាស់

ចំពោះសុខុមាលភាព ជីវិត និងសង្គមរបស់មនុស្សម្នាក់ៗ ហើយក៏មានសារសំខាន់សម្រាប់ជនដែលជនរងគ្រោះផងដែរ ។ ការអត់ឱនទោសដល់មនុស្ស គឺធ្វើឲ្យមនុស្សមានមានសេរីភាពនិងភាពរីករាយឡើងវិញជាថ្មីម្តងទៀត ។ ទោះជាមានលក្ខណៈដូច្នេះក៏ដោយ ក៏ការអត់ឱនទោសគឺជាមុខវិជ្ជាដែលទើបតែលេចឡើងថ្មីក្នុងវិស័យចិត្តវិទ្យា ដែលចាប់ផ្តើមឡើងក្នុងដើមទសវត្សរ៍៨០ ។ ចាប់ពីសតវត្សរ៍៥ ដល់ឆ្នាំ១៩៧០ អ៊ិនរ៉ាយ បានរកឃើញឯកសារដែលបានសរសេរឡើងមានចំនួនតែ១១០ទំព័រប៉ុណ្ណោះ ដែលរៀបរាប់អំពីការអត់ឱនទោសរវាងបុគ្គលនិងបុគ្គល ។ បើគិតមើលទៅក្នុងរយៈរៀងរាល់១០ទៅ១៥ឆ្នាំម្តង ការលើកលែងទោសមានតែម្តងប៉ុណ្ណោះ ។

## ២.១) និយមន័យនៃការអត់ឱនទោស

ដោយសារតែការអត់ឱនទោសគឺជាមុខវិជ្ជាថ្មីមួយនៅក្នុងមជ្ឈដ្ឋានសិក្សា និយមន័យនៃការអត់ឱនទោសហាក់បីដូចជាមិនមានពាក្យណាច្បាស់លាស់ជាផ្លូវការទេ ។ និយមន័យមានសារសំខាន់ណាស់ ព្រោះវានឹងផ្តល់នូវក្របខ័ណ្ឌមួយដែលអនុញ្ញាតឲ្យអ្នកស្រាវជ្រាវមានលទ្ធភាពក្នុងការសិក្សាបន្ថែម និងពិនិត្យមើលភាពច្បាស់លាស់នៃប្រធានបទ ។

វចនានុក្រមអេនសាយក្លូផេឌៀ អុកហ្វើដ បានឲ្យនិយមន័យទៅលើពាក្យការអត់ឱនថា «ជាសកម្មភាពនៃការបញ្ឈប់អារម្មណ៍ដែលពោរពេញដោយកំហឹងនិងការតូចចិត្តចំពោះនរណាម្នាក់» ។ ជាមួយគ្នានោះដែរ វចនានុក្រមឡុងមែនក៏បានឲ្យអត្ថន័យស្រដៀងគ្នានោះដែរដោយបានលើកឡើងថា «សកម្មភាពនៃការជម្រះចោលនូវអារម្មណ៍តូចចិត្ត និងមហិច្ឆតាក្នុងការសងសឹកដោយខ្លួនឯងដោយការធ្វើទុកបុកម្នេញ» ។

លោក ម៉ៃឃើល ហេនដើសាន់ បានឲ្យនិយមន័យទៅលើពាក្យការអត់ឱនថា «ជាការលះបង់ចោលនូវសិទ្ធិដើម្បីឲ្យមានភាពស្មើគ្នា» ។ លោក អាបឺសប ដេមិន ទូទូ ដែលជាជនដ៏មានកេរ្តិ៍ឈ្មោះមួយរូបអំពីការលើកលែងទោសរបស់គាត់បានឲ្យនិយមន័យអំពីកាអត់ឱនទោសថា «ជាការទទួលយកនូវហេតុការណ៍អាក្រក់ដែលបានកើតមានឡើង នៅពេលដែលនរណាម្នាក់មិនត្រូវទទួលបាននូវភាពយុត្តិធម៌...ដែលជាការបើកផ្លូវដល់មនុស្សផ្សេងទៀតក្នុងការធ្វើការងារស្រដៀងនឹងយើងដែរ» ។ ម៉ាកឃូ ឡាហ្និងសហការីរបស់គាត់បានស្នើក្នុងការកំណត់និយមន័យនៃពាក្យការអត់ឱនទោសថា «ជាការផ្លាស់ប្តូរនៅក្នុងគំនិតរបស់បុគ្គលនិងសង្គមចំពោះអ្នកដែលបានប្រព្រឹត្តខុសសីលធម៌សង្គមដែលបានដក់ជាប់នៅក្នុងចិត្តរបស់បុគ្គលជាក់លាក់ណាមួយ» ។

និយមន័យនៅក្នុងវចនានុក្រមហាក់បីដូចជាផ្តោតទៅលើការជម្រះចោលនូវការអាក់អន់ចិត្ត ហើយលះបង់ចោលនូវបំណងក្នុងការសងសឹក ចំណែកលោក ហេនដើសាន់ វិញបានឲ្យនិយមន័យស្រដៀងគ្នានេះដែរដោយប្រើពាក្យត្រង់ៗសំដៅទៅលើការសងសឹក ។ លោក ដេមិន ទូទូ វិញបានផ្តោតទៅលើការទទួលយកនូវការឈឺចាប់ និងការផ្តល់នូវសមានចិត្តចំពោះជនល្មើស ។

អ៊ិនរ៉ាយ និងសហការីរបស់គាត់បានពិពណ៌នាថាការអត់ឱនទោសគឺជា «ឆន្ទៈក្នុងការជម្រះចោលនូវការការអាក់អន់ចិត្ត អារម្មណ៍អវិជ្ជមាន និងអត្តចរិតខុសពីប្រក្រតីដែលមាននៅក្នុងបុគ្គលណាម្នាក់ ហើយទង្វើទាំងអស់នេះបានផ្តល់ចំពោះនរណាមួយដែលធ្លាប់បានធ្វើទុក្ខបុកម្នេញមកលើយើង ដោយបង្កើននូវសមានចិត្តសប្បុរសធម៌ និងក្តីស្រឡាញ់ចំពោះបុគ្គលនោះ» ។ និយមន័យនេះហាក់បីដូចជាគ្របលើនិយមន័យទាំងអស់ស្តីអំពីការអត់ឱនទោសដែលផ្តល់ដោយអ្នកផ្សេងទៀត ។ ខ្ញុំបានលើកយកនិយមន័យនេះមកពិភាក្សាអំពីការអត់ឱនទោសនេះ ។

## ២.២) តើការអត់ឱនតែងតែអាចធ្វើទៅបានដែរឬ?

ករណីដែលថាការអត់ឱនទោសអាចធ្វើទៅរួចគឺជាសំណួរមួយដែលត្រូវសួរថាតើមនុស្សម្នាក់ត្រូវបានបង្រៀនឲ្យចេះធ្វើការអត់ឱនទោសវិធីណាក្នុងលក្ខណៈវិជ្ជមានមួយ ។ បើសិនជាមានវិធីកាន់តែច្រើន មនុស្សម្នាក់នោះទំនងជាអាចនឹងអត់ឱនទោសកាន់តែច្រើនផងដែរ ហើយប្រសិនបើតែងតែអាចធ្វើការអត់ឱនទោសឲ្យបាននោះ យើងអាចនិយាយបានថា មនុស្សគ្រប់រូបសុទ្ធតែអាចបង្រៀនឲ្យចេះអត់ឱនទោសជានិច្ច ទោះបីជាអ្នកទាំងនោះទទួលរងនូវភាពឈឺចាប់ពីសំណាក់ជនដៃដល់កម្រិតណាក៏ដោយ ។

ចាំបាច់ត្រូវធ្វើការបញ្ជាក់ឲ្យច្បាស់ថា «មានតែជនរងគ្រោះទេដែលអាចអត់ឱនទោសបាន» មុននឹងចាប់ផ្តើមដំណើរការសិក្សានេះ ។

### ក) មានតែជនរងគ្រោះទេដែលអាចអត់ឱនទោសបាន?

អ្នកនិពន្ធមួយចំនួនដែលបានចែករំលែកអត្ថបទរបស់ខ្លួន នៅក្នុងសៀវភៅផ្កាឈូករ័ត្ន ដែលជំរុញឲ្យមានការពិភាក្សាអំពីបញ្ហានៃការអត់ឱនទោសដល់ពួកណាហ្ស៊ី ។ អ្នកនិពន្ធទាំងនោះមានជំនឿថា មានតែជនរងគ្រោះក្រោមការធ្វើទុក្ខបុកម្នេញរបស់ខក្រិដ្ឋជនម្នាក់ឈ្មោះ ខាល ប៉ុណ្ណោះទើបអត់ឱនទោសដល់គាត់បាន ។ នេះមានន័យថា ជនរងគ្រោះរបស់ ខាល មិនអាចអត់ឱនទោសដល់ឧក្រិដ្ឋជនម្នាក់ទៀតដូចជា វ៉ាយសិនថល ជាដើមបានទេ ។ ម្យ៉ាងវិញទៀតមានតែជនរងគ្រោះដែលទទួលរងនូវភាពឈឺចាប់ខាងផ្លូវកាយ និងផ្លូវចិត្តប៉ុណ្ណោះទើបអាចអត់ឱនទោសដល់ជនដៃដល់បាន នេះមានន័យថា ការអត់ឱនទោសមិនអាចឲ្យមនុស្សម្នាក់ទៀតធ្វើជំនួសយើងបានទេ គឺទាមទារឲ្យយើងត្រូវធ្វើខ្លួនឯង ។ បើតាមការអះអាងនេះ ក្នុងករណីឧក្រិដ្ឋកម្មសម្លាប់ ការអត់ឱនទោសដូចជាមិនអាចធ្វើទៅបានឡើយ ។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ចាំបាច់ត្រូវកត់សម្គាល់ថា ឃាតកម្មមួយមិនត្រឹមតែសម្លាប់ជនរងគ្រោះតែម្នាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ការបាត់បង់សុភមង្គលរបស់អ្នកដែលនៅរស់រានមានជីវិតផងដែរ ។ សាច់ញាតិដែលនៅរស់របស់ជនរងគ្រោះអាចនឹងនិយាយអំពីការអត់ឱនទោសជាមួយជនដៃដល់ជំនួសជនរងគ្រោះដែលបានស្លាប់បាត់ទៅហើយ ។ ជនរងគ្រោះគឺជាបុគ្គលម្នាក់ ជាសមាជិកគ្រួសារម្នាក់ ហើយជាសមាជិកនៅក្នុងសហគមន៍មួយអាចមានការអត់ឱនទោសចំនួនបីកម្រិតផ្សេងពីគ្នា ។ ទី១) ការអត់ឱនទោសពីសំណាក់ជនរងគ្រោះផ្ទាល់ ទី២) ពីសំណាក់សាច់ញាតិជាទីស្រឡាញ់របស់ជនរងគោះ និងទី៣) ពីសំណាក់សហគមន៍ដែលជនរងគ្រោះរស់នៅមុននឹងទទួលរងនូវការធ្វើទុក្ខបុកម្នេញ ។ ហើយករណីនេះក៏អាចធ្វើបានដូចគ្នាដែរ ប្រសិនបើជនរងគ្រោះទទួលការព្យាបាទ តែបានរស់រានមានជីវិត ។ ប៉ុន្តែក៏មិនអាចធានាបានទេថាបុគ្គលដែលស្លាប់ទៅហើយពិតជាមិនអាចអត់ឱនទោសបាននោះ ។ ប្រសិនបើករណីជនរងគ្រោះមានវ័យក្មេងពេកដូចជា ទារក ឬក៏កុមារ ឬក៏អ្នកនោះមានជំងឺសរសៃប្រសាទធ្ងន់ដែលនឹងត្រូវអត់ឱនទោសបានគឺជាភារកិច្ចរបស់អ្នកដែលនៅរស់រានមានជីវិត ។ ប្រការនេះមានន័យថា អ្នកដែលរស់រានមានជីវិតជាអ្នកត្រូវធ្វើការអត់ឱនទោស ។

### ១) រឿងរ៉ាវអំពីការអត់ឱនទោស ការអភ័យទោសដល់ជនដៃដល់

ប្រធានាធិបតីដែលមានសម្បុរខ្មៅលើកទីមួយរបស់ប្រទេសអាហ្វ្រិកខាងត្បូងឈ្មោះ នេលសាន់ ម៉ែនដេឡា បានជាប់ក្នុងពន្ធនាគារអស់រយៈពេល២៧ឆ្នាំ ។ ក្នុងឆ្នាំ១៩៦២ គាត់ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិតនៅក្នុងគុកសន្តិសុខមួយនៅលើកោះ រូបបេន ពីបទព្យាយាមផ្តួលរំលំរដ្ឋាភិបាលផ្តាច់ការមួយដែលគ្រប់គ្រងដោយមេដឹកនាំដែលមានសម្បុរស ហើយជាជនជាតិភាគតិចនៅក្នុងប្រទេសនេះ ។ ក្រុមគ្រួសាររបស់ម៉ែនដេឡាត្រូវបានទទួលរងការធ្វើទុកបុកម្នេញដូចគ្នា ទោះជាមិនបានធ្វើការឃុំឃាំងក្តី ។ ក្រោយពេលដែលគាត់ត្រូវបានដោះលែងឲ្យមានសេរីភាព លោក ម៉ែនដេឡា បានអញ្ជើញអ្នកដែលឃុំឃាំងរូបគាត់មកចូលរួមពិធីផ្ទេរតំណែងរបស់គាត់ជាប្រធានាធិបតីផងដែរ ។

ចំណែកឯមេដឹកនាំនយោបាយនិងសាសនា ដាឡៃ ឡាម៉ា វិញ បានធ្វើការអត់ឱនទោសជាលក្ខណៈផ្ទាល់ខ្លួននិងជាសមូហភាពដល់ជនជាតិចិនដែលបានលុកលុយដែនដីរបស់គាត់បណ្តាលឲ្យមានការស្លាប់ដល់ប្រជាជនរបស់ប្រទេសទីបេដល់ទៅចំនួនមួយភាគប្រាំនៃចំនួនប្រជាពលរដ្ឋទាំងអស់ ។ ដាឡៃ ឡាម៉ា មានជំនឿថា «មនុស្សគ្រប់រូបគួរតែអត់ឱនទោសដល់ជនដែលប្រព្រឹត្តអំពើឃោរឃៅមកលើខ្លួនយើងនិងអ្នកដទៃ» ។ នៅពេលនរណាម្នាក់ទទួលរងនូវអំពើឃោរឃៅ អ្វីដែលលោកមានការបារម្ភបំផុតនោះគឺការបាត់បង់នូវសមានចិត្ត និងក្តីអាណិតអាសូរ ។

### ការអភ័យទោសដល់ឃាតករ និងជនចាប់ជម្រិត

អ្នកស្រី ម៉ារៀតថា ដែហ្គើ បានធ្វើការអត់ឱនទោសដល់បុរសម្នាក់ដែលបានចាប់ជម្រិតនិងសម្លាប់កូនស្រីដែលមានអាយុ៧ឆ្នាំជាទីស្រឡាញ់របស់គាត់ឈ្មោះ ស៊ូស៊ី ទោះបីជាលើកដំបូងគាត់មានបំណងដើម្បីសម្លាប់បុរសនោះដោយដៃរបស់គាត់ ហើយចងកំហឹងនឹងបុរសនោះក៏ដោយ ។ អ្នកស្រីមានជំនឿថា ព្រះគឺជាព្រះនៃភាពសន្តោស ហើយអ្នកដែលចាប់ជម្រិត ស៊ូស៊ី គឺជាកូនប្រុសរបស់ព្រះ ដែលមានភាពថ្លៃថ្នូរនិងមានតម្លៃ ។ អ្នកស្រីដឹងច្បាស់ថា ជម្រើសដ៏ប្រសើរបំផុតរបស់គាត់ដើម្បីធ្វើឲ្យគាត់មាន

ភាពរីករាយ សេចក្តីថ្លៃថ្នូរ និងមានសុខភាពមាំមួនគឺត្រូវរៀនចេះអត់ឱនទោស ហើយគាត់មានជំនឿថា ការចងគំនុំនឹងធ្វើឲ្យរូបអ្នកស្រីក្លាយជាជនរងគ្រោះផ្សេងទៀតនៃជនចាប់ជម្រិតម្នាក់ទៀតមិនខាន ។ អ្នកស្រីបាននិយាយទៅកាន់ជនចាប់ជម្រិតនោះ ដោយសួរបុរសនោះថា អ្វីដែលអ្នកស្រីធ្វើបានគឺជួយបុរសនោះឲ្យឆ្លងផុតនូវភាពខ្វោចផ្សាទាំងពួង ។

ប្អូនស្រីរបស់ ម៉ារៀន ដាទីងថន ឈ្មោះ លូស៊ី ត្រូវបានចាប់ជម្រិត រំលោភ ធ្វើទារុណកម្ម និងសម្លាប់ ក្រោយមកកាត់រូបរាងកាយនាងជាច្រើនបំណែក ។ ម៉ារៀន បានព្យាយាមយ៉ាងលំបាកក្នុងការដើរលើវិថីឆ្ពោះទៅកាន់ភាពអត់ឱនទោស ។ ក្រោយពេលដែលធ្វើកិច្ចការលើកម្រោងមួយអំពីយុត្តិធម៌ផ្សះផ្សានៅក្នុងគុកមួយនៅទីក្រុងប្រីសស្តុល ម៉ារៀន រកឃើញថាជនដៃដល់ភាគច្រើនធ្លាប់ជាជនរងគ្រោះកាលពីនៅកុមារភាព ។ ដូច្នេះគាត់អាចធ្វើការអត់ឱនទោសដល់ឃាតករសម្លាប់ប្អូនស្រីរបស់គាត់បាន ។ សម្រាប់រូបគាត់ ការអត់ឱនទោសមិនមែនជាឆន្ទៈក្បត់នឹងប្អូនស្រីរបស់គាត់ឈ្មោះ លូស៊ី នោះទេ តែជាការផ្តល់កិត្តិយសដល់ លូស៊ី ទៅវិញ ។

**ការអត់ឱនទោសដល់ឃាតករដែលព្យាយាមធ្វើឃាតមកលើខ្លួន**

ប៉ូលិសម្នាក់ឈ្មោះ ប៊ីលី ប៊ើន ត្រូវបានចោរប្លន់ធនាគារបាញ់ចំមុខរបស់គាត់ ។ ប៊ីលី បានរស់រានមានជីវិតពីមុខរបួសដែលយាយីដល់ជីវិតរបស់គាត់ ប៉ុន្តែស្នាមរបួសនោះមិនអាចវិលទៅរកសភាពដើមបានឡើយ ។ ចោរប្លន់ធនាគារដែលបាញ់មកលើរូបគាត់នោះឈ្មោះ ស្តេវិន ករសា អាក្កា ត្រូវបានចាប់ខ្លួនបន្តិចក្រោយព្រឹត្តិការណ៍ ហើយត្រូវដាក់ពន្ធនាគារអស់មួយជីវិត ។ ប្រាំពីរឆ្នាំក្រោយមក ស្តេវិន បានសរសេរសំបុត្រមួយទៅ ប៊ីលី ដោយរៀបរាប់អំពីឧក្រិដ្ឋកម្មទាំងអម្បាលម៉ាន ហើយទីបញ្ចប់នៃសំបុត្រគាត់បានធ្វើការសុំទោស ។ ប៊ីលី បានអភ័យទោសដល់ ស្តេវិន ទាំងស្រុង ដោយបានបញ្ជាក់អំពីវិប្បដិសារីដែល ស្តេវិន មាន ហើយពួកគេគឺជាមិត្តភក្តិនឹងគ្នា ។

**ការអត់ឱនទោសដល់ជនដែលវាយប្រហារដោយគ្រាប់បែក**

ឪពុករបស់ ចូ ប៊ើរី ឈ្មោះ អេនថូនី ប៊ើរី ត្រូវបានសម្លាប់នៅក្នុងខបទុវហេតុដោយការដាក់គ្រាប់បែកបំផ្ទុះនៅក្នុងសណ្ឋាគារមួយដោយក្រុមទាហានសាធារណរដ្ឋបណ្តោះអាសន្នរបស់ប្រទេសអៀឡង់ កាលពីឆ្នាំ១៩៨៤ ។ ដោយបំណងចង់ដឹងអំពីមូលហេតុ ចូ បានធ្វើដំណើរទៅកាន់ប្រទេស អៀឡង់ ហើយបានស្តាប់អំពីរឿងរ៉ាវរបស់ជនរងគ្រោះជាច្រើនដែលបានជាប់នៅក្នុងសណ្ឋាគារនៅពេលអំពើហិង្សាកំពុងកើតឡើង ។ ក្រោយពីស្តាប់រឿងទាំងអស់ហើយ ចូ ហាក់មាន ជំនឿថា «ទោះបីជាស្ថិតនៅជ្រុងខាងណានៃជម្លោះក៏ដោយ យើងរស់នៅតាមបែបផែនរៀងៗខ្លួន ហើយយើងក៏អាចធ្វើអ្វីៗបានដូចអ្នកដទៃដែរ» ។ នៅពេលកំពុងតែចែករំលែករឿងរ៉ាវឈឺចាប់រវាងជនរងគ្រោះនិងជនដៃដល់ ចូ បានជួបជាមួយនឹងបុរសម្នាក់ឈ្មោះ ផេត ម៉ាស៊ីដែលជាអ្នកដាក់គ្រាប់បែកឲ្យផ្ទុះ ។ អស់រយៈពេលពីរបីឆ្នាំក្រោយមក អ្នកទាំងពីរបានស្គាល់គ្នាយ៉ាងជិតស្និទ្ធ ។ ចូ បានអភ័យទោសដល់ ផេត ដោយផ្នែកខ្លះ ហើយក្រោយមក ផេត ចាប់ផ្តើមធ្វើការអភ័យទោសដល់ខ្លួនឯង ។

ក្នុងឆ្នាំ១៩៩០ ដៃរបស់ ម៉ៃឃើល លេបស្លេ ត្រូវបានផ្ទុះដាច់ចេញពីដងខ្លួន ត្រចៀកត្រូវរបួសដោយដាច់ជាបំណែក ហើយភ្នែកម្ខាងត្រូវខ្វាក់ដោយសារគ្រាប់បែកមួយគ្រាប់ក្នុងការវាយប្រហារពីសំណាក់ក្រុមរដ្ឋាភិបាលអាហ្វ្រិកខាងត្បូង ។ គាត់មិនមានបំណងចងកំហឹង និងចង់សងសឹកទេ ។ គាត់បាននិយាយថា គាត់បានធ្វើដំណើរពីជនរងគ្រោះទៅជាអ្នករស់រានមានជីវិត ហើយនឹងទៅជាអ្នកឈ្នះ ។ ទោះបីជាគាត់អះអាងថា មនុស្សគ្រប់រូបអាចជាជនដៃដល់និងជាជនរងគ្រោះឬអាចទាំងពីរ គាត់មានជំនឿទៅលើយុត្តិធម៌ផ្សះផ្សា និងសំណាងជំងឺចិត្ត ។ គាត់អាចធ្វើការអត់ឱនទោសដល់ជនដៃដល់បាន ប៉ុន្តែបានស្នើដល់ជនដៃដល់ទាំងនោះឲ្យមើលថែទាំងដល់ជនពិការដោយសារគ្រាប់បែកនោះផង ដោយមិនមែនជាលក្ខខណ្ឌក្នុងការដោះដូរជាមួយការលើកលែងទោសនោះទេ តែជាផ្នែកមួយនៃការស្តាបនាជំងឺចិត្តនិងសំណាង ។

ក្នុងករណីខាងលើនេះ ជនរងគ្រោះក្នុងហេតុការណ៍ផ្សេងគ្នាបានអត់ឱនទោសដល់ជនដៃដល់ប្រភេទផ្សេងគ្នាក្នុងបទល្មើសមួយចំនួនដូចជា អំពើគាបសង្កត់ខាងនយោបាយ ការសម្លាប់ ការចាប់ជម្រិត ការរំលោភ និងឃាតកម្ម ។ ខ្ញុំសូមទាញនូវការសន្និដ្ឋាន

ពីរ ។ ទី១) ការពិតដែលថាមានមនុស្សច្រើនដែលអាចអត់ឱនទោសដល់អំពើល្មើសទាំងឡាយ ហើយប្រការនេះយើងអាចសន្និដ្ឋានបានថាការអត់ឱនទោសពិតជាអាចធ្វើទៅបាន ។ ទោះបីជាជនរងគ្រោះដែលបានស្លាប់ទៅហើយអាចនឹងអត់ឱនទោសដល់ខ្លួនគាត់ យើងនៅតែមិនដឹងថាតើជនរងគ្រោះអាចអត់ឱនទោសបានដែរឬទេ ប្រសិនបើគាត់នៅរស់ ។

ទីពីរ) សាសនា ទស្សនៈ និងវប្បធម៌របស់បុគ្គលមានតួនាទីយ៉ាងសំខាន់ក្នុងការអត់ឱនទោស ។ ភាពឈឺចាប់ដែលមនុស្សម្នាក់ចាត់ទុកថាជារឿងតូចតាចអាចថាជារឿងធំសម្រាប់មនុស្សផ្សេងទៀតដែលមានការលំបាកក្នុងការអត់ឱនទោស ។ ថេម៉ូស្សុក និងចាន្ទ្រា បានអះអាងថា «ទំហំនិងចិត្តសាស្ត្រនៃការអត់ឱនទោសរវាងបុគ្គលម្នាក់ៗមានលក្ខណៈខុសប្លែកៗពីគ្នាទៅតាមវប្បធម៌របស់គេ ស្ថានភាព អាយុកាល ស្ថានភាពសេដ្ឋកិច្ចសង្គម សុខុមាលភាព គ្រួសារនិងផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ» ។

លើសពីនោះទៅទៀត ជនរងគ្រោះខ្លះដូចជាអ្នកស្រី ម៉ារៀតថា ដែហ្គើ, ម៉ៃឃើល លេបស្លេ, ម៉ារៀន ដាទីងថន, និង ចូប៊ើរី បានសង្កត់ធ្ងន់ទៅលើបុព្វហេតុដែលជំរុញឲ្យជនដៃដល់ប្រព្រឹត្តបទល្មើស ។ ម្យ៉ាងវិញទៀត អ្នកទាំងអស់ខាងលើទទួលស្គាល់ថាអ្នកដែលប្រព្រឹត្តខុសគឺជាកម្លាំងពីខាងក្រៅដែលជំរុញឲ្យពួកគេប្រព្រឹត្តអំពើបែបនេះ ប៉ុន្តែអ្នកទាំងនោះជាអ្នកធ្វើការសម្រេចចិត្តខ្លួនឯងថាត្រូវប្រព្រឹត្តបទល្មើសឬក៏អត់ ។ លោក ហារី វូ ដែលជាជនរងគ្រោះម្នាក់ពីសម័យបដិវត្តន៍វប្បធម៌ទៅប្រទេសចិនត្រូវបានដាក់ឃុំឃាំងអស់រយៈពេល១៩ឆ្នាំពីរឿងជម្លោះផ្នែកនយោបាយ ។ លោក ហារី វូ បន្ទាប់ពីរំឭកពីបទពិសោធន៍របស់គាត់នៅប្រទេសចិន គាត់បានសរសេរនៅក្នុងសៀវភៅ ផ្កាឈូករ័ត្ន ថា ខាល គឺជាមួយផ្នែកនៃអ្វីដែលបានកើតនៅក្នុងសង្គម ប៉ុន្តែ ខាល ជាមនុស្សមានការទទួលខុសត្រូវចំពោះទង្វើអាក្រក់របស់ខ្លួន ។ ខ្មែរក្រហមបានជ្រើសរើសមនុស្សមានអាយុចាប់ពី១២ ទៅក្រោម២០ឆ្នាំដើម្បីធ្វើជាទាហាន អ្នកសម្លាប់ និងឆ្មាំគុកដើម្បីបម្រើរបបរបស់មនុស្សមួយក្តាប់តូច ។ ក្មេងៗ ជនក្រីក្រ ជនខ្វះចំណេះដឹងត្រូវបានធំដឹងក្តីឡើងនៅក្នុងវប្បធម៌ហិង្សាមួយ ហើយដោយខ្លាចនូវការធ្វើទារុណកម្មដ៏ធ្ងន់ធ្ងរឬក៏សម្លាប់ បានខំបម្រើបក្សយ៉ាងអស់ពីសមត្ថភាព ។ ជាភ័ព្វសំណាងដ៏អាក្រក់ណាស់សម្រាប់ក្មេងៗទាំងនោះដែលបានស្ថិតក្នុងស្ថានការណ៍បែបនេះ ប៉ុន្តែនេះជាការសម្រេចចិត្តរបស់ពួកគេ ។ នៅក្នុងចំណុចនេះ សម្រាប់លោក ម៉ៃឃើល លេបស្លេ បានបកស្រាយថា អ្នកដែលបានប្រព្រឹត្តខុសគួរតែថែទាំគាត់សម្រាប់ការធ្វើឲ្យគាត់មានរបួសក្នុងទម្រង់ជាការជួសជុលវិបត្តិដួងចិត្តនិងស្តាបនានូវអ្វីដែលបានខូចខាំ ។ ពេលដែលយើងបន្ទោសរចនាសម្ព័ន្ធសង្គមពីបទធ្វើឲ្យមនុស្សទទួលរងនូវទុក្ខទោស យើងក៏គួរតែបន្ទោសសង្គមផងដែរ ដែលធ្វើឲ្យមនុស្សម្នាក់នេះក្លាយជាជនកំណាចបែបនេះតាមរយៈការឃោសនានិងការអប់រំមនោគមន៍វិជ្ជានយោបាយដូចអ្វីដែលបានកើតឡើងក្នុងអំឡុងនៃការដឹកនាំរបស់ពួកណាហ្ស៊ីនៅអាឡឺម៉ង់ បដិវត្តន៍វប្បធម៌នៅប្រទេសចិន និងរបបខ្មែរក្រហមនៅប្រទេសកម្ពុជា ។

## គ) ការអត់ឱននៅក្នុងសាសនា

មានភាពច្បាស់លាស់បន្តិចដែរដែលថា នៅក្នុងសាសនាគ្រិស្តការអត់ឱនអាចធ្វើទៅបាន ។ ឃ្លាសំខាន់បំផុតគឺពាក្យរបស់ព្រះយេស៊ូពីឈើឆ្កាង «លោកឪពុកអត់ឱនដល់ពួកគេផង ដោយសារពួកគេមិនដឹងអំពីអ្វីដែលពួកគេធ្វើ» ។ ឃ្លានេះបង្ហាញន័យអំពីសមត្ថភាពដែលគ្មានដែនកំណត់របស់ព្រះក្នុងការអត់ឱន ។ ក្នុងនាមជាអ្នកបម្រើសេវាម្នាក់ទៅព្រះវិហារក្រោមសង្ឃរាជ៤អង្គ និងសមាជិកក្រុមប្រឹក្សាវិទ្យាស្ថានដើម្បីសន្តិភាពរបស់សហរដ្ឋអាមេរិក សេអរដ័រ ហេសប័រ លើកឡើងថា «...បាបកម្ម (អំពើឃោរឃៅរបស់ណាហ្ស៊ី)...គឺធំធេងណាស់ ។ វានៅតែមានកំណត់ ហើយការករុណារបស់ព្រះគឺមិនមានកំណត់ ។ ប្រសិនបើស្នើសុំឲ្យអត់ឱនចំពោះអ្វីក៏ដោយ ខ្ញុំគួរតែអត់ឱនពីព្រោះព្រះនឹងអត់ឱន ។ ប្រសិនបើខ្ញុំទទួលរងការឈឺចាប់ដូចមនុស្សជាច្រើនបានទទួលរង... ខ្ញុំនឹងនៅតែអត់ឱន...ក្នុងនាមជាអ្នកជំនួសឲ្យព្រះជាម្ចាស់និងព្រះមហាអត់ឱន» ។

ខាឌីនល កូនិក អតីតអ្នកដឹកនាំក្នុងសាសនាប្រចាំទីក្រុងវីយែន ពន្យល់ក្នុងកាយវិការកក់ក្តៅថា «សំណួរថាតើការកម្រិតនៃការអត់ឱនត្រូវបានឆ្លើយដោយព្រះយេស៊ូនៅក្នុងន័យអវិជ្ជមានដែរឬទេ?»

នៅក្នុងសាសនារបស់ពួកជ្វីហ្វ អ្នកជំនាញដែលកាន់សាសនា

របស់ជ្វីហ្វ អេលៀត ដហ្វ លើកឡើងស្រដៀងគ្នាថា «...ព្រះខ្លួនឯងកំពុងតែអត់ឱន ដូច្នេះយើងដែលធ្វើតម្រាប់តាមព្រះត្រូវតែធ្វើដូច្នោះដែរ» ហើយគាត់ដកស្រង់ពាក្យរបស់ រ៉ាប៊ី នៅក្នុងគម្ពីរតូរ៉ាថា «...ដូចជាព្រះមហាករុណា អ្នកត្រូវតែមហាករុណាដែរ... ដូចជាព្រះមហាអាណិតស្រឡាញ់ អ្នកត្រូវតែចេះអាណិតស្រឡាញ់ដែរ» ។

នៅក្នុងសាសនាដែលមានដើមកំណើតស្រដៀងគ្នា ដូចជាសាសនារបស់អាប្រាហាំ ដែលរួមមានសាសនារបស់ពួកជ្វីហ្វ គ្រិស្តសាសនា និងសាសនាឥស្លាម អ្នកដើរតាមត្រូវបានរំពឹងថាធ្វើតម្រាប់តាមព្រះដែលផ្តល់ការអត់ឱនឲ្យមនុស្ស ។ នៅក្នុងករណីសិក្សាជាច្រើន អ្នកដែលអាចអត់ឱនឲ្យអ្នកប្រព្រឹត្តខុសគឺជាមនុស្សដែលមានការលះបង់ដល់សាសនា ។

នៅក្នុងសាសនាព្រះពុទ្ធមិនមានការណែនាំដោយផ្ទាល់តាមគម្ពីរដ៏ពិសិដ្ឋគឺគម្ពីរព្រះត្រៃបិដក សម្រាប់មនុស្សដើម្បីអត់ឱនទេ ។ នៅក្នុងសាសនានេះ ជាជាងការធ្វើត្រាប់តាមព្រះ មនុស្សត្រូវបានផ្តល់ដំបូន្មានឲ្យចេះស្រឡាញ់និងធ្វើអំពើល្អចំពោះអ្នកដទៃ រួមមានការមិនគុំកួនចងគំនុំ ។ ដំបូន្មានដែលល្បីល្បាញរបស់ព្រះពុទ្ធគឺ «ពៀររំងាប់ដោយការមិនចងពៀរ» ។ ច្បាប់កម្មផលដែលមនុស្សជឿនៅក្នុងសាសនាព្រះពុទ្ធនិងសាសនាហិណ្ឌូ គឺជាច្បាប់មួយដែលវិនិច្ឆ័យថាតើមនុស្សម្នាក់គួរតែទទួលបានផលអាក្រក់ចំពោះអំពើបាបរបស់ខ្លួននៅក្នុងជាតិនេះឬជាតិក្រោយឬទេ ។ កម្មផលត្រូវបានចាត់ទុកជាភ្នែករបស់ព្រះដែលមើលឃើញអ្វីៗទាំងអស់ ។ កម្មផលចាត់ទុករាល់កត្តាទាំងឡាយដែលពាក់ព័ន្ធនឹងការបំពានជាក់លាក់ណាមួយ ។ អាស្រ័យដូច្នេះហើយ គ្មានភាពចាំបាច់ណាសម្រាប់មនុស្សដើម្បីបំផ្លាញជីវិតរបស់ខ្លួនដោយការស្អប់ខ្ពើម ការជូរចត់ ការអាក់អន់ចិត្ត និងអារម្មណ៍ផ្សេងទៀតនៃភាពអយុត្តិធម៌ឡើយ ។ មនុស្សបានដាក់រឿងរ៉ាវទាំងអស់ទៅលើកម្មផល ។ ម៉ាស្ស៊ែរ រីឆាដ ដែលជាព្រះសង្ឃ និងអ្នកបកប្រែឲ្យសម្តេចសង្ឃ ដាឡៃ ឡាម៉ា បានសន្និដ្ឋានថា «សម្រាប់ពុទ្ធសាសនិក ការអត់ឱនតែងតែអាចធ្វើទៅបាន ហើយយើងគួរតែអត់ឱនឲ្យគ្នាជានិច្ច» ។

នៅក្នុងសេចក្តីសន្និដ្ឋាន ការអត់ឱនគឺតែងតែអាចធ្វើទៅបាន (ទោះបីជាក្នុងស្ថានការណ៍ជាច្រើន ការអត់ឱនមិនគួរឲ្យចង់បានក៏ដោយ ក៏វាមិនមែនមិនអាចធ្វើទៅរួចទេ) ដោយសារមានមនុស្សដែលសម្រេចបានការអត់ឱនទៅនឹងការប្រព្រឹត្តកំហុសជាច្រើន ហើយវាស្របនឹងពាក្យរបស់ព្រះ «ពួកគេមិនដឹងថា ពួកគេធ្វើអ្វី» ។ កម្លាំងខាងក្រៅគឺជាកត្តាលាក់កំបាំងនាំឲ្យជនល្មើសប្រព្រឹត្តកំហុស ទោះបីជនល្មើសធ្វើសេចក្តីសម្រេចចិត្តចុងក្រោយក៏ដោយ» ។ ទោះបីជាពួកគេមិនអាចអះអាងពីបទល្មើសក៏ដោយ ក៏កម្លាំងខាងក្រៅនេះធ្វើឲ្យមានការលំបាកក្នុងការចងកំហឹង ។ សម្រាប់ផលប្រយោជន៍យុត្តិធម៌ ជនល្មើសត្រូវតែទទួលខុសត្រូវចំពោះការសម្រេចចិត្តនេះ ។ ដោយសារការអត់ឱនតែងតែអាចទៅរួចជានិច្ចនោះ ការអត់ឱនអាចត្រូវបានបង្រៀន ។

## ២.៣) ទស្សនៈចិត្តសាស្រ្តនិងទស្សនៈដទៃទៀត

ការបង្រៀនឲ្យចេះអត់ឱនឬការរៀនអត់ឱនពាក់ព័ន្ធនឹងបុគ្គលដែលខំព្យាយាមអត់ឱន ជំនួយការរបស់អ្នកព្យាបាលរោគដើម្បីជួយមនុស្សម្នាក់ឲ្យអត់ឱនឬមនុស្សម្នាក់កំពុងត្រូវបានបង្រៀនតាមរយៈសាសនាឬការអប់រំក្នុងប្រព័ន្ធឬក្រៅប្រព័ន្ធឲ្យចេះអត់ឱន ។

និយមន័យដែលត្រូវបានផ្តល់ដោយ អិនរ៉ាយធ៍ និងសហសេវិករបស់គាត់សង្កត់ធ្ងន់ទៅលើ «សិទ្ធិចំពោះការអាក់អន់ចិត្ត ការវិនិច្ឆ័យអវិជ្ជមាន និងឥរិយាបថខុសគ្នា» របស់ជនរងគ្រោះ ។ ម៉ារីតា ចាហ្គី បានលើកឡើងអំពី «សិទ្ធិធម្មតាដំបូង សុពលភាពការឆ្លើយតបរបស់មនុស្សចំពោះកំហឹងប្រឡោត» ។ សិទ្ធិមានអារម្មណ៍អវិជ្ជមានបង្កប់ន័យថាអារម្មណ៍ទាំងអស់នោះមានជាប់មករហូត ប៉ុន្តែមិនអាចគ្រប់គ្រងបាន ។ នេះមានន័យថា ជនរងគ្រោះត្រូវការប្រឹងប្រែងយកឈ្នះកំហឹងរយៈពេលខ្លី ហើយអត់ឱនឲ្យបានក្នុងរយៈពេលវែង ។ នោះគឺត្រូវរៀនអត់ឱន ។

ការបកស្រាយនេះត្រូវបានគាំទ្រដោយការអង្កេតរបស់ អិនរ៉ាយធ៍ ដែល «...មនុស្សជាច្រើនមិនពិចារណាចំពោះការអត់ឱនដោយមនសិការនោះទេ នៅពេលមនុស្សម្នាក់ផ្សេងទៀតធ្វើឲ្យខ្លួនឈឺចាប់ខ្លាំង» ។ ទស្សនវិទូ ចូអាណា ន័រស៍ លើកឡើងថា ការអត់ឱនគឺជា «ការផ្លាស់ប្តូរចិត្តដោយសុឆន្ទៈ លទ្ធផលនៃការខំខ្នះខ្នែងយ៉ាងសកម្មប្រកបដោយជោគជ័យដើម្បីជំនួសការគិតមិន

ល្អ ដោយការគិតល្អ ភាពល្វីងជូរចត់និងកំហឹងដោយសេចក្ដីអាណិតនិងស្រឡាញ់» ។ ដូច្នេះហើយ វាមានហេតុផលសមស្របដើម្បីបង្ហាញថាការរៀនអត់ឱនបានកើតឡើងចំពោះមនុស្សគ្រប់រូបដែលបានអត់ឱន ។ អ្នកព្យាបាលរោគផ្លូវចិត្ត ប៉ូល ខូលមែន អះអាងថា «ការអត់ឱននឹងសម្រេចចិត្តផ្ដល់ការស្រឡាញ់ដល់មនុស្សម្នាក់ដែលក្បត់ការស្រឡាញ់នោះ» ហើយ «ការអត់ឱនគឺជាការចាំបាច់នៅរាល់បញ្ហាគ្រួសារដែលមានការឈឺចាប់ខ្លាំង ការក្បត់ឬមិនស្មោះត្រង់ ។ ប្រសិនបើមិនអាចមានការផ្សះផ្សា នោះការអត់ឱនគឺជាដំណើរការដែលអាចឲ្យអ្នកអត់ឱនមានការចម្រើនជឿនលឿនទៅមុខដោយគ្មានការរារាំងការឈឺចាប់ចំពោះភាពក្បត់ ។

## ៣) តើការអត់ឱនត្រូវបានបង្រៀនយ៉ាងម៉េច?

វាហាក់ដូចជាថាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយប្រកបដោយប្រសិទ្ធភាពជាច្រើនដើម្បីជួយមនុស្សឲ្យអត់ឱនគឺនាំជនរងគ្រោះនិងអ្នកប្រព្រឹត្តកំហុសឲ្យជួបគ្នា ។ វិធីសាស្ត្រកំពុងត្រូវបានប្រើដោយគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានៅប្រទេសអាហ្វ្រិកខាងត្បូង តុលាការកាឆាឆានៅប្រទេសរវ៉ាន់ដា និងវិទ្យាស្ថានដើម្បីការផ្សះផ្សានិងការចងចាំ ។ វិធីសាស្ត្រនេះក៏បានបង្ហាញឡើងនៅក្នុងការងារសម្រុះសម្រួលរវាងជនរងគ្រោះនិងជនល្មើសរបស់ បាបារ៉ា ទូដ័រ ដែលបានលើកឡើងថា ភាគច្រើននៃរឿងក្ដីរបស់គាត់បានបញ្ចប់ត្រឹមការអត់ឱន ។ អ្នកស្រី ទូដ័រ កំពុងធ្វើការនៅក្នុងមូលដ្ឋានអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ គាត់អនុញ្ញាតឲ្យជនរងគ្រោះដើរតួនាទីសកម្មច្រើនថែមទៀតក្នុងការស្វែងរកយុត្តិធម៌បែបស្ដារឡើងវិញ ដូចជាផ្ដល់ព័ត៌មាននិងបង្ហាញចេញនូវការឈឺចាប់និងតម្រូវការផ្ទាល់ខ្លួន ។ ទាំងជនរងគ្រោះនិងជនល្មើសត្រូវបានជួយឲ្យមានការពិភាក្សាទល់មុខគ្នា និងជួយដល់ដំណើរការណែនាំផ្សេងទៀតនៅពេលវេលាបន្ថែមទៀតដែលជួយឲ្យពួកគេដឹងពីស្ថានភាពជីវិតរបស់គ្នាទៅវិញទៅមក ។ យោងតាមអ្នកស្រី ទូដ័រ ការទាក់ទងគ្នាទៅវិញទៅមកអាចជួយឲ្យពួកគេដោះស្រាយជាមួយលទ្ធផលក្រោយពីបទល្មើសដោយដាក់អតីតកាលនៅក្រោយ ហើយចាប់ផ្ដើមនិយាយអំពីការអត់ឱននិងអនាគតឲ្យប្រសើរឡើង ។

សាសនាបានដើរតួនាទីសំខាន់ក្នុងការអត់ឱន ។ មនុស្សស្ទើរតែទាំងអស់ដែលបានលើកឡើងថា ពួកគេអាចអត់ឱនឲ្យរបបណាហ្ស៊ីនៅក្នុងសៀវភៅសៀវភៅផ្កាឈូករ័ត្នគឺជាអ្នកកាន់សាសនាជាពុទ្ធសាសនិក ឬគ្រិស្តសាសនិក ឬអ្នកគោរពសាសនារបស់ជ្វីហ្វ ។ ពួកគេធ្វើដូច្នេះដោយជឿនិងដើរតាមដំបូន្មានរបស់ព្រះយ៉ាងខ្លាំងដែលថាការអត់ឱនគឺជារឿងដែលល្អបំផុតដែលត្រូវតែធ្វើ ហើយទទួលអំនួតនៅក្នុងដំណើរការនិងលើកកម្ពស់ការគោរពចំពោះខ្លួន ។

ម្យ៉ាងវិញទៀត វិទ្យាសាស្ត្រក៏បង្កើតគំរូនៃការអត់ឱនដែរ ។ អ្នកស្រាវជ្រាវខុសគ្នាមានគំរូខុសគ្នាដោយផ្អែកលើការរកឃើញរបស់ខ្លួន ។ គំរូល្អឥតខ្ចោះដែលគួរតែមានប្រសិទ្ធភាពក្នុងការជួយមនុស្សឲ្យអត់ឱននៅរាល់ករណីទាំងអស់គឺមិនទាន់បង្កើតឡើងនៅឡើយទេ ហើយប្រទាក់គ្នាជាមួយនិយមន័យនិងការយល់ដឹងអំពីការអត់ឱន ។ ប្រសិនបើនិយមន័យមានគុណវិបត្តិ គំរូនឹងមានគុណវិបត្តិ ។ ចំណេះដឹងត្រឹមត្រូវដែលអ្នកស្រាវជ្រាវមានទៅលើការអត់ឱនគឺគំរូដ៏ប្រសើរដែលពួកគេអាចបង្កើតឡើង ។ ឧទាហរណ៍ មីសែល ណែលសុន ស្នើឲ្យមានប្រភេទបីយ៉ាងចំពោះការអត់ឱនគឺការអត់ឱនដែលធ្វើឡើងតែឯង ការអត់ឱនមាន កម្រិតព្រំដែន និងការអត់ឱនពេញលេញ ។ ប្រសិនបើការអត់ឱនមានប្រភេទច្រើនយ៉ាងយោងទៅតាមកម្រិតដែលគាត់បានស្នើឡើង វាមានន័យថា អ្នកព្យាបាលរោគដែលចង់ឲ្យអ្នកជំងឺរបស់ខ្លួនសម្រេចបាននូវការអត់ឱនពេញលេញនិងកម្រិតគោលដៅខ្ពស់ណាស់ចំពោះពួកគេខណៈដែលមិនគិតដល់ភាពរីកចម្រើនដែលពួកគេធ្វើបាន ។

អិនរ៉ាយធ៍ និងសហសេវិករបស់គាត់មកពីសកលវិទ្យាល័យវីស្កន់សិនបង្កើតគំរូនៃការអត់ឱនជា៤ដំណាក់កាលគឺការលាតត្រដាង ការសម្រេចចិត្ត ការងារ និងលទ្ធផល ។ នៅក្នុងដំណាក់កាលលាតត្រដាងជនរងគ្រោះទទួលស្គាល់ការឈឺចាប់របស់ខ្លួន ហើយឆ្លងកាត់ការឆ្លើយតបចំពោះការឈឺចាប់តាមបែបចិត្តសាស្ត្រ ។ នៅក្នុងដំណាក់កាលទី២ គាត់ធ្វើសេចក្ដីសម្រេចចិត្តដើម្បីចាប់ផ្ដើមជម្នះការអត់ឱនបន្ទាប់ពីដឹងថា វាគឺជាមធ្យោបាយដែលធ្វើឲ្យមានសុខភាពល្អ ។ បន្ទាប់ពីធ្វើការប្ដេជ្ញាដើម្បីអត់ឱនជនរងគ្រោះចាប់ផ្ដើមធ្វើការគ្រោងជាថ្មីដែលចេញជាលទ្ធផលនៅក្នុងការយោគយល់គ្នាទៅកាន់ជនល្មើសប្រសើរឡើង ប៉ុន្តែមិនមែនលើកទោសឲ្យឡើយ ។ នៅក្នុងដំណាក់កាលចុងក្រោយ ជនរង

គ្រោះកត់សម្គាល់ឃើញថា អត្ថប្រយោជន៍ចំពោះការអត់ឱនអាចទទួលបានការគោរពខ្លួនឯង ដែលផ្តល់ឲ្យបុគ្គលនូវកម្លាំងជំរុញដើម្បីសម្រេចបានការអត់ឱនពេញលេញ ។ សរុបមក នៅក្នុងគំរូនេះជនរងគ្រោះឆ្លងកាត់លំដាប់នៃការឆ្លើយតបតាមបែបធម្មជាតិតាមរយៈការសម្រេចចិត្តនិងការឃើញខ្លួនឯង ។ បន្ទាប់ពីប្រើប្រាស់គំរូនេះជាមួយក្រុមជនរងគ្រោះដែលមានការស្នូន៍ផ្ទាល់ក្នុងជាង១ឆ្នាំ ដែលការអប់រំអំពីការអត់ឱនដំបូងត្រូវបានផ្តល់ឲ្យ ហើយគ្រូបង្ហាត់បង្រៀនត្រូវបានចាត់តាំងឲ្យជួយពួកគេ ក្រុមការងាររកឃើញជនរងគ្រោះ «បានទទួលផលធំធេងនៅក្នុងការអត់ឱន ការគោរពខ្លួនឯង និងក្តីសង្ឃឹម ហើយកាត់បន្ថយការថប់បារម្ភនិងការបាក់ទឹកចិត្តបានច្រើន» ដែលបង្ហាញពីជោគជ័យនៃការអប់រំអំពីការអត់ឱន ។

## ៤) សក្តានុពលនិងព្រំដែននៃការអប់រំពីការអត់ឱននិងការប្រឹក្សាយោបល់

### ៤.១) សក្តានុពល

ដូចដែលបានយល់ស្របដោយអ្នកស្រាវជ្រាវ ការអប់រំទៅលើការអត់ឱនប្រកបដោយភាពជោគជ័យនឹងជួយឲ្យជនរងគ្រោះអត់ឱន ហើយត្រឡប់មកវិញការអត់ឱននឹងផ្តល់លទ្ធផលផ្នែកសុខភាពប្រកបដោយភាពវិជ្ជមានចំពោះជនរងគ្រោះ (នៅក្នុងករណីខ្លះចំពោះជនរងគ្រោះនិងជនល្មើស) ។ ការអត់ឱនអាច «មានសារសំខាន់ចំពោះការព្យាបាលភាពមិនប្រក្រតីខាងផ្លូវមនោសញ្ចេតនានិងផ្លូវចិត្ត ដូចការរកឃើញថ្នាំស៊ុលហ្វានិងថ្នាំពេនីស៊ីលីន ដែលបានព្យាបាលជំងឺឆ្លង» ។ ការអប់រំអំពីការអត់ឱននៅក្នុងប្រព័ន្ធអប់រំសម្រាប់ក្មេងអាចជួយពួកគេឲ្យដោះស្រាយជាមួយអារម្មណ៍អវិជ្ជមានចេញមកពីវិបត្តិដែលត្រូវបានរៀបចំសម្រាប់ការដោះស្រាយជម្លោះដោយសន្តិវិធីនិងជំរុញការយោគយល់គ្នា និងការគោរពគ្នា ។ មនុស្សចាស់អាចទទួលបានផលចំណេញពីការអប់រំស្តីពីការអត់ឱននៅក្នុងឆ្នាំមុនៗសម្រាប់ជីវិតរបស់ពួកគេ ដោយកាត់បន្ថយបញ្ហាដែលមិនទាន់បានដោះស្រាយ ។

យុទ្ធនាការសម្រាប់ការស្រាវជ្រាវអំពីការអត់ឱន ការរៀបចំការស្រាវជ្រាវត្រូវបានគាំទ្រដោយអតីតប្រធានាធិបតីជីមី ខាទ័រ និងសហអ្នកដឹកនាំ ដេមិន ទូទូ អះអាងថា ការអប់រំអំពីការអត់ឱនមានអត្ថប្រយោជន៍ដើម្បីកាត់បន្ថយជំងឺបេះដូងទប់ស្កាត់បទឧក្រិដ្ឋនៅនឹងកន្លែងដែលជាការឆ្លើយតបបែបចងគំនុំត្រូវបានកាត់បន្ថយ ហើយការផ្សះផ្សាការរៀបការដែលមានបញ្ហា ។ បន្ថែមលើពីនេះទៀត ការផ្តល់ប្រឹក្សាអំពីការអត់ឱនមានសក្តានុពលដើម្បីជួយមនុស្សជំនង់ដែលជួបប្រទះការរំលោភផ្នែករាងកាយនិងផ្លូវចិត្ត យុទ្ធជនវៀតណាមដើម្បីដោះស្រាយជំងឺមិនប្រក្រតីដែលជាលទ្ធផលមកពីហេតុការណ៍រន្ធត់នៅក្នុងសង្រ្គាមអ្នកជំងឺពុំរ៉ៃ ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ជនរងគ្រោះដោយជំងឺអេដស៍ឬផ្ទុកមេរោគអេដស៍ ជនរងគ្រោះដែលសម្លាប់ខ្លួននិងជនពិការ ។

ការអប់រំអំពីការអត់ឱនមានសក្តានុពលខ្លាំងមិនត្រឹមតែសម្រាប់បុគ្គល ប៉ុន្តែសម្រាប់សង្គមទាំងមូល ។ នៅប្រទេសអាហ្វ្រិកខាងត្បូង ការអត់ឱនមិនត្រឹមតែជាវិធីសាស្ត្រដើម្បីផ្សះផ្សាផ្ទាល់ខ្លួនទេ វាគឺជា «នយោបាយជាក់ស្តែង» អាស្រ័យលើអ្វីដែលប្រទេសនោះកសាងខ្លួនឯងឡើងវិញ ពីការបំផ្លិចបំផ្លាញដោយរដ្ឋាភិបាលអាប៉ាថេត ។ នៅប្រទេសកម្ពុជានិងប្រទេសដទៃទៀតដែលទទួលរងពីអំពើប្រល័យពូជសាសន៍និងជម្លោះបន្តមកទៀត ដែលយុត្តិធម៌តាមផ្លូវតុលាការអាចសម្រុះសម្រួលឲ្យមានសន្តិភាព ការអត់ឱនផ្តល់ឲ្យនូវដំណោះស្រាយឈ្នះ-ឈ្នះសម្រាប់សុខុមាលភាពបុគ្គលការផ្សះផ្សាជាតិ សន្តិភាព និងការអភិវឌ្ឍ ។ យុទ្ធនាការសម្រាប់ការស្រាវជ្រាវអំពីការអត់ឱនមានគម្រោងធ្វើការស្រាវជ្រាវទៅលើតួនាទីរបស់ក្រុមក្នុងសង្គមដែលមានឥទ្ធិពលទៅលើឥរិយាបថជាពិសេសការអត់ឱនរវាងបុគ្គលនៅក្នុងប្រទេសអៀរឡង់ខាងជើងដើម្បីវិភាគការចម្លងចេញពីសក្តីភាពដែលបានកត់ត្រានៅក្នុងគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានៅប្រទេសអាហ្វ្រិកខាងត្បូងក្នុងការប្រើប្រាស់តួនាទីរបស់ការអត់ឱនបន្ថែមទៀតនៅក្នុងការកសាងប្រទេសឡើងវិញ ដើម្បីបង្កើតឲ្យមានការប្រឹក្សាយោបល់អំពីការអត់ឱនដល់ក្រុមគ្រួសារហ៊ូទូនិងក្រុមទុតស៊ីនៅប្រទេសរ៉ូវ៉ាន់ដា ដែលពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍នៅឆ្នាំ១៩៩៤ ដែលអាចធ្វើឲ្យជីវិតប្រសើរឡើងសម្រាប់ពួកគេ ។

ទីបញ្ចប់ ការអប់រំអំពីការអត់ឱនជួយឲ្យពិភពលោកផ្លាស់សក្តានុពល ។ វាអាចបំបែកការស្អប់ខ្ពើមដែលចេះតែបន្តរវាង

សហគមន៍និងប្រទេសហើយទប់ស្កាត់ជម្លោះ ។ ពិភពលោកតែងតែស្ថិតក្នុងសង្គ្រាមក្នុងសតវត្សរ៍២០ ដែលជាសតវត្សរ៍បង្ហូរឈាមយ៉ាងខ្លាំងបំផុត ហើយនេះកើតឡើងដោយគ្មានការអត់ឱនដែលត្រូវបានរកឃើញថាជាដំណោះស្រាយដើម្បីបញ្ឈប់សង្គ្រាម ។ ទោះបីមានលទ្ធភាពខ្លះៗដែលថាហេតុអ្វីការអត់ឱនមិនត្រូវបានយកចិត្តទុកដាក់ដោយផ្នែកវិទ្យាសាស្ត្រដូចជា ៈ ការអត់ឱនមិនត្រឹមតែត្រូវបានធ្វេសប្រហែសនៅក្នុងវិទ្យាសាស្ត្រសង្គមទេ ប៉ុន្តែទូទាំងពិភពសិក្សា ដោយសារវិទ្យាសាស្ត្រសង្គមទោរទន់ទៅរកការពិចារណាថា ការអត់ឱនគឺជារឿងសាសនា ហើយចិត្តសាស្ត្រតាមបែបវិទ្យាសាស្ត្រទទួចទៅលើការវិភាគឥរិយាបថបែបអង្កេតដែលការអត់ឱនគឺមានការលំបាកក្នុងការអង្កេត នោះហើយក៏មិនត្រូវបានយកចិត្តទុកដាក់ ។ ការស្រាវជ្រាវទៅលើការអត់ឱនបានទទួលនូវភាពសំខាន់ចាប់តាំងពីទសវត្សរ៍៨០ ។ អេវីរ៉េត វឺស៊ិនតុនហៅថា «ភាពគានតឹងខាងពូជសាសន៍កើតឡើងនៅក្នុងសហគមន៍និងជម្លោះហិង្សាជាមួយ និងរវាងប្រទេសនិយាយគាំទ្រកំណើនចំណេះដឹងអំពីវិធីជួយជួសជុលការខូចខាត ។ ការអប់រំអំពីការអត់ឱនអាចនឹងត្រូវបានប្រើប្រាស់ជាវិធីដើម្បីទប់ស្កាត់ជម្លោះ ជំរុញការយោគយល់គ្នាទៅវិញទៅមកនិងហាមឃាត់សេចក្តីត្រាប្រណីក្នុងចំណោមក្រុមប្រកួតប្រជែងគ្នា ។

### ៤.២) ដែនកំណត់

ទាញចេញពីរយៈពេល២០ឆ្នាំនៃបទពិសោធន៍ខាងគ្លីនិកជាពេទ្យចិត្តសាស្ត្រ រីឆាដ ហ្វិតស៍ហ្គីប ប៊ុន បាននិយាយថាការអត់ឱនមានដែនកំណត់ ។ ការអង្កេតមួយដែលគាត់បានធ្វើគឺថា ការអត់ឱនមិនបានដោះស្រាយការឈឺចាប់ផ្នែកអារម្មណ៍ទាំងអស់ ការអាក់អន់ចិត្តដែលលើសលប់ ការប្រទូសរ៉ាយ និងការស្អប់ខ្ពើមទេ ។ វាអាចជួយកាត់បន្ថយទម្ងន់ទុក្ខព្រួយ ប៉ុន្តែមិនជួយព្យាបាលការអស់សង្ឃឹមឬការធ្លាក់ទឹកចិត្តកើតមកពីការឈឺចាប់ជ្រាលជ្រៅទេ ។ លើសពីនេះទៀត សម្រាប់បុគ្គលដែលកំហឹងរបស់ខ្លួនពាក់ព័ន្ធជាមួយនឹងអត្តចរិតខ្សោយ ដូចជាការស្រឡាញ់ងប់ងុលនឹងខ្លួនឯងមហិច្ឆតាខ្ពស់ ភាពមិនអត់ធ្មត់ ហើយមានតម្លៃសីលធម៌ទាប ការអត់ឱនហាក់ដូចជាមិនអាចជួយបាននៅក្នុងការដោះស្រាយបញ្ហាទេ ។ ទោះបីយ៉ាងណាក៏ដោយ ទស្សនៈរបស់ ហ្វិតស៍ហ្គីបប៊ុន មិនអាចវិនិច្ឆ័យថាជាព្រំដែននៃការអត់ឱនផ្ទាល់ខ្លួនទេ ដោយសារគ្មាននិយមន័យទទួលស្គាល់ជាទូទៅដែលជាការអត់ឱនពិតប្រាកដអាស្រ័យដូច្នេះហើយវាអាចថា គាត់កំណត់ពាក្យអត់ឱនចង្អៀតពេក ។

មានការលំបាកមួយចំនួននៅក្នុងការអប់រំអំពីការអត់ឱន ប៉ុន្តែមិនមានដែនកំណត់ចំពោះការអប់រំអំពីការអត់ឱនដោយសារការអត់ឱនតែងតែអាចទៅរួចជានិច្ចទេ ។ ភាពស្មុគស្មាញនៃដំណើរការអត់ឱននិងការខ្វះខាតការយល់ដឹងតាមបែបវិទ្យាសាស្ត្រទៅលើការអត់ឱនជាឧបសគ្គចំពោះការអប់រំអំពីការអត់ឱននិងការប្រើប្រាស់សម្រាប់គោលបំណងជាក់ស្តែង ។ ការអប់រំអំពីការអត់ឱននិងការផ្តល់ប្រឹក្សាអាចនាំទៅរកការអត់ឱនខុសនិងការបាក់ទឹកចិត្ត នៅពេលដែលត្រូវបានផ្តល់ឲ្យជនរងគ្រោះមិនសមរម្យ ។ ខ្ញុំកត់សម្គាល់ឃើញបញ្ហាមួយចំនួនរួមជាមួយនឹងស្នាដៃដែលសរសេរចេញមួយចំនួនត្រូវបានគាក់តែងឡើងដើម្បីជួយមនុស្សឲ្យអត់ឱន ។

មនុស្សជាច្រើនចាត់ទុកសៀវភៅរបស់ ស្មេដ ថាជាសៀវភៅដែលអាចជឿបាននិងប្រកបដោយសុទិដ្ឋិនិយម ដែលមានចំណងជើងថា «ការអត់ឱននិងការបំភ្លេច» អាចជួយបានច្រើន ។ សៀវភៅនេះមានគោលបំណងបង្ហាញផ្លូវដល់អ្នកដែលត្រូវបានធ្វើឲ្យបាបនិងឃុំដោយការស្អប់ខ្ពើមរបស់ខ្លួនផ្ទាល់ដើម្បីរៀនអត់ឱន ។ សៀវភៅនេះពិពណ៌នាបញ្ហានិងរឿងព្រេងជុំវិញការផ្សះផ្សា ។ ស្មេដ បំភ្លឺដោយកក់ក្តៅនិងធានានូវទិដ្ឋភាពនៃការអត់ឱនខុសគ្នា ហើយនាំអ្នកអានឲ្យទទួលយកនូវអាកប្បកិរិយាអត់ឱនបែបសេរីនៅចុងបញ្ចប់នៃសៀវភៅនេះ ។ គាត់បែងចែកការអត់ឱនជា៤ដំណាក់កាល ការឈឺចាប់ ការស្អប់ ការព្យាបាលនិងការមកជួបជុំគ្នា ។ អាស្រ័យលើចំណុចនោះ គាត់ផ្តល់ឲ្យនូវរឿងមួយថាតើមនុស្សអត់ឱនរបៀបម៉េច ត្រូវអត់ឱនឲ្យមនុស្សដែលមានការលំបាកក្នុងការអត់ឱនឲ្យរបៀបម៉េច ហើយហេតុអ្វីមនុស្សគួរតែអត់ឱនដោយប្រើប្រាស់ករណីសិក្សាជាច្រើន ។ ទោះបីយ៉ាងណាក៏ដោយ សៀវភៅនេះខ្វះការពន្យល់បែបវិទ្យាសាស្ត្រអំពីហេតុអ្វីបានជាការអត់ឱនអាចធ្វើបានក្នុងមធ្យោបាយបែបហ្នឹង ។ ចំពោះមនុស្សមួយចំនួន សៀវភៅនេះអាចជួយបាន

ប៉ុន្តែសម្រាប់អ្នកដទៃទៀតដែលមិនអាចអត់ឱនបន្ទាប់ស្វែងរកសេចក្តីពន្យល់ពីសៀវភៅនេះ នឹងមិនដឹងថាហេតុអ្វីបានជាពួកគេមិនអាចអត់ឱន ។ វាក៏អាចនាំទៅរក «ការអត់ឱនដែលមិនស្មោះត្រង់ឬខុស» ឬ «ការអត់ឱនមិនជាក់ស្តែង» ។

ប្រជាប្រិយភាពរបស់ សៀវភៅផ្កាឈូករ័ត្ន អាចជួយជំរុញការគិតទៅលើបញ្ហានៃការអត់ឱន ។ អ្នកចូលរួមចំណែកនៅក្នុងសៀវភៅពិភាក្សាការប្រឈមមុខដាក់គ្នារវាង វ៉ាយសិនថល និងខាល ចេញពីជ្រុងផ្សេងៗជាច្រើន ។ ទស្សនៈរបស់អ្នកចូលរួមចំណែកមួយចំនួនជ្រុលហួសហេតុពេក ចំណែកទស្សនៈរបស់អ្នកចូលរួមដទៃទៀតមានភាពស្មុគស្មាញ ប៉ុន្តែទស្សនៈផ្សេងទៀតផ្តល់ឲ្យនូវការអត់ឱនមិនពេញលក្ខណៈ ។ ទស្សនៈផ្សេងៗទាំងនេះគឺជាបទពិសោធន៍ផ្ទាល់ខ្លួនជាជាងទស្សនៈដែលទទួលស្គាល់ជាទូទៅ ។ សៀវភៅនេះគឺជាប្រភពប្រសើរសម្រាប់ការពិភាក្សា ប៉ុន្តែមិនមានតម្លៃក្នុងការជួយមនុស្សឲ្យអត់ឱន ។ វាមានការលំបាកសម្រាប់អ្នកដែលរំពឹងក្នុងការស្វែងរកចម្លើយមួយចំនួនសម្រាប់បញ្ហាផ្ទាល់ខ្លួនពីសៀវភៅនេះ ។ ការនិយាយថា «បាទឬចាស» ភ្លាមចំពោះការអត់ឱនដោយមនុស្សមួយចំនួនអាចបង្កកំហឹងដល់ជនរងគ្រោះ និងនាំពួកគេទៅរកបន្ទុកទ្វេដង ដែលកំពុងតែត្រូវបានធ្វើឲ្យឈឺចាប់ ហើយត្រូវផ្តល់ការអត់ឱនដូចអ្នកដទៃ ។ នៅពេលជាមួយគ្នានេះដែរ ទស្សនៈប្រែប្រួលគឺជាប្រភពនៃការភាន់ច្រឡំ ។ ប្រសិនបើគ្មានការអត់ឱនសម្រាប់ការសម្លាប់ សំណួរតាមប្រធានបទរបស់ វ៉ាយសិនថល «អ្នកគួរធ្វើអ្វី?» គឺជាសំណួរមិនប្រកបដោយសុពលភាព ហើយមិនគួរមានការពិភាក្សាដោយសារការជួបប្រទះរបស់ វ៉ាយសិនថល មិនស្ថិតនៅក្នុងទ្វេគ្រោះ ។

## ៥) សេចក្តីបញ្ចប់

គោលដៅនៃការសិក្សាអំពីការអត់ឱនគឺដើម្បីជួយមនុស្សឲ្យរៀនថាតើត្រូវអត់ឱនរបៀបម៉េច ។ នៅក្នុងសាសនារបស់អាប្រាហាំ និងនៅក្នុងសាសនាព្រះពុទ្ធនិងសាសនាហិណ្ឌូ ការអត់ឱនតែងតែអាចធ្វើទៅបានជានិច្ច ។ ការពិតដែលថាមានមនុស្សមកពីមូលដ្ឋាននិងវប្បធម៌ផ្សេងគ្នាដែលអាចអត់ឱនចំពោះរាល់បទល្មើសចង្អុលបង្ហាញថា ការអត់ឱនអាចទៅរួចជានិច្ច ។ មានកម្លាំងមកពីខាងក្រៅដែលមិនអាចបង្ហាញថាបទល្មើសជាការត្រឹមត្រូវ ប៉ុន្តែវាធ្វើឲ្យលំបាកដល់ជនរងគ្រោះក្នុងការចងគំនុំជារៀងរហូត ។ ប្រសិនបើយើងបន្ទោសរចនាសម្ព័ន្ធសង្គមហិង្សាជាមូលហេតុបង្កឲ្យមានសង្គ្រាមនិងភាពក្រីក្រដោយលម្អៀងទៅខាងជនរងគ្រោះ យើងក៏គួរតែបន្ទោសរចនាសម្ព័នសង្គមដែលប្រកបដោយភាពហិង្សាជាមូលហេតុបង្កឲ្យមានបទឧក្រិដ្ឋដែលលម្អៀងទៅខាងជនល្មើសដែរ ។

ចេញពីលទ្ធភាពមិនមានកម្រិតព្រំដែននេះ យើងអាចសន្មតដោយសុវត្ថិភាពថា ការអត់ឱនអាចត្រូវបានបង្រៀនឡើង ។ ការអះអាងនេះក៏ត្រូវបានគាំទ្រដោយទស្សនៈខាងចិត្តសាស្រ្តដែលការអត់ឱនគឺជាលទ្ធផលនៃការរៀនតាមរយៈការអប់រំនិងការផ្តល់ប្រឹក្សា ។ ទោះបីយ៉ាងណាក៏ដោយ មានទិដ្ឋភាពសង្គម វប្បធម៌និងជនរងគ្រោះពិសេសដែលបង្កើននិងបន្ថយល្បឿនដំណើរការអត់ឱនរបស់ជនរងគ្រោះ ។ ប្រសិនបើមនុស្សមិនអាចរកឃើញលក្ខខណ្ឌសមរម្យសម្រាប់ការអត់ឱន មនុស្សទំនងជាមិនអាចអត់ឱនឡើយ ។

ការអប់រំអំពីការអត់ឱននិងការផ្តល់ប្រឹក្សាមានសក្តានុពលខ្លាំង ។ វាអាចជួយព្យាបាលបុគ្គល គ្រួសារ និងជាតិ ។ ការអប់រំអំពីការអត់ឱនមានសក្តានុពលផ្លាស់ប្តូរពិភពលោកតាមរយៈការទម្លាយចំណងនៃភាពស្អប់ខ្ពើម ។ ភាពស្មុគស្មាញនៃដំណើរការអត់ឱនធ្វើឲ្យមានការលំបាក ប៉ុន្តែមិនមែនមិនអាចទៅរួចនោះទេដើម្បីសម្រេចឲ្យបានការអត់ឱនពេញលេញ ។ រហូតទាល់តែវិទ្យាសាស្រ្តមានការយល់ដឹងទូលំទូលាយទៅលើការអត់ឱននៅពេលនោះយើងអាចនិយាយប្រាកដថា ការអត់ឱនកម្រិតណាដែលអាចនិងមិនអាចធ្វើបានសម្រាប់យើង ។ **អេង កុកថាយ**

**កម្មវិធីអប់រំអំពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ**

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# នួន ជា កាលពីក្មេងនៅទីក្រុងបាងកក (១៩៤២-១៩៥០) និងបក្សកុម្មុយនីស្តថៃ៖ ជីវិតរបស់បុរសនេះនៅទីក្រុងបាងកកដែលបានក្លាយជា "បងធំទី២" នៅក្នុងរបបខ្មែរក្រហម

***(តពីលេខមុន)***

### ***៦) ការចងចាំរបស់ ស៊ុមខ្វាន ភិគៃុល***

មនុស្សម្នាក់ទៀតដែល នួន ជា បានចុចឈ្មោះថាធ្លាប់មានសកម្មភាពក្បៀវក្លាជាមួយគាត់ក្នុងបក្សកុម្មុយនីស្តថៃគឺ ស៊ុមខ្វាន ភិគៃុល ដែលឈ្មោះនេះត្រូវបានលើកមកនិយាយជាច្រើនដងរួចមកហើយ ព្រមទាំងជាមនុស្សម្នាក់ដែលជិតស្និទ្ធបំផុតជាមួយវុងឡឹត ក្នុងអំឡុងឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៤៨ រយៈពេលមួយដែល នួន ជា បានធ្វើការជាជនកុម្មុយនីស្តមួយរូប បើយោងតាមសាណុះ ជានិតចារើន ។ អ្នកនិពន្ធបានជួបជាមួយ ស៊ុមខ្វាន នៅក្នុងទីក្រុងបាងកកនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៥ នៅក្នុងហាងកាហ្វេជាយក្រុងមួយ ព្រមទាំងធ្វើសម្ភាសន៍ជាមួយគាត់អស់រយៈពេលជិត៣ម៉ោង ។

ស៊ុមខ្វាន បានចាប់ផ្តើមកិច្ចសម្ភាសន៍ដោយនិយាយថា គាត់បានកើតនិងរស់នៅក្នុងស្រុកបានរ៉ៃ ខេត្តណាខន រាជសីម៉ា ។ ថ្ងៃខែឆ្នាំកំណើតរបស់គាត់គឺថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩២៦ ។ បន្ទាប់ពីបានបញ្ចប់ថ្នាក់បឋមសិក្សារយៈពេល៤ឆ្នាំនៅសាលាមូលដ្ឋាន គាត់បានធ្វើដំណើរទៅទីក្រុងបាងកក ដោយមានការជួយទំនុកបម្រុងពីអាចារ្យម្នាក់នៅក្នុងភូមិរបស់គាត់ដែលស្នាក់នៅក្នុងវត្តរ៉ាក់ខាង នាទីក្រុងបាងកក ។ ឪពុករបស់គាត់ក៏ធ្លាប់ធ្វើជាអាចារ្យនៅក្នុងទីក្រុងបាងកកអស់រយៈពេល១៥ឆ្នាំដែរ ហើយបន្ទាប់ពីគាត់ត្រឡប់ទៅកាន់ភូមិកំណើតវិញ គាត់ក៏បានក្លាយទៅជាអ្នកដឹកនាំនៅក្នុងភូមិ ។ ប្អូនប្រុសខាងម្តាយរបស់គាត់បានធ្វើដំណើរទៅទីក្រុងបាងកកហើយបានក្លាយជាមេធាវី ។ គាត់បាននិយាយថា ឪពុកម្តាយរបស់គាត់បានជំរុញឲ្យគាត់រៀនសូត្រ ។ ដើរអស់រយៈពេល៣-៤ថ្ងៃ ចេញពីស្រុកបានរ៉ៃ ទើបគាត់ទៅដល់ស្ថានីយរថភ្លើងនៅស៊ីខៀវ ដែលជាទីកន្លែងគាត់ត្រូវជិះរថភ្លើងទៅកាន់ទីក្រុងបាងកក ។ គាត់រស់នៅក្នុងនិវេសនដ្ឋានរបស់អាចារ្យម្នាក់ក្នុងពេលដែលគាត់កំពុងរៀននៅឯសាលាឯកជនមួយ ។ គាត់បានបញ្ចប់ការសិក្សាថ្នាក់មធ្យមរយៈពេល៣ឆ្នាំ ។ បន្ទាប់មកនៅឆ្នាំ១៩៣៩ គាត់បានចូលសាលាមធ្យមឆ្នាំទី៤នៅសាលាសួនកុលាបដែលជាសាលាប្រកបដោយកិត្យានុភាពគ្រប់គ្រងដោយរដ្ឋាភិបាល ។ នៅពេលនោះ ស៊ុមខ្វាន បានបញ្ជាក់ថា សាលានេះបង្រៀនពីឆ្នាំទី៤ដល់ឆ្នាំទី៦ប៉ុណ្ណោះ ។ អាចារ្យមកពីភូមិកំណើតរបស់គាត់បានមើលថែរក្សាក្មេងៗចំនួន១០នាក់ផ្សេងទៀត រួមទាំងរូបគាត់ផងនៅក្នុងវត្តរ៉ាក់ខាង ។ ការចំណាយលុយកាក់គឺមានលក្ខណៈរឹតត្បិតយ៉ាងខ្លាំង ។ ស៊ុមខ្វាន បាននិយាយថា គាត់បានរស់នៅអស់រយៈពេលពេញ១ឆ្នាំដោយស្លៀកសម្លៀកបំពាក់ដូចៗគ្នា ។ នៅឯសាលាសួនកុលាប ក្មេងៗភាគច្រើនមកពីគ្រួសារធូរធារ ក៏ប៉ុន្តែការចូលរៀននៅសាលានេះគឺតាមរយៈការប្រឡង ។ ដូច្នេះហើយកូនសិស្សក្រីក្រមកពីជនបទក៏អាចចូលរៀនបានដែរ ប្រសិនបើអ្នកទាំងអស់នោះមានសមត្ថភាពប្រឡងជាប់ ។ អស់រយៈពេល៣ឆ្នាំនៅឯសាលាសួនកុលាប ស៊ុមខ្វាន រៀននៅក្នុងថ្នាក់ជាមួយ ថានិន ក្រៃវិឆាន ដែលជាកូនអ្នកធូរធារម្នាក់ ។ ថានិន ទៅសាលាដោយជិះរថយន្ត ។ បើរាប់ទាំង ថានិន ផង មានកូនសិស្សតែ៥នាក់ប៉ុណ្ណោះនៅក្នុងសាលានាពេលនោះដែលទៅរៀនដោយជិះរថយន្ត ។ ក្នុងចំណោមកូនសិស្សរៀនឆ្នាំជាមួយគ្នានៅឯសាលាសួនកុលាប ដូចជា ថានិន កូនសិស្សមួយចំនួនដែលក្រោយមកក្លាយជាសមាជិកបក្សកុម្មុយនីស្តរួមមាន រួម វង់ផាន ចារើន វ៉ាន់ង៉ាម ព្រមទាំង ស៊ុមខ្វាន ខ្លួនគាត់ដែរ ។ ដោយឲ្យយោបល់ទៅលើហេតុការណ៍នេះ ស៊ុមខ្វាន បាននិយាយថា គេបានសរសេរថា ថានិន បានស្ថិតនៅក្រោមឥទ្ធិពលរបស់កុម្មុយនីស្ត អំឡុងឆ្នាំដែលគាត់បានសិក្សាដោយសារតែមិត្តរួមថ្នាក់របស់គាត់ ប៉ុន្តែក្រោយមកគាត់មានប្រតិកម្មប្រឆាំងនឹងការលើកឡើងនេះ ហើយបានក្លាយជាអ្នកប្រឆាំងនឹងកុម្មុយនីស្តយ៉ាងខ្លាំងទៀតផង ។ នៅក្នុងទស្សនៈរបស់

ស៊ុមខុន នេះមិនពិតជាត្រឹមត្រូវទេ ។ ថានិន មិនចូលចិត្តនយោបាយកាលនៅជាសិស្សឡើយ ។ គាត់ជាអ្នកស្តាំនិយមទាំងស្រុង ហើយមិនដែលផ្លាស់ប្តូរយោបល់ជាមួយ ស៊ុមខុន និងក្រុមរបស់គាត់ឡើយ ។ ប៉ុន្តែមិនមែននិយាយថា គាត់និង ថានិន មិនបានរួបរួមគ្នាទាល់តែសោះនោះទេ ។ នៅពេលបុណ្យសពរបស់ម្តាយគាត់ ថានិន គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សទាំងឡាយដែលបានមកគោរពសាកសព ។ នៅពេលចូលរៀនឆ្នាំទី៦ នៅសាលាសួនកុលាប ចារើន វ៉ាន់ម៉ម រូម វង់ផាន និង សុធី ណារ៉ូវ៉ាថាត បានផ្លាស់ចូលមក ។ អ្នកទាំងបីនេះរៀនតែឆ្នាំទី៦ នៅសាលាមធ្យមសិក្សាសួនកុលាបប៉ុណ្ណោះ ។ ដូច្នេះមានន័យថា អ្នកទាំងអស់នេះរៀននៅទីនោះតែមួយឆ្នាំប៉ុណ្ណោះ ។ ក្នុងនាមជាសិស្សក្រីក្រដែលចិញ្ចឹមបីបាច់នៅទីជនបទ ស៊ុមខុន បាននិយាយថា គាត់ និង រូម គឺជាសិស្សចម្លែកខុសគេនៅសាលាសួនកុលាប ដែលសិស្សជាច្រើននៅទីនោះគឺជាសិស្សមកពីក្រុមគ្រួសារមានទ្រព្យសម្បត្តិស្តុកស្តម្ភប្រចាំទីក្រុងបាងកក ។ ដោយធំធាត់នៅក្នុងកាលៈទេសៈស្រដៀងគ្នា អ្នកទាំងនេះក៏ក្លាយជាមិត្តភក្តិជិតស្និទ្ធ ។ ប៉ុន្តែបន្ទាប់ពីការបញ្ចប់ថ្នាក់នៅឆ្នាំ១៩៨១ (នៅពាក់កណ្តាល ឆ្នាំ១៩៨២ដំបូង) រូម បានចូលរៀននៅសាលាជំនួញខណៈពេលដែល ស៊ុមខុន ចុះឈ្មោះចូលរៀននៅសកលវិទ្យាល័យធម្មសាស្ត្រនៅថ្នាក់បញ្ចប់ជំនាន់ទី៥ នៃវគ្គត្រៀម ហើយអ្នកទាំងពីរមិនបានជួបគ្នាម្តងទៀតទេក្នុងរយៈពេលបីឆ្នាំក្រោយមក ។ ការជួបជុំគ្នាបន្ទាប់មកគឺនៅឯសកលវិទ្យាល័យធម្មសាស្ត្រ (ក្នុងឆ្នាំ១៩៨៤) ខណៈពេលដែល រូម បានចុះឈ្មោះរៀននៅមហាវិទ្យាល័យ ។ ចារើន បានទៅរៀនសាលា


នួន ជា

ពាណិជ្ជកម្មបន្ទាប់ពីរៀនចប់ថ្នាក់មធ្យមសិក្សា ហើយមិនបានចូលរៀនវគ្គត្រៀមនៅសកលវិទ្យាល័យទេ ។ បន្ទាប់មក ស៊ុមខុន បានអត្ថាធិប្បាយថា ថ្នាក់មធ្យមសិក្សាដែលគាត់និង ថានិន សុធី ចារើន និង រូម បានចូលរៀនគឺជាថ្នាក់សម្រាប់សិស្សលំដាប់ខ្ពស់ដែលទទួលលទ្ធផលប្រឡងបានចំនួន៧០ភាគរយឬលើសពីនេះ ហើយត្រូវបានស្គាល់ថាជាថ្នាក់ស្តេច ។ ការប្រកួតប្រជែងដើម្បីបានពិន្ទុខ្ពស់មានលក្ខណៈស៊ុតស្វាញក្នុងចំណោមសិស្សានុសិស្សទាំងឡាយ ។ ការប្រកួតប្រជែងនេះមិនបានបង្កើតឲ្យមានបរិយាកាសប្រកបដោយមនោសញ្ចេតនារាប់អានរាក់ទាក់រវាងគ្នាទៅវិញទៅមកទេ ។

នៅពាក់កណ្តាលឆ្នាំ១៩៨២ ស៊ុមខុន ចុះឈ្មោះចូលរៀននៅថ្នាក់បញ្ចប់ជំនាន់ទី៥ នៃវគ្គត្រៀមនៅសកលវិទ្យាល័យធម្មសាស្ត្រ (ឆ្នាំសិក្សា១៩៨២-១៩៨៣) ។ ក្នុងចំណោមអ្នកដែលបានចុះឈ្មោះជាមួយគាត់មានដូចជា ថានិន ក្រៃវិឆៀន សុធី ណាគវ៉ូវ៉ាថាត និង ជួង វ៉ាណាស្រី (១៩៧២-១៩៧៦) ។ ថ្នាក់បញ្ចប់ជំនាន់ទី៥ បែងចែកជា១៥ថ្នាក់ ។ សិស្សឆ្នើមដែលមានពិន្ទុខ្ពស់ស្ថិតក្នុងថ្នាក់លេខ១ (ហុង១) ដែលចាប់ពីថ្នាក់នេះដល់ថ្នាក់លេខ៣ត្រូវបានទទួលស្គាល់ថាជា «ថ្នាក់ស្តេច» (ហុងស្តេច) ។ ថានិន ស្ថិតនៅក្នុងថ្នាក់លេខ១ ប៉ុន្តែ ស៊ុមខុន បាននិយាយថា គាត់ទៅមករវាងថ្នាក់លេខ២ និងលេខ៣ដោយសារពិន្ទុរបស់គាត់ឡើងចុះ ។ ហេតុផលដែលធ្វើឲ្យពិន្ទុរបស់គាត់ស្ថិតនៅក្នុងលំដាប់បែបនេះគឺដោយសារតែគាត់គ្មានប្រាក់គ្រប់គ្រាន់ដើម្បីទិញសៀវភៅសិក្សា ដែលនេះជាសំណាងមិនល្អ ។ គាត់បានបញ្ចប់វគ្គត្រៀមនៅពាក់កណ្តាលឆ្នាំដំបូងនៃឆ្នាំ១៩៨៤ ហើយបានចូលរៀននៅសកលវិទ្យាល័យធម្មសាស្ត្រ (ឯកសារចូលរៀននៅបណ្ណសារដ្ឋានរបស់សកលវិទ្យាល័យបង្ហាញថា ស៊ុមខុន បានចុះឈ្មោះចូលរៀននៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៨៤ ដែលមានលេខសម្គាល់និស្សិត ១៧៧២៧) ។ បន្ទាប់ពីបញ្ចប់វគ្គត្រៀម គាត់បានធ្វើការឲ្យក្រុមហ៊ុនសំណង់របស់ជប៉ុនឈ្មោះ កៃហ្គេ ដូបូគុ ដែលម៉ៅការសាងសង់មូលដ្ឋានកងទ័ពជប៉ុននៅព្រលានយន្តហោះដនមឿង ។ ការងាររបស់គាត់គឺមើលការខុសត្រូវលើកម្មករសាងសង់ជនជាតិថៃ ហើយធ្វើការទាក់ទងជាមួយចៅហ្វាយជនជាតិជប៉ុនជាភាសាអង់គ្លេស ។ ការងាររបស់

គាត់ឲ្យកងទ័ពជប៉ុនគឺងាយស្រួលរកលុយណាស់ ហើយ ស៊ឹមខុន បានប្រាប់អ្នកនិពន្ធថា វាមិនមានអ្វីទាក់ទងជាមួយចលនាថៃសេរីឡើយ ។ គាត់ធ្វើការឲ្យក្រុមហ៊ុនដូបូគុ រហូតដល់ទ្រព្យសម្បត្តិជប៉ុនត្រូវបានរឹបអូសហើយទុកជាទ្រព្យសម្បត្តិរបស់សត្រូវដោយរដ្ឋាភិបាលថៃបន្ទាប់ពីសង្គ្រាម (នៅខែកញ្ញា ឆ្នាំ១៩៤៥) ។ បន្ទាប់ពីនោះ គាត់រកបានការងារនៅការិយាល័យទំនាក់ទំនងដែលរដ្ឋាភិបាលថៃបានបង្កើតឡើងដើម្បីធ្វើសហប្រតិបត្តិការជាមួយកម្លាំងសម្ព័ន្ធមិត្ត ។ យោងតាម ស៊ឹមខុន រដ្ឋាភិបាលថៃបានបង្កើតការិយាល័យនេះឡើងដើម្បីកេណ្ឌ និងគ្រប់គ្រងទ្រព្យសម្បត្តិជប៉ុន (ទ្រព្យសម្បត្តិសត្រូវ) នៅប្រទេសថៃដើម្បីដាក់ទុកឲ្យសម្ព័ន្ធមិត្ត ។ ឧទាហរណ៍ រដ្ឋាភិបាលបានបញ្ជូនមនុស្សទៅប្រមូលគ្រឿងយន្តជប៉ុន ហើយមនុស្សមួយចំនួនបានយករថយន្តទុកសម្រាប់ខ្លួនឯងដើម្បីលក់យកលុយ ។ ស៊ឹមខុន បាននិយាយថា គាត់បានទៅប្រមូលឃ្លាំងសម្លៀកបំពាក់ធំមួយរបស់ជប៉ុននៅស៊ីផាយ៉ា ប៉ុន្តែគាត់យកបានតែសម្លៀកបំពាក់មួយចំនួនតូចប៉ុណ្ណោះ ។ ប្រាក់ខែរបស់គាត់ច្រើនបំផុតគឺ១៥០បាតក្នុងមួយខែ ប៉ុន្តែវាជាការងារបណ្តោះអាសន្នប៉ុណ្ណោះ ហើយមិនយូរប៉ុន្មានក៏បានបញ្ចប់ទៅ ។

ឆ្នាំ១៩៤៧ គឺជាពេលដែលគាត់បានចូលរួមបក្សកុម្មុយនីស្តថៃ ។ មនុស្សដែលណែនាំគាត់ឲ្យចូលក្នុងបក្សមានដូចជា ឧត្តម ស៊ីសុវ៉ាន និងមិត្តភក្តិរួមថ្នាក់របស់គាត់នៅឯសាលាសួនកុលាប និងជាមិត្តភក្តិជិតស្និទ្ធរបស់គាត់ រួម វង់ផាន ។ ស៊ឹមខុន បាននិយាយថា ឧត្តម អាចពន្យល់រាល់បញ្ហាទាំងឡាយទាក់ទងនឹងទ្រឹស្តីម៉ាកស៊ីស ហើយការវិភាគដ៏ឈ្លាសវៃរបស់គាត់ទៅលើកូខណ្ឌផ្សេងៗនាំឲ្យគាត់ទទួលបានការគោរពដ៏ខ្ពង់ខ្ពស់ពីសំណាក់បញ្ញវន្ត ។ អត្ថបទទាំងឡាយនៅក្នុងសារព័ត៌មាន មហាជន ដែលមានទ្រឹស្តីមួយចំនួនត្រូវបានសរសេរឡើងដោយគាត់ ។ ស៊ឹមខុន បាននិយាយថា គាត់ទទួលឥទ្ធិពលខ្លាំងពី ឧត្តម ស៊ីសុវ៉ាន ។ គាត់ក៏ទទួលឥទ្ធិពលពីស្នាដៃរបស់ ប្រាសិទ្ធិ សាបសុនថុន ដែលមានចំណងជើងថា ទស្សនៈនៃជីវិត ។ ស៊ឹមខុន បាននិយាយថា គាត់ជាមនុស្សនៅក្នុងខ្សែរបស់ ឧត្តម ស៊ីសុវ៉ាន ។ សមាជិកបក្សម្នាក់គួរតែមានសកម្មភាពក្បៀវក្លានៅត្រឹមតែខ្សែដែលខ្លួនប្រកាន់យកប៉ុណ្ណោះ ហើយវាជាការផ្ទុយពីបទបញ្ជារបស់បក្សក្នុងការព្យាយាមស្វែងរកការងារនានានៅក្នុងខ្សែផ្សេងទៀត ។ មនុស្សពីរនាក់គត់នៅក្នុងសមាជិកបក្សកុម្មុយនីស្តដែលគាត់មានទំនាក់ទំនងជាមួយគឺ ឧត្តម និង រួម ។

ស៊ឹមខុន ក៏បាននិយាយអំពីសន្និសីទយុវជនប្រជាធិបតេយ្យអន្តរជាតិដែលប្រារព្ធធ្វើនៅទីក្រុងបាងកកក្នុងខែកញ្ញា ឆ្នាំ១៩៤៧ ដែរ (ការគូសបញ្ជាក់ក្នុងចំណុចនេះត្រូវបានលើកឡើងនៅខាងដើម ហើយនៅត្រង់ចំណុចនេះ គាត់គ្រាន់តែបញ្ជាក់ថាអង្គការយុវជនថៃត្រូវបានបង្កើតឡើងក្នុងអំឡុងពេលប្រហាក់ប្រហែលគ្នានេះដែរ ហើយថាគាត់មិនមានទំនាក់ទំនងមិត្តភាពអ្វីជាមួយ រុងឡឹត ឡៅឌី នេះទេ) ។

នៅចុងបញ្ចប់នៃការធ្វើការងារនៅឯការិយាល័យទំនាក់ទំនងនៃកងទ័ពសម្ព័ន្ធមិត្តរបស់រដ្ឋាភិបាល ស៊ឹមខុន បានចូលប្រឡងធ្វើការនៅនាយកដ្ឋានជម្រះបញ្ជីទូទៅរបស់ក្រសួងហិរញ្ញវត្ថុ និងនៅធនាគារថៃ ។ ប្រធាននាយកដ្ឋានជម្រះបញ្ជីទូទៅក៏ធ្លាប់បានបង្រៀននៅសកលវិទ្យាល័យធម្មសាត្រដែរ ។ គាត់ចូលចិត្តនិស្សិតនៅសកលវិទ្យាល័យធម្មសាត្រ ដូច្នេះហើយគាត់ក៏ព្រមទទួល ស៊ឹមខុន ឲ្យធ្វើការ ។ បន្ទាប់ពីគាត់បានចាប់ផ្តើមធ្វើការនៅនាយកដ្ឋានជម្រះបញ្ជីទូទៅនៅក្នុងការិយាល័យគណនេយ្យ ស៊ឹមខុន បាននិយាយថា រុងឡឹត ក៏ត្រូវបានទទួលឲ្យធ្វើការនៅក្នុងនាយកដ្ឋានដូចគ្នា ហើយធ្វើការនៅក្នុងការិយាល័យតែមួយ ។ ដូច្នេះហើយអ្នកទាំងពីរក៏បានក្លាយទៅជាសហការីនឹងគ្នា ។ រុងឡឹត មានពណ៌សម្បុរស្បែកជ្រះ ហើយជាមនុស្សម្នាក់មានអត្តចរិតល្អទៀតផង ។ អ្នកទាំងពីរបានធ្វើការជាមួយគ្នានៅក្នុងការិយាល័យតែមួយនៃក្រសួងហិរញ្ញវត្ថុអស់រយៈពេលមួយឆ្នាំ ហើយក្នុងអំឡុងពេលមួយឆ្នាំនោះ ស៊ឹមខុន បាននិយាយថា គ្មានមិត្តភក្តិណាផ្សេងទៀតដែលគាត់មានភាពជិតស្និទ្ធនោះទេ ។ អ្នកទាំងពីរនៅជាមួយគ្នាដូចមិត្តភក្តិតាំងពីកុមារភាពមកអ៊ីចឹង ។ នៅកន្លែងណាដែលអ្នកទាំងពីរទៅដល់ និងអ្វីដែលអ្នកទាំងពីរធ្វើ គឺអ្នកទាំងពីរធ្វើជាមួយគ្នា ។ អ្នកទាំងពីរបរិភោគអាហារជាមួយគ្នាជារៀងរាល់ថ្ងៃ ។ ស៊ឹមខុន ស្នាក់នៅក្នុងវត្តរ៉ាក់ខាង ប៉ុន្តែគាត់និយាយថា គាត់ក៏បានទៅស្នាក់នៅឯនិវេសនដ្ឋានរបស់អាចារ្យនៅវត្តបិណ្ឌចាម៉ាបូពិតជាទីកន្លែងដែល រុងឡឹត កំពុងស្នាក់នៅ ។ រុងឡឹត បានចាយលុយ

ច្រើនដាងគាត់ ដូច្នេះហើយ រ៉ុងឡឺត ផ្តល់អាហារឲ្យគាត់ ។ រ៉ុងឡឺត និយាយភាសាបារាំងបានល្អ ហើយ ស៊ុមខ្វាន បានព្យថានៅក្នុងការប្រឡងភាសាបារាំងដើម្បីចូលរៀនវគ្គត្រៀមនៅសកលវិទ្យាល័យធម្មសាត្រ រ៉ុងឡឺត បានទទួលពិន្ទុយ៉ាងល្អទៀតផង ។ គាត់ក៏មានចំណាប់អារម្មណ៍ខ្លាំងនៅក្នុងការរៀនភាសាបារាំង ហើយគាត់បានព្យាយាមនិយាយជាមួយ រ៉ុងឡឺត ជាភាសាបារាំង ។ ការសន្ទនារបស់អ្នកទាំងពីរមានលក្ខណៈចម្រុះគ្នាទាំងភាសាថៃនិងភាសាបារាំង ។ អ្នកទាំងពីរអានសារព័ត៌មាន មហាជន ទាំងអស់គ្នាដែលដាក់លក់ជាសាធារណៈនាពេលនោះ ។ អ្នកទាំងពីរបានអានអត្ថបទសរសេរដោយ ឧត្តម ស៊ីសុវ៉ាន ដោយធ្វើការពិភាក្សាលើបញ្ហានិងគំនិតដែលអ្នកទាំងពីរបានអាន ។ ក្នុងនាមជាជនជាតិកម្ពុជាមួយរូប លក្ខណៈជាតិនិយមរបស់ រ៉ុងឡឺត ចំពោះប្រទេសមានលក្ខណៈរឹងមាំ ហើយគាត់មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើបញ្ហានៃភាពក្រីក្រ និងភាពឯករាជ្យរបស់ប្រទេសកម្ពុជាពីបារាំង ។

ស៊ុមខ្វាន បានធ្វើអត្ថាធិប្បាយថា អំឡុងពេលនោះ គាត់និង រ៉ុងឡឺត នៅជាមួយគ្នា ហើយ រ៉ុងឡឺត មិនមានការទាក់ទងជាមួយ រួម វង់ផាន ឡើយ ។ នៅពេល រួម ត្រូវបានបញ្ជូនទៅប្រទេសចិន (នៅខែឧសភា ឆ្នាំ១៩៤៩ ជាមួយក្រុមដំបូងរបស់សមាជិកបក្សដែលបក្សកុម្មុយនីស្តបញ្ជូនទៅប្រទេសចិន) គាត់ក៏បានលាឈប់ពីការងារជានាយកសាលាចិន ឈី គួង ហើយ ស៊ុមខ្វាន បាននិយាយថា គាត់ក៏បានកាន់មុខតំណែងនោះជំនួសវិញ ។ គាត់បានលាឈប់ពីការងាររបស់គាត់ជា សាមៀន (ស្មៀនសាមញ្ញម្នាក់ដែលធ្វើការនៅក្នុងការិយាល័យរបស់រដ្ឋាភិបាល) នៅក្រសួងហិរញ្ញវត្ថុ ដែលប្រាក់ខែរបស់គាត់នាពេលនោះគឺត្រឹមតែ៣៥បាតប៉ុណ្ណោះក្នុងមួយខែ ប៉ុន្តែនៅប្រសើរជាងប្រាក់ខែដំបូងរបស់គាត់នៅពេលចាប់ផ្តើមត្រឹមតែ២៤បាត ។ បន្ទាប់ពីផ្លាស់ទៅសាលាចិន ឈី គួង គាត់ទទួលបានប្រាក់ខែ២០០បាតក្នុងមួយខែ ។ បន្ទាប់ពីចាកចេញពីក្រសួងហិរញ្ញវត្ថុ ស៊ុមខ្វាន បាននិយាយថា គាត់គ្មានឱកាសដើម្បីជួបជាមួយ រ៉ុងឡឺត ឡើយ ។ គាត់បម្រើការងារជានាយកសាលាប្រហែលជា២ឆ្នាំ ប៉ុន្តែការភ័យខ្លាចកាន់តែខ្លាំងឡើងអំពីការចាប់ខ្លួននៅក្នុងការបង្ក្រាបទៅលើកុម្មុយនីស្តបាននាំឲ្យគាត់ទទួលយកការងារថ្មីមួយទៀតនៅខេត្ត សាកន ណាខុន ជាគ្រូបង្រៀននៅសាលាដែលមាន ទៀង ស៊ិរិខាន់ (ពីមុនជាមន្ត្រីខុទ្ទកាល័យ) ជាម្ចាស់ ។ តាមពិត ទៀង មិនមែនមានតែសាលាមួយទេ គឺគាត់មានសាលាជាច្រើននៅក្នុងស្រុកផ្សេងៗនៅក្នុងខេត្ត សាកន ណាខុន ហើយ ស៊ុមខ្វាន បាននិយាយថា គាត់បានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀតដើម្បីបង្រៀនភាសាអង់គ្លេស ។ នៅឆ្នាំ១៩៥២ បក្សបានបញ្ជូនគាត់ទៅប្រទេសចិន ដែលគាត់បានស្នាក់នៅទីនោះអស់រយៈពេល៣-៤ឆ្នាំ បន្ទាប់មកទើបវិលត្រឡប់មកប្រទេសថៃវិញ ។

បន្ទាប់ពីវិលត្រឡប់មកវិញ គាត់បានធ្វើការជាគ្រូបង្រៀនភាសាអង់គ្លេសនៅសាលាមធ្យមសិក្សានាទីក្រុងបាងកក ខណៈពេលបន្តសកម្មភាពកិច្ចការបក្សកុម្មុយនីស្តរបស់គាត់ ។ គាត់ធ្វើដំណើរយ៉ាងទៀងទាត់ទៅកាន់ ណាខន រាជសីមា ដែលជាខេត្តកំណើតមូលដ្ឋានរបស់បក្សនាពេលនោះ ។ សមាជលើកទី៣របស់បក្សកុម្មុយនីស្តថៃនៅប្រទេសថៃឆ្នាំ១៩៦១ មិនមានការប្រមូលផ្តុំមនុស្សច្រើនឡើយ ។ ស៊ុមខ្វាន បានចូលរួមប្រជុំនៅ សាខន រាជសីមា ដែលមានតែអ្នកចូលរួមបីនាក់ប៉ុណ្ណោះ ។ នៅឆ្នាំ១៩៦៧ គាត់ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ។ ពួកគេត្រូវបានក្បត់ដោយមិត្តជិតស្និទ្ធម្នាក់ ហើយមានមនុស្សជាង១០០នាក់ដែលជាប់ទាក់ទងនឹងបក្សកុម្មុយនីស្តថៃត្រូវបានចាប់ខ្លួន ហើយ ស៊ុមខ្វាន គឺជាមនុស្សម្នាក់ក្នុងចំណោមនោះ ។ ប៉ូលិសធ្វើទារុណកម្មគាត់ ប៉ុន្តែជីដូនមួយរបស់គាត់ដែលជាកូនប្រុសរបស់ប្អូនស្រីខាងម្តាយគាត់គឺជានាយកសាលាបណ្ឌិតសភាយោធានៅជូឡាចោមក្លាវ ដែលជាសាលាបណ្តុះបណ្តាលមន្ត្រីកងទ័ព ។ ដោយសារមានតំណែងសំខាន់នេះ គាត់បានទូរស័ព្ទទៅឲ្យប៉ូលិស ហើយ ស៊ុមខ្វាម បានរួចផុតពីការធ្វើទារុណកម្ម ។ ទីបំផុត គាត់បានជាប់ពន្ធនាគាររយៈពេល៥ឆ្នាំ ។ បន្ទាប់ពីការដោះលែង គាត់បានបើកហាងថ្នាំនៅទីក្រុងរ៉ាយុងភាគខាងកើតប្រទេសថៃដែលស្ថិតនៅលើឈូងសមុទ្រថៃ ។ ម្តាយខាងប្រពន្ធគាត់រស់នៅទីនោះ ហើយគាត់បានចូលប្រឡូកក្នុងជំនួញនៅទីនោះរហូតដល់ពេលថ្មីៗនេះ ។ គាត់ក៏បានធ្វើការជាទីប្រឹក្សាឲ្យអភិបាលក្រុងនោះផងដែរ ។ គាត់មានកូន៤នាក់ ដែលពីរនាក់កំពុងសិក្សានៅសហរដ្ឋអាមេរិក ហើយម្នាក់ក្នុងចំណោមនេះបានប្រកបរបររកស៊ីខាងប្រព័ន្ធអ៊ិនធឺណែត ។

អត្ថាធិប្បាយរបស់ ស៊ុមខ្វាន អំពីពេលរបស់គាត់នៅនាយកដ្ឋានជម្រះបញ្ជីទូទៅ គាត់បានធ្វើការនៅនាយកដ្ឋាននោះរួចទៅហើយនៅពេលដែល វុងឡឹត ត្រូវបានទទួលឲ្យធ្វើការងារ ។ អ្នកទាំងពីរ បានក្លាយជាមិត្តជិតស្និទ្ធយ៉ាងខ្លាំង ហើយធ្វើការជាមួយគ្នានៅក្នុងផ្នែកតែមួយអស់រយៈពេល១ឆ្នាំ រហូតដល់ ស៊ុមខ្វាន ឈប់ធ្វើការក្នុងរវាងខែឧសភា ឆ្នាំ១៩៤៩ ។ ស៊ុមខ្វាន ក៏បាននិយាយផងដែរថា នៅពេលមានសន្និសីទយុវជនប្រជាធិបតេយ្យអន្តរជាតិនៅខែកញ្ញា ឆ្នាំ១៩៤៧ នៅពេលដែលអង្គការយុវជនថៃត្រូវបានបង្កើត គាត់មិនទាន់បានជួបជាមួយ វុងឡឹត ឡើយ ។ ព័ត៌មាននេះបញ្ជាក់ថា វុងឡឹត បានចាប់ផ្តើមធ្វើការងារនៅនាយកដ្ឋានជម្រះបញ្ជីទូទៅនៅចុងឆ្នាំ១៩៤៧ ឬដើមឆ្នាំ ១៩៤៨ ប្រហែលជារយៈពេល១ឆ្នាំមុនពេល ស៊ុមខ្វាន លាឈប់ពីការងារនៅការិយាល័យ ។

នួន ជា នៅក្នុងបទសម្ភាសន៍បាននិយាយថា រហូតដល់ឆ្នាំ ១៩៥០ គាត់បានបម្រើការងារជាស្មៀនអស់រយៈពេល៣ឆ្នាំ (សាមៀន) នៅនាយកដ្ឋានជម្រះបញ្ជីទូទៅនៅក្រសួងហិរញ្ញវត្ថុ ។ ទោះបីជាគ្មានកំណត់ត្រាផ្លូវការនៅសេសសល់ស្តីពីការងាររបស់គាត់នៅក្រសួងនោះក៏ដោយ ក៏កំណត់ត្រានៅឯក្រសួងការបរទេសថៃដែល វុងឡឹត បានចូលធ្វើការក្រោមបន្ទាប់ពីចាកចេញពីនាយកដ្ឋានជម្រះបញ្ជីទូទៅបញ្ជាក់ថា គាត់បានចូលធ្វើការនៅក្រសួងនៅឆ្នាំ១៩៥០ ប៉ុន្តែមិនមានបញ្ជាក់ខែពិតប្រាកដឡើយ ។ ការរាប់ត្រឡប់មក៣ឆ្នាំក្រោយមានន័យថា គាត់បានចូលធ្វើការនៅក្រសួងហិរញ្ញវត្ថុនៅឆ្នាំ១៩៤៧ ។ ទោះបីយ៉ាងណាក៏ដោយ ស៊ុមខ្វាន មិនបានស្គាល់ វុងឡឹត រហូតដល់មានសន្និសីទយុវជនប្រជាធិបតេយ្យអន្តរជាតិនៅខែកញ្ញា ឆ្នាំ១៩៤៧ ។ ព័ត៌មាននេះបញ្ជាក់ថា វុងឡឹត ប្រហែលជាចាប់ផ្តើមធ្វើការនៅនាយកដ្ឋានជម្រះបញ្ជីទូទៅក្នុងរវាងឆ្នាំ១៩៤៧ នៅពេលដែលគាត់ជានិស្សិតឆ្នាំទី១នៅសកលវិទ្យាល័យ ។ នេះប្រហែលជាមានន័យផងដែរថា គាត់បានលាឈប់ពីការបម្រើរដ្ឋាភិបាលនៅវង្វង់ឆ្នាំ១៩៥០ រយៈពេល៣ឆ្នាំក្រោយមក ។ មានភាពខុសគ្នាដល់ទៅ៦ខែនៅក្នុងការចងចាំរបស់បុរសទាំងពីរនាក់នេះទាក់ទិនទៅនឹងពេលវេលាដែល វុងឡឹត បានចាប់ផ្តើមធ្វើការនៅក្រសួងហិរញ្ញវត្ថុ ប៉ុន្តែបើពិនិត្យមើលទៅឃើញថា ពួកគេកំពុងរំឭកអំពីហេតុការណ៍ដែលកើតឡើងកាលពីជាងកន្លះសតវត្សរ៍មុន ដូច្នេះភាពខុសគ្នានេះមិនមានអ្វីអស្ចារ្យទេ ហើយយើងអាចនិយាយថា នួន ជា គឺជា វុងឡឹត ឡៅឌី ដែលបានចាប់ផ្តើមធ្វើការងារជាមន្ត្រីនៅក្នុងរដ្ឋាភិបាល



លោក គ្លីនថ៍ រិល្មៀមសុន ចែកសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ” ជូនសិស្សានុសិស្ស

ថៃរវាងចុងឆ្នាំ១៩៤៧ និងត្រីមាសទី៣នៃឆ្នាំ១៩៤៨ ។

## ៧) ការចងចាំរបស់ ខុត្តម ចារីនរ៉ាត

នៅក្នុងបទសម្ភាសន៍របស់គាត់ នួន ជា បានលើកឡើងអំពីឈ្មោះសមាជិកបក្សកុម្មុយនីស្តថៃម្នាក់ឈ្មោះ ខុត្តម ដែលធ្វើការជាមួយគាត់នៅការិយាល័យដូចគ្នានៅនាយកដ្ឋានជម្រះបញ្ជីទូទៅនៃក្រសួងហិរញ្ញវត្ថុ ហើយដែលនៅជាមួយគាត់ក្នុងក្រុមតែមួយបន្ទាប់ពី នួន ជា ចូលក្នុងបក្ស ។ មុននេះបន្តិច នៅក្នុងអត្ថបទអ្នកនិពន្ធបានពន្យល់អំពីថាតើគាត់សន្និដ្ឋានចំពោះមនុស្សនេះថាជា ចារីនរ៉ាត យ៉ាងម៉េច ហើយក្នុងចំណោមអតីតសមាជិកបក្សទាំងអស់ដែលផ្តល់ឈ្មោះដោយ នួន ជា ខុត្តម គឺជាមនុស្សដែលត្រូវបានសម្ភាសន៍ដំបូងយ៉ាងម៉េច ។

នៅពេលបទសម្ភាសន៍ចាប់ផ្តើម ខុត្តម បញ្ជាក់អំពីកម្រិតភ្ញាក់ផ្អើលនៅពេលដែលដឹងថា រុងឡឹត នៅរស់នៅឡើយ ។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើងនៅខែមេសា ឆ្នាំ១៩៧៥ គាត់បាននិយាយថា គាត់បានគិតដល់ រុងឡឹត ហើយបានសាកសួរ ភិន បួអុន (១៩៣១-១៩៩៩) ដែលជាតស៊ូរជនសំខាន់នៅក្នុងបក្សកុម្មុយនីស្តថៃ ក្រែងលោបានទទួលដំណឹងអំពី រុងឡឹត ។ ភិន បានប្រាប់ ខុត្តម ថា គាត់បានឮ រុងឡឹត ធ្លាក់ពីលើខ្នងសេះនៅក្នុងព្រៃ ហើយស្លាប់យូរណាស់មកហើយ ។ ខុត្តម បានប្រាប់អ្នកនិពន្ធថា ចម្លើយរបស់ ភិន បង្ហាញថា សូម្បីតែមេដឹកនាំមជ្ឈិមរបស់បក្សកុម្មុយនីស្តថៃមិនបានដឹងទាល់តែសោះថា រុងឡឹត ឡោឌី គឺជា នួន ជា ។

និយាយអំពីការចាប់អារម្មណ៍របស់គាត់ចំពោះ រុងឡឹត ខុត្តម ចងចាំថា រុងឡឹត មិនដូចជា ជនជាតិខ្មែរសាមញ្ញដែលមានសម្បុរខ្មៅឡើយ ដោយសារគាត់មានខ្សែស្រឡាយចិនមានសម្បុរស ។ គាត់មានលក្ខណៈទន់ភ្លន់និងបេះគួរសម ហើយមិនមែនជាប្រភេទមនុស្សដែលអួតអាងអំពីភាពខ្លាំងរបស់ខ្លួនឬអ្វីដែលគាត់មានឡើយ ។ គាត់រស់នៅក្នុងវត្តអស់រយៈពេលយ៉ាងយូរ ដូច្នេះហើយគាត់មិនមែនជាប្រភេទអ្នកដែលសម្លាប់មនុស្សឡើយ ។ ខុត្តម បាននិយាយថា ប្រសិន បើគាត់បានជួប រុងឡឹតម្តងទៀតគាត់ចង់សួរ នួន ជា ថា ហេតុអ្វីបានជាខ្មែរក្រហមប្រព្រឹត្តអំពើប្រល័យពូជសាសន៍បែបនេះ ។

នៅពេលដែលអ្នកនិពន្ធបានសួរទៅ ខុត្តម អំពីការអត្តាធិប្បាយរបស់ នួន ជា ថា (រុងឡឹត) បានចូលបក្សកុម្មុយនីស្តនៅ ព.ស២៤៩៣ (ឆ្នាំ១៩៥០) ខុត្តម បានឆ្លើយតបវិញថា «ត្រឹមត្រូវហើយ ។ ការចងចាំរបស់ រុងឡឹត ល្អណាស់ ។ មិនអីចឹង?» ។ ហេតុដូច្នេះហើយ ខុត្តម បានបញ្ជាក់អំពីកាលបរិច្ឆេទដែល នួន ជា បានចូលបក្ស ។

ត្រឡប់ទៅប្រវត្តិផ្ទាល់របស់គាត់វិញ ខុត្តម បាននិយាយថា គាត់កើតនៅក្នុងគ្រួសារកសិករនៅខេត្តអូប៊ុននៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩២៩ ។ បន្ទាប់ពីបញ្ចប់ការសិក្សាឆ្នាំទី៦នៅសាលាមធ្យមសិក្សា គាត់បានចុះឈ្មោះចូលរៀនវគ្គត្រៀមនៅសកលវិទ្យាល័យធម្មសាត្រនៅថ្នាក់បញ្ចប់ជំនាន់ទី៨ ។ គាត់បាននិយាយថា បងប្រុសរបស់គាត់ក៏បានសិក្សានៅសកលវិទ្យាល័យធម្មសាត្រដែរ ហើយប្តីប្អូនស្រីរបស់គាត់ជាអ្នកការទូតផ្នែកការបរទេសថៃ ។ បន្ទាប់ពីបញ្ចប់វគ្គត្រៀម គាត់បានចុះឈ្មោះចូលរៀននៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៤៨ ។ អំឡុងពេលនៃការប៉ុនប៉ងធ្វើរដ្ឋប្រហាររបស់ ព្រីឌី នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៤៩ និងខណៈពេលធ្វើការសិក្សានៅសកលវិទ្យាល័យ ខុត្តម ទទួលបានការងារមួយជា សាមៀន ដែលជាស្មៀនរដ្ឋាភិបាលជាន់ទាបបំផុតនៅក្នុងការិយាល័យគណនេយ្យ (គង់ ថាណាធិការ) នៅនាយកដ្ឋានជម្រះបញ្ជីទូទៅនៃក្រសួងហិរញ្ញវត្ថុ ។ នៅពេលនេះ ខុត្តម បានចង្អុលបង្ហាញថា តំណែងរបស់ សាមៀន គឺជាតំណែងធម្មតាក្នុងរដ្ឋាភិបាលដែលមនុស្សត្រូវបានទទួលឲ្យបម្រើការងារជាមន្ត្រីរដ្ឋាភិបាល ហើយនិងការិយាល័យគណនេយ្យមានការទទួលខុសត្រូវសំខាន់ក្នុងការគ្រប់គ្រងចំណូលនិងចំណាយទៅលើថវិកាជាតិ ។ នៅពេល ខុត្តម បានចាប់ផ្តើមការងារនៅការិយាល័យ រុងឡឹត ធ្វើការនៅទីនោះជា សាមៀន រួចជាស្រេច ។ ពួកគេធ្វើការនៅក្នុងការិយាល័យដូចគ្នាអស់រយៈពេល១ឆ្នាំ រហូតដល់ រុងឡឹត ឈប់ធ្វើការ ហើយផ្លាស់ទៅធ្វើការនៅក្រសួងការបរទេសវិញ ។ ខុត្តម ផ្ទៀងផ្ទាត់របាយការណ៍របស់ នួន ជា ថាអ្នកទាំងពីររួមជាមួយមន្ត្រីទី៣ធ្វើការនៅក្នុងការិយាល័យដូចគ្នាបង្កើតបានជាក្រុមមួយមានមនុស្ស៣នាក់ ។ ខុត្តម បាននិយាយថា គាត់បានអញ្ជើញ រុងឡឹត ដើម្បីចូលរួមក្នុងបក្សនៅឆ្នាំ១៩៥០ ខណៈពេលអ្នកទាំងពីរកំពុងធ្វើការនៅនាយកដ្ឋាន

ជម្រះបញ្ជីទូទៅ ។ គាត់ខ្លួនឯងជាមេដឹកនាំក្រុម (ហួណា នួយ) ខណៈពេលដែល រុងឡឺត គឺជាសមាជិកក្រុម (លូក នួយ) ។ សមាជិកទីពាវងចាស់ជាងបន្តិចដែល ខត្តម បានសន្និដ្ឋានថាឥឡូវ (ឆ្នាំ ២០០៣) គាត់ប្រហែលជាមានអាយុ៨០ឆ្នាំហើយ ។ គាត់ចង់រក្សាភាពអាណាមិករបស់មនុស្សនោះ ដោយគ្រាន់តែនិយាយថាមិនមែនជា ស៊ុមខុន ភិនែគុល ឡើយ ។ ទោះបីជា ស៊ុមខុន ធ្វើការនៅក្នុងនាយកដ្ឋានជម្រះបញ្ជីទូទៅក៏ដោយ ក៏គាត់នៅក្នុងក្រុមផ្សេងគ្នាដែរ ។ ក្រោយមកគាត់បានក្លាយជានាយកសាលាចិន ។ និស្សិតសកលវិទ្យាល័យធម្មសាត្រម្នាក់ទៀតធ្វើការនៅនាយកដ្ឋានជម្រះបញ្ជីទូទៅមានឈ្មោះ សំផាត ភុងប្រាឌិត ដែលក្រោយមកក្លាយជាសមាជិកបក្សកុម្មុយនីស្ត ហើយទីបំផុតបម្រើការងារនៅក្នុងគណៈកម្មការមជ្ឈិមបក្ស ។

ខត្តម បានលើកឡើងអំពីរបៀបយ៉ាងម៉េចបន្ទាប់ពីប្រឡងជាប់នៅក្រសួងការបរទេស ហើយធ្វើការងារនៅទីនោះ រុងឡឺត ឈប់ធ្វើការប្រហែល១ខែក្រោយមក ហើយវិលត្រឡប់មកប្រទេសកម្ពុជាវិញ ។

ខត្តម ក៏បាននិយាយដែរថា រុងឡឺត បានប្រាប់គាត់អំពីសាច់ញាតិជនជាតិខ្មែរនៅខេត្តខ្មែរសូរិន្ទ ដែលសកម្មជាមួយខ្មែរឥស្សរៈ បន្ទាប់មកក៏បានបន្ថែមថា គាត់ខ្លួនឯងបានរស់នៅអស់រយៈពេលប្រហែល៦ខែជាមួយជនជាតិវៀតណាមដែលទទួលបន្ទុករាល់សកម្មភាពកុម្មុយនីស្តនៅកម្ពុជា ។ គាត់មិនអាចរំឭកឈ្មោះមនុស្សនោះឡើយ ប៉ុន្តែគាត់បានគិតថា ប្រសិនបើគាត់អាចជួបនិងនិយាយជាមួយ រុងឡឺត អំពីមនុស្សនោះ គាត់ (រុងឡឺត) នឹងដឹងភ្លាមថាគាត់នោះជានរណា ដែល រុងឡឺត បានទាក់ទងជាមួយមេដឹកនាំសកម្មភាពកុម្មុយនីស្តកម្ពុជាតាមរយៈសាច់ញាតិដែលរស់នៅប្រទេសកម្ពុជា ។ មេដឹកនាំនេះបានធ្វើការទាក់ទងនឹងជនកុម្មុយនីស្តវៀតណាម ។ ខត្តម បានគិតថា តាមរយៈការទាក់ទងជាមួយមេដឹកនាំរូបនេះហើយទើបធ្វើឲ្យ រុងឡឺត លេចមុខឡើងតាមរយៈអង្គការកុម្មុយនីស្ត ។ គាត់បានកត់សម្គាល់ថា ខណៈពេលរស់នៅប្រទេសថៃរហូតដល់ឆ្នាំ១៩៥០ ការយល់ដឹងរបស់ រុងឡឺត ទៅលើទ្រឹស្តីកុម្មុយនីស្តនៅទាបនៅឡើយ ។ សៀវភៅរបស់ ប្រាសិទ្ធិ សាបសុនថុន ដែលមានចំណងជើងថា ទស្សនៈនៃជីវិត ប៉ុន្តែសៀវភៅនេះបានបង្កឲ្យមានបញ្ហាហើយមិនមែនជាស្នាដៃបែបទ្រឹស្តីឡើយ ។ ដើម្បីទទួលបានការយល់ដឹងខ្ពស់ទៅលើទ្រឹស្តី សមាជិកបក្សត្រូវបានបញ្ជូនទៅសិក្សានៅប្រទេសចិន ។ ដូច្នេះហើយគ្មានផ្លូវណាដែល រុងឡឺត អាចទទួលបាននូវកម្រិតនៃការយល់ដឹងអំពីទ្រឹស្តីកុម្មុយនីស្តនៅក្នុងប្រទេសថៃឡើយ ។ អ៊ីចឹងហើយ ខត្តម សន្និដ្ឋានថា រុងឡឺត បានទទួលការបណ្តុះបណ្តាលនៅប្រទេសវៀតណាមដើម្បីធ្វើឲ្យប្រសើរឡើងនូវចំណេះដឹងផ្នែកទ្រឹស្តីរបស់គាត់ ។

បន្ទាប់ពី រុងឡឺត បានវិលត្រឡប់ទៅប្រទេសកម្ពុជា ខត្តម បាននិយាយថា គាត់ត្រូវបានបញ្ជូនទៅប្រទេសចិន ។ បន្ទាប់ពីវិលត្រឡប់មកប្រទេសថៃនៅឆ្នាំ១៩៥៧ ទស្សនៈរបស់គាត់បានផ្លាស់ប្តូរពីអ្នកទាំងឡាយដែលនៅក្នុងបក្សកុម្មុយនីស្តថៃ ដូច្នេះហើយគាត់បានលាឈប់ពីបក្ស ។ គាត់បានចូលសកលវិទ្យាល័យធម្មសាត្រហើយបញ្ចប់ការសិក្សានៅឆ្នាំ១៩៦៤ ។

### ៨) នួន ជា ត្រូវបានរកឃើញនៅក្នុងប្រវត្តិរូបនិស្សិតនៅសកលវិទ្យាល័យធម្មសាត្រ

រុងឡឺត ឡៅឌី បានចូលថ្នាក់បញ្ចប់ជំនាន់ទី៧នៃវគ្គត្រៀមនៅសកលវិទ្យាល័យធម្មសាត្រក្នុងអំឡុងពាក់កណ្តាលឆ្នាំដំបូងនៃឆ្នាំ១៩៤៤ ។ ត្រឹមកាលបរិច្ឆេទនេះ លក្ខណៈសង្គ្រាមកាន់តែលំបាកយ៉ាងខ្លាំង ។ សម្ព័ន្ធមិត្តបានបង្កើនការវាយប្រហារតាមផ្លូវអាកាសទៅលើទីក្រុងបាងកកកាន់តែខ្លាំងឡើង ។ នៅពេលនេះដែរ ចលនាថៃសេរីក៏ចាប់ផ្តើមសកម្មភាពប្រឆាំងនឹងជប៉ុន ។ ហេតុផលទាំងនេះប៉ះពាល់ដល់ប្រតិបត្តិការរបស់សកលវិទ្យាល័យ ។ យោងតាម ខត្តម ចារើនវ៉ាត ដែលស្ថិតនៅក្នុងថ្នាក់បញ្ចប់នៃវគ្គត្រៀមជំនាន់ទី៨ ថ្នាក់បញ្ចប់ជំនាន់ទី៧នៅតែបង្រៀនធម្មតារយៈពេលប្រហែល១ខែប៉ុណ្ណោះ ។ ដោយធ្វើអត្ថាធិប្បាយស្រដៀងគ្នាលេខចេញផ្សាយស្តីពីបុណ្យសពរបស់ ប្រាមួន សាជាវ៉ាស៊ូ (១៩២៧-២០០២) អតីតរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនិងជាសិស្សរួមជំនាន់ជាមួយ រុងឡឺត នៅថ្នាក់បញ្ចប់វគ្គត្រៀមជំនាន់ទី៧ បានសរសេរថា ប្រាមួន បានចូលថ្នាក់បញ្ចប់នៃវគ្គត្រៀមជំនាន់ទី៧នៅសកលវិទ្យាល័យធម្មសាត្រ ប៉ុន្តែភាពធ្ងន់ធ្ងរបានកើនឡើងហើយសាលារៀនត្រូវបានបិទទ្វារដោយទុកឲ្យសិស្សគ្មានទីពំនាក់

ជាជាងការសិក្សាធ្វើឡើងតាមរយៈប្រៃសណីយ៍ ។

ទោះបីយ៉ាងនេះក៏ដោយ នៅឆ្នាំបន្ទាប់មកគឺឆ្នាំ១៩៨៥ សិស្សនៃវគ្គសិក្សាថ្នាក់ត្រៀមជំនាន់ទី៧អាចឈានដល់ឆ្នាំសិក្សាទីពីររបស់ខ្លួន ។ វគ្គសិក្សាថ្នាក់ត្រៀមនៅសកលវិទ្យាល័យធម្មសាស្ត្រ ដែល បញ្ជីរាយនាមថ្នាក់បញ្ចប់ជំនាន់ទី៧-ឆ្នាំទី២ (១៩៨៥-១៩៨៦) ត្រូវបានរៀបចំឡើងដោយនៅក្នុងបណ្ណសារសកលវិទ្យាល័យបង្ហាញថា សិស្សត្រូវបានបែងចែកជា២៨ថ្នាក់ ហើយឈ្មោះ វុងឡឹត ឡេវឌី ស្ថិតនៅខាងលើគេនៃបញ្ជីរាយនាមថ្នាក់លេខ៩ (ហុង៩) ។

នៅពេលអ្នកនិពន្ធលើកឡើងនូវចំណុចនេះទៅកាន់ ឧត្តម គាត់បានអត្ថាធិប្បាយថា «អ៊ីចឹងមែនហើយ ប៉ុន្តែពិន្ទុរបស់ វុងឡឹត ស្ថិតនៅក្នុងចំណាត់ថ្នាក់ល្អ» ។ និស្សិតរៀនថ្នាក់ត្រៀមនៅសកលវិទ្យាល័យធម្មសាស្ត្រត្រូវបានបែងចែកតាមចំណាត់ថ្នាក់ដោយចាប់ផ្តើមពីចំណាត់ថ្នាក់លេខ១ ហើយបន្តតាមលេខរៀងចុះមកក្រោម ។ ថ្នាក់ដែលមានមនុស្សកាន់តែតិចចំណាត់ថ្នាក់របស់សិស្សនៅក្នុងថ្នាក់កាន់តែខ្ពស់ ។ បន្ទាប់ពីបញ្ចប់វគ្គត្រៀមនៅសកលវិទ្យាល័យធម្មសាស្ត្រនៅពាក់កណ្តាលឆ្នាំ១៩៨៦ វុងឡឹត បានចុះឈ្មោះចូលរៀនផ្នែកច្បាប់នៅក្នុងសកលវិទ្យាល័យនោះ ។ ការត្រួតពិនិត្យនៅក្នុងបណ្ណសារដ្ឋានរបស់សកលវិទ្យាល័យមានចំណងជើងថា «បញ្ជីរាយនាមវគ្គសិក្សាកម្រិតបរិញ្ញារបស់សកលវិទ្យាល័យធម្មសាស្ត្រលេខ១៥០២៦-២០០០០» បានបង្ហាញថាគាត់បានចុះឈ្មោះនៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៨៦ ដែលមានលេខសម្គាល់ខ្លួននិស្សិត១៩៧៧០ ។ កំណត់ហេតុចុះឈ្មោះរបស់គាត់ក៏បានបញ្ជាក់ដែរថា គាត់កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦ ។ គាត់មានអាយុ១៩ឆ្នាំ នៅពេលចុះឈ្មោះចូលរៀន ។ អាសយដ្ឋាននៅទីក្រុងបាងកករបស់គាត់គឺលេខ៦៩ស្រុកឌូស៊ិត ។ ឈ្មោះឪពុករបស់គាត់ ប្រាសឺត ម្តាយរបស់គាត់ឈ្មោះ ស៊ុមប៊ុន អាណាព្យាបាលរបស់គាត់ឈ្មោះ ឃុនភីហ្សានខាគិត ។

បណ្ណសារដ្ឋានរបស់សកលវិទ្យាល័យក៏មានកត់ត្រាកំណត់ហេតុលទ្ធផលចំណាត់ថ្នាក់របស់ វុងឡឹត ដែរ ។ គាត់បានចុះឈ្មោះចូលរៀនពីរខែមុនពេលខួបកំណើតគម្រប់អាយុ២០ឆ្នាំ ។ យោងតាមឧត្តម ចារើនវ៉ាត និង ប្រាជួប អាំផាសាវេត ការបញ្ចប់ឆ្នាំសិក្សាចេញពីសកលវិទ្យាល័យធម្មសាស្ត្រ ត្រូវការរយៈពេល៣ឆ្នាំយ៉ាងតិច ។ ទោះបីយ៉ាងណាក៏ដោយ វគ្គសិក្សាដែលនិស្សិតម្នាក់ៗត្រូវឆ្លងកាត់រៀងរាល់ឆ្នាំត្រូវបានកំណត់ដោយសកលវិទ្យាល័យ ហើយនិស្សិតម្នាក់ៗមិនអាចឈានទៅឆ្នាំបន្ទាប់បានទេ លុះណាតែនិស្សិតម្នាក់ៗបានបំពេញតាមវគ្គសិក្សាដែលតម្រូវជាចំបាច់សម្រាប់ឆ្នាំខាងមុខ ។ មនុស្សទាំងពីរនាក់នេះបានកត់សម្គាល់ឃើញថាមាននិស្សិតជាច្រើនដែលរៀននៅសកលវិទ្យាល័យនេះរយៈពេល៣ឆ្នាំ ក៏ប៉ុន្តែមិនអាចប្រឡងបញ្ចប់វគ្គសិក្សាឆ្នាំទី១ ។ អ្នកទាំងពីរក៏បានគូសបញ្ជាក់ថា ចំនួនក្រេឌីតសម្រាប់វគ្គសិក្សានីមួយៗខុសប្លែកពីគ្នាតាមវគ្គសិក្សា ។ ឧទាហរណ៍ វគ្គសំខាន់ៗដូចជាច្បាប់រដ្ឋធម្មនុញ្ញមានចំនួន៣០ក្រេឌីត ក៏ប៉ុន្តែវគ្គសិក្សាខ្លះដូចជាវគ្គសិក្សាអំពីការបោះឆ្នោតតម្រូវឲ្យមានតែ១០ក្រេឌីតប៉ុណ្ណោះ ។ ចំពោះការប្រឡងម្តងៗវិញ និស្សិតត្រូវតែបង់លុយសុំសិទ្ធិប្រឡង ។ តាមពិត នេះជាប្រាក់ចំណូលតែមួយគត់របស់រដ្ឋ ដែលប្រាក់បង់នេះប្រើសម្រាប់ការចំណាយទៅលើថ្លៃសេវាបង្រៀន ។ ថ្លៃឈ្នួលសាលាមានចំនួនខ្ពស់សម្រាប់វគ្គសិក្សាសំខាន់ៗជាងវគ្គសិក្សាដែលមិនសូវសំខាន់ ។ បន្ទាប់ពីបានប្រឡងបញ្ចប់វគ្គសិក្សាទាំងអស់ ការប្រឡងតាមការធ្វើសម្ភាសន៍ត្រូវបានធ្វើឡើងមុនពេលដែលនិស្សិតម្នាក់ៗអាចបញ្ចប់ការសិក្សា ។

ក្នុងអំឡុងឆ្នាំសិក្សាទី១នៅសកលវិទ្យាល័យធម្មសាស្ត្រ វុងឡឹត ត្រូវបានតម្រូវឲ្យរៀនចំនួន៧ ថ្នាក់ដូចខាងក្រោមៈ ចំណេះដឹងជាសារវន្ត បុគ្គលពីធម្មជាតិនិងបុគ្គលច្បាប់ ច្បាប់ឧក្រិដ្ឋកម្មទី១ ច្បាប់រដ្ឋធម្មនុញ្ញ ការបោះឆ្នោត ច្បាប់រៀបចំតុលាការ និងសិទ្ធិជាក់ស្តែង ។ នៅខែតុលា ឆ្នាំ១៩៨៦ គាត់បានធ្វើការប្រឡងជាលើកដំបូង ។ យោងតាមកំណត់ហេតុស្តីពី «ការប្រឡងនៅថៃទី១ ខែតុលា ឆ្នាំ១៩៨៦ លទ្ធផលនៃការប្រឡងផ្នែកសរសេរនិងផ្ទាល់មាត់សម្រាប់និស្សិតកម្រិតបរិញ្ញប័ត្រឆ្នាំទី១» របស់សកលវិទ្យាល័យ វុងឡឹត បានធ្វើការប្រឡងទាំង៧ថ្នាក់ ក៏ប៉ុន្តែជាប់តែពីរថ្នាក់ទេ គឺច្បាប់ឧក្រិដ្ឋកម្មទី១និងច្បាប់រៀបចំតុលាការ ។ ការត្រួតពិនិត្យរបស់អ្នកនិពន្ធទៅលើលទ្ធផលប្រឡងដែលបានកត់ត្រាទុកចំពោះនិស្សិតផ្សេងៗទៀតបានបង្ហាញថា បើទោះបីជាមាននិស្សិតខ្លះបានប្រឡងជាប់រហូតដល់ទៅ៦ថ្នាក់ក៏ដោយ អ្នកទាំងនេះគឺគ្រាន់

តែជាករណីលើកលែងតែប៉ុណ្ណោះ ។ និស្សិតភាគច្រើនបំផុតប្រឡងជាប់តែ២ឬ៣ថ្នាក់ប៉ុណ្ណោះ ។ ដូច្នេះមានន័យថា លទ្ធផលរបស់ រុងឡិត គឺធម្មតា ។ នៅក្នុងការប្រឡងដែលធ្វើឡើងនៅក្នុងខែមករា ឆ្នាំ១៩៨៧ គាត់បានចូលរួមប្រឡង សម្រាប់ថ្នាក់ចំនួន៥ដែលគាត់ធ្លាក់ ក៏ប៉ុន្តែប្រឡងជាប់តែពីរមុខវិជ្ជាប៉ុណ្ណោះ រូបវន្តបុគ្គល នីតិបុគ្គល និងការបោះឆ្នោត ។

១ឆ្នាំក្រោយមក នៅក្នុងការប្រឡងខែមករា ឆ្នាំ១៩៨៨ រុងឡិត បានធ្វើការប្រឡងទៅលើថ្នាក់ដែលនៅសល់ចំនួន៣ទៀត ដោយជាប់បានតែ២មុខប៉ុណ្ណោះ ៖ ចំណេះដឹងជាមូលដ្ឋាននិងច្បាប់រដ្ឋធម្មនុញ្ញ ។ វគ្គសិក្សាឆ្នាំទី១ដែលតម្រូវចាំបាច់នៅសល់ចុងក្រោយគឺសិទ្ធិជាក់ស្តែង ដែលគាត់អាចប្រឡងជាប់នៅខែតុលា ឆ្នាំ១៩៨៨ ។ ចាប់ពីពេលនោះមក គាត់បានចុះឈ្មោះចូលរៀននៅសកលវិទ្យាល័យធម្មសាត្រនៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៨៦ ដែលការណ៍នេះបណ្តាលឲ្យ រុងឡិត ចំណាយពេល២ឆ្នាំកន្លះដើម្បីប្រឡងជាប់វគ្គសិក្សាដែលតម្រូវចាំបាច់ទាំង៧មុខនៅឆ្នាំទី១ ។ គាត់បានចំណាយពេលក្នុងឆ្នាំ១៩៨៧ និងបីត្រីមាសនៃឆ្នាំ១៩៨៨ ដើម្បីបំពេញក្រេឌីតទៅលើវគ្គសិក្សាឆ្នាំទី១ ដែលគាត់បានប្រឡងធ្លាក់ដើម្បីសងវិញនៅឆ្នាំ១៩៨៦ ។

នៅពេលអ្នកនិពន្ធបង្ហាញលទ្ធផលពិន្ទុទាំងនេះទៅ ឧត្តម ការគិតរបស់គាត់គឺថា រុងឡិត ចូលប្រឡូកក្នុងសកម្មភាពនយោបាយ ហើយធ្វើការងារជាមន្ត្រីរដ្ឋាភិបាល អាស្រ័យដូច្នេះហើយ គាត់មានពេលតិចតួចសម្រាប់សិក្សា ។ ឧត្តម យល់ឃើញថា ប្រសិនបើគាត់មានពេលគ្រប់គ្រាន់ដើម្បីសិក្សាទៀងទាត់ គាត់អាចប្រឡងជាប់យ៉ាងឆាប់រហ័សបំផុត ។ ដូចដែលបានពិភាក្សាមុននេះនៅឆ្នាំ១៩៨៧ គឺជាឆ្នាំដែល រុងឡិត បានចូលរួមអង្គការយុវជនថៃដែលដឹកនាំដោយ រួម វង់ផាន បន្ទាប់មកមួយឆ្នាំឬនៅដើមឆ្នាំ១៩៨៨ ដែលគាត់បានចាប់ផ្តើមធ្វើការនៅឯនាយកដ្ឋានជម្រះបញ្ជីទូទៅនៅក្រសួងហិរញ្ញវត្ថុបង្ហាញថា ពេលវេលាជាច្រើនរបស់ រុងឡិត ត្រូវបានចំណាយទៅលើសកម្មភាពផ្សេងៗដែលកាត់បន្ថយទៅលើការសិក្សារបស់គាត់ ។ មានចំណុចមួយទៀតដែលបានលើកឡើងនៅក្នុងបទសម្ភាសន៍របស់គាត់ដែរថា ការអានសារព័ត៌មាន មហាជន បណ្តាលឲ្យគាត់មានមន្ទិលសង្ស័យថា តើហេតុអ្វីបានជាគាត់រៀននៅសកលវិទ្យាល័យធម្មសាត្រ ។ ដូច្នេះហើយនៅឆ្នាំ១៩៨៧ និងឆ្នាំ១៩៨៨ វាហាក់ដូចជាថា រុងឡិត មិនបានស្ថិតនៅក្នុងបរិស្ថានឬមិនមានគំនិតលះបង់ខ្លួនឯងចំពោះការសិក្សាឡើយ ។

**(នៅមានត)**

**អ៊ីជី ម្ញ៉ាស្ទ្រីម៉ា**

---

***(តមកពីទំព័រ៩)***

ដូច្នេះយើងប្រាកដជាក្លាយជាជនប្រឆាំងនឹងបក្សកុម្មុយនីស្តនិងហូជីមិញក្នុងការអនុវត្តគោលនយោបាយ «សហព័ន្ធឥណ្ឌូចិន» ហើយយើងទាំងពីរនាក់នឹងត្រូវដាក់ទណ្ឌកម្មរួម ទាំងគ្រួសាររបស់ខ្ញុំនិង ង៉ៀន វ៉ាន់ង៉ៀ ផងដែរ ។ ក្រោយមក ខ្ញុំក៏សម្រេចចិត្តអនុវត្តន៍តាមបញ្ជារបស់លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន ដើម្បីការពារគ្រួសារខ្ញុំ ។

ក្នុងរយៈពេលស៊ើបយកព័ត៌មាន លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន បានបញ្ជូនកងទ័ពមួយចំនួនឲ្យធ្វើដំណើរអមជាមួយខ្ញុំ ទៅដល់ស្ទឹង អ៊ុង ខួ ជ្រលងភ្នំសាម ។ កងទ័ពវៀតណាមបានឲ្យខ្ញុំចុះពីលើរថយន្ត ហើយតាមមើលខ្ញុំពីក្រោយ ប្រសិនបើខ្ញុំមិនចូលទៅស៊ើបយកព័ត៌មានទេ នោះពួកកងទ័ពទាំងនោះនឹងបាញ់សម្លាប់ខ្ញុំភ្លាម ។ ហេតុដូច្នេះហើយ ខ្ញុំក៏បង្ខំចិត្តចូលទៅស៊ើបយកព័ត៌មានតាមបញ្ជារបស់លោកវរសេនីយ៍ឯក ត្រាន វ៉ាន់លួន ដែលជាមេបញ្ជាការកងពលធំលេខ៧ ។

នៅពេលដែលខ្ញុំបានចូលទៅទឹកដីកម្ពុជាបានប្រហែលប្រាំម៉ែត្រ ដែលស្ថិតនៅក្នុងតំបន់ព្រៃកក្បាលបួន ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ ខ្ញុំក៏ត្រូវបានចាប់ខ្លួនភ្លាមៗដោយកងទ័ពកម្ពុជា ។ ចំណែកឯ ង៉ៀន វ៉ាន់ង៉ៀ ដែលបានធ្វើដំណើរមកជាមួយខ្ញុំ ក៏បានរត់គេច ប៉ុន្តែត្រូវកងទ័ពកម្ពុជាបាញ់សម្លាប់ចោលនៅនឹងកន្លែង ។

ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៨

ហត្ថលេខា ង៉ៀន វ៉ាន់ហ័រ

**ឯកសារ D២៩០៦២**

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា : ចម្ងល់សម្រាប់អ្នកទាំងអស់គ្នា

ការបង្កើត អ.វ.ត.ក ដែលមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាបញ្ហាសំខាន់មួយសម្រាប់ប្រជាជនកម្ពុជានិងអន្តរជាតិ ។ លោក ដេវីដ សេហ៊ុរ និងលោក ឆាំង យុ បានពន្យល់ពីមូលហេតុដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានសារសំខាន់ចំពោះប្រជាជនកម្ពុជា និងសហគមន៍អន្តរ-ជាតិ ។ ការសម្លាប់រង្គាលដែលធ្វើឡើងដោយខ្មែរក្រហមមកលើជនរងគ្រោះកម្ពុជាបានទាក់ទាញការចាប់អារម្មណ៍ពីអ្នកជំនាញខាងយុត្តិធម៌អន្តរកាល ក៏ដូចជាអ្នកវិភាគនយោបាយផងដែរ ។ មតិភាគច្រើនគិតថា តុលាការនឹងនាំមកនូវយុត្តិធម៌ដល់ជនរងគ្រោះ និងបញ្ចប់និទ្ទណ្ឌភាពដោយធ្វើការដាក់ទណ្ឌកម្មទៅលើអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋកម្មដែលគេបានប្រព្រឹត្ត ។ ហេតុផលសម្រាប់ការដាក់ទណ្ឌកម្មនេះ គឺដើម្បីការពារមិនឲ្យអំពើឧក្រិដ្ឋកម្មកើតឡើងសាជាថ្មីម្តងទៀតនៅពេលអនាគត ។ ការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មនេះនឹងក្លាយទៅជាសញ្ញាណរំឭកមួយដល់ជនដែលដល់មួយចំនួន ។ យ៉ាងហោចណាស់ ជនដែលដល់ទាំងនោះអាចនឹងយកចិត្តទុកដាក់ទៅលើវិធានច្បាប់ និងគោរពសិទ្ធិមនុស្ស ។ មានមតិមួយចំនួនទៀតយល់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចផ្តល់ជាគំរូសាកល្បងមួយសម្រាប់ច្បាប់



លោក គ្លីនថ៍ វិល្លៀមសុន និងលោក ឆាំង យុ ចែកសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ជូនសិស្សានុសិស្ស

អន្តរជាតិ ជាពិសេសតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការកូនកាត់ដំបូងបង្អស់នៅក្នុងប្រវត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលមានការចូលរួមពីភាគីខាងកម្ពុជានិងអន្តរជាតិ ហើយចៅក្រមភាគច្រើនជាចៅក្រមកម្ពុជា ។ ទោះជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលបានជោគជ័យត្រឹមតែបន្តិចបន្តួច ក៏គំនិតបង្កើតតុលាការកូនកាត់ដែលមានជនជាតិកម្ពុជាភាគច្រើនអាចនឹងក្លាយជាជម្រើសមួយសម្រាប់កន្លែងដទៃទៀតដែលធ្លាប់ជួបប្រទះស្ថានភាពដូចគ្នានេះនៅពេលអនាគត ។ អ្នកវិភាគនយោបាយនិងច្បាប់មួយចំនួនបានរំពឹងទុកដូចគ្នាមុនថា ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធានាបាននូវភាពយុត្តិធម៌និងអាចគោរពទៅតាមនីតិវិធីច្បាប់ នោះប្រជាជនកម្ពុជានិងសកម្មជនដទៃទៀតក៏អាចពេញចិត្តចំពោះរសជាតិនៃអ្វីដែលថាយុត្តិធម៌និងភាពត្រឹមត្រូវនៅក្នុងតុលាការដែរ ។ នេះអាចនឹងជំរុញឲ្យប្រជាជនកម្ពុជាចង់ធ្វើកំណែទម្រង់ច្បាប់ដើម្បីធានាឲ្យបាននូវភាពត្រឹមត្រូវនិងនីតិវិធីច្បាប់នៅក្នុងតុលាការ ។ ការរំពឹងទុកនេះអាចនឹងទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកគាំទ្រសង្គមស៊ីវិល ក៏ដូចជាសហគមន៍ ម្ចាស់ជំនួយដែលបានជំរុញដំណើរការអភិបាលកិច្ច និងកំណែទម្រង់តុលាការនៅក្នុងរដ្ឋាភិបាលអាណត្តិថ្មី ។ អ្នកវិភាគខ្លះបានទាមទារឲ្យសាលាក្តីខ្មែរក្រហមលាតត្រដាងការពិត ជួយព្យាបាលប្រជាជនដែលមានជំងឺសតិអារម្មណ៍ និងនាំមកនូវការផ្សះផ្សាជាតិនៅទូទាំងប្រទេស ។ អ្នកសិក្សាជាន់ខ្ពស់ខ្លះទៀតបានធ្វើការគិតទុកមុនថា សាលាកាត់ក្តីខ្មែរក្រហមនេះបានត្រឹមតែបម្រើឲ្យល្បែងនយោបាយរវាងក្រុមអ្នកមានអំណាចរបស់កម្ពុជានិងសហគមន៍អន្តរជាតិ ជាពិសេសអង្គការសហប្រជាជាតិប៉ុណ្ណោះ ។ ការពន្យារពេលដ៏យូរនិងការមិនយកចិត្តទុកដាក់គឺជាមូលហេតុនៃការមិនយល់ស្របគ្នា ។ ប្រសិនបើរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិយកចិត្តទុកដាក់ចំពោះការឈឺចាប់របស់ជនរងគ្រោះ ហើយតាំងចិត្តជំរុញឲ្យមានការទទួលខុសត្រូវពីអ្នកដែលបានធ្វើអំពើឃោរឃៅ ហេតុអ្វីបានជាអ្នកទាំងនោះពន្យារពេលរហូតមកដល់បច្ចុប្បន្ន? នេះគឺជាគោលបំណងរបស់សាលាក្តីដែលអាចត្រូវសង្ខេបមកពីការរសម្លឹងមើលថយក្រោយនិងទៅមុខ ។ គោលបំណងនៃការសម្លឹងមើលថយក្រោយ គឺដើម្បីរកឲ្យឃើញពីទោសកំហុសរបស់មេដឹកនាំខ្មែរក្រហមទាំង៥រូបដែលត្រូវទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដែលត្រូវបានចោទប្រកាន់ថាបានសម្លាប់ប្រជាជនច្រើនជាង១,៧លាននាក់ ហើយដំណើរនីតិវិធីរបស់តុលាការនេះអាចបម្រើឲ្យប្រវត្តិសាស្ត្រពិត ។ គោលបំណងនៃការសម្លឹងមើលទៅខាងមុខ គឺដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មកុំឲ្យកើតឡើងម្តងទៀតនៅពេលអនាគតដោយប្រជាជនធ្វើការគោរពវិធានច្បាប់ ។ សិទ្ធិមនុស្សនិងតុលាការឧក្រិដ្ឋកម្មអាចជាគំរូមួយនៃការកាត់ក្តីដ៏យុត្តិធម៌នៅក្នុងប្រព័ន្ធតុលាការកម្ពុជា ក៏ដូចជាប្រទេសដែលទទួលជំនួយពីអន្តរជាតិ ។ យោងទៅលើអត្ថបទពិភាក្សាខាងលើនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហាក់ដូចជាចម្ងល់ពិសេសមួយសម្រាប់អ្នកទាំងអស់គ្នា ។ តើអង្គជំនុំជម្រះនឹងបំពេញគោលបំណងទាំងនេះបានដែរឬទេ?

ជាការពិតណាស់ ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានឆ្លើយតបទៅនឹងការសង្ស័យចំពោះវត្តមាននៃសាលាក្តីមេដឹកនាំខ្មែរក្រហម ។ ទោះបីជាមានការខ្វែងគំនិតគ្នាខ្លះចំពោះអធិបតេយ្យភាពនិងភាពជឿជាក់របស់តុលាការ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបានយល់ស្របបង្កើតតុលាការព្រហ្មទណ្ឌដែលស្ថិតនៅក្រោមច្បាប់កម្ពុជា និងមានការចូលរួមរបស់ចៅក្រមអន្តរជាតិ ។ អតីតមេដឹកនាំខ្មែរក្រហមទាំង៥រូបត្រូវបានចោទប្រកាន់និងឃុំនៅមន្ទីរឃុំឃាំង ។ កាំង ហ្គេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ និងមណ្ឌលទារុណកម្ម គឺជាអ្នកដែលត្រូវបានចោទប្រកាន់ដំបូងដើម្បីយកមកកាត់ទោស ។ ការចាប់ផ្តើមបើកសវនាការដំបូងមុនអង្គជំនុំជម្រះនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ និងនៅសប្តាហ៍បន្ទាប់ទៅលើករណី ឌុច បង្ហាញពីជំហានសំខាន់ដើម្បីឆ្ពោះទៅកាន់ការស្វែងរកយុត្តិធម៌ ។ សហគមន៍កម្ពុជានិងអន្តរជាតិពេញចិត្តនឹងដំណើរការកាត់សេចក្តី ហើយសង្ឃឹមយ៉ាងមុតមាំថា យុត្តិធម៌នឹងត្រូវបានរកឃើញ វប្បធម៌នៃការគ្មានទោសនឹងត្រូវបានជំនួសដោយវប្បធម៌នៃការទទួលខុសត្រូវ ហើយនៅទីបញ្ចប់វិធាននៃច្បាប់នឹងត្រូវបានសម្រេច ។ វិធានផ្ទៃក្នុងនៃនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចត្រូវបានអនុម័ត ។ វិធានផ្ទៃក្នុងអនុញ្ញាតឲ្យ

ជនរងគ្រោះចូលរួមធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធី និងបង្កើតជាអង្គភាពជនរងគ្រោះដែលមានជំនាញមួយ ។ អង្គភាពជនរងគ្រោះនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបង្ហាញឲ្យឃើញពីការអភិវឌ្ឍជាវិជ្ជមានមួយនៅក្នុងមជ្ឈដ្ឋានច្បាប់កម្ពុជានិងអ្វីដែលធ្លាប់មានពីមុនសម្រាប់ជាជំនួយរបស់តុលាការផ្សេងទៀត ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានដើរតួនាទីយ៉ាងសកម្មក្នុងការជំរុញឲ្យជនរងគ្រោះចូលរួមនៅក្នុងដំណើរការតុលាការ ក៏ដូចជាការផ្សព្វផ្សាយពីដំណើរការកាត់ទោសទៅកាន់ប្រជាជន ។

បញ្ហាបច្ចេកទេសនិងបញ្ហាចម្បងនៅតែជាការព្រួយបារម្ភ ។ បញ្ហាបច្ចេកទេសសំដៅទៅលើការខ្វះធនធាន ឆន្ទៈនយោបាយ ធាតុផ្សំច្បាប់ដើម្បីដោះស្រាយសកម្មភាពបទល្មើស សមត្ថភាពរបស់ចៅក្រមកម្ពុជា ការទទួលខុសត្រូវនៅក្នុងអង្គភាព និងបញ្ហាការបកប្រែ ។ល ។ បញ្ហាចម្បងសំដៅទៅលើសមត្ថភាពរបស់ចៅក្រមក្នុងការផ្តល់យុត្តិធម៌ដោយត្រឹមត្រូវនិងការប្រកាន់ខ្ជាប់តាមមូលដ្ឋានគ្រឹះនៃវិធានច្បាប់ ដោយរួមបញ្ចូលភាពឯករាជ្យនៃនយោបាយនិងភាពមិនលម្អៀង ។ បញ្ហាទាំងពីរបានដើរតួនាទីសំខាន់ក្នុងការសម្រេចឲ្យបាននូវភាពជោគជ័យរបស់អង្គជំនុំជម្រះដើម្បីធានាឲ្យមានយុត្តិធម៌ដំណើរការត្រឹមត្រូវនិងការទទួលស្គាល់ដោយសង្គម ។ ការចាប់ផ្តើមដែលពោរពេញដោយឧបសគ្គរបស់អង្គជំនុំជម្រះនិងបញ្ហាតម្លាភាពបានធ្វើឲ្យប្រជាជនមានការអស់សង្ឃឹមចំពោះអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះត្រូវបានបង្កើតឡើងដោយមានជម្លោះរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិចំពោះទស្សនៈយល់ឃើញ និងអធិបតេយ្យភាព បូករួមទាំងការជឿទុកចិត្តបានរបស់តុលាការ ធ្វើឲ្យអង្គការសហប្រជាជាតិដកខ្លួនចេញពីការចរចា ។ អរគុណចំពោះការដាក់សម្ពាធពីអន្តរជាតិនិងការជួយឧបត្ថម្ភរបស់សង្គមស៊ីវិលដើម្បីជំរុញឲ្យភាគីទាំងពីរត្រឡប់មកកាន់ភារកិច្ចរបស់ខ្លួនវិញ ។ ភាពមិនយល់ស្របគ្នាចំពោះធាតុផ្សំនៃច្បាប់ ដែលជាវិធានផ្ទៃក្នុងដែលលើកឡើងពីការចោទប្រកាន់អំពើពុករលួយគឺជាបញ្ហាចម្បង ។ អំពើពុករលួយគឺជាចំណុចទាក់ទាញបំផុត ។ ចាប់ពីឆ្នាំ២០០៧-២០០៨ និងរហូតមកដល់ថ្មីៗនេះ បញ្ហាចោទប្រកាន់អំពើពុករលួយនេះ


លោក ជិតាវ ទន់ សាអ៊ីម និងលោក ឆាំង យុ ចែកសៀវភេ

នៅតែជារឿងលំបាក ហើយមិនទាន់បានដោះស្រាយដែលបង្កឲ្យមានយុទ្ធសាស្ត្រសម្រាប់ដោះស្រាយ គឺដើម្បីធ្វើឲ្យមានតុល្យភាពខាងអំណាច ។ ជាធម្មតា អង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិប្រើប្រាស់ថវិកាបម្រុងធ្វើជាវិធីសាស្ត្ររបស់ខ្លួន ហើយគេអាចដកខ្លួនចេញ ប្រសិនបើគេរកឃើញភាពមិនសមស្រប ។ រដ្ឋាភិបាលកម្ពុជាប្រើប្រាស់វិធីសាស្ត្របែបប្រពៃណីដើម្បីឆ្លើយតបនឹងការគំរាមកំហែងដើម្បីហាមឃាត់អ្នកដែលធ្វើការរិះគន់គំរាមកំហែងបញ្ឈប់តុលាការដោយប្រើអំណាច ហើយថ្មីៗនេះរដ្ឋាភិបាលបានប៉ុនប៉ងនិងបែរបន់ឲ្យតុលាការទទួលបរាជ័យឆាប់ៗទៀតផង ។ បច្ចុប្បន្ន យុទ្ធសាស្ត្រតុល្យភាពនៃអំណាចថ្មីមួយត្រូវបានសម្តែងចេញយ៉ាងច្បាស់នៅពេលដែលរដ្ឋាភិបាលប្រកាសថានឹងធ្វើការពិនិត្យពិច័យចំពោះចៅក្រមនិងបុគ្គលិកអន្តរជាតិពីបញ្ហាអំពើពុករលួយ ។ អរគុណសម្រាប់ការមិនប្រើពាក្យបណ្តឹងបរិហារកេរ្តិ៍ប្រឆាំងនឹងការចោទប្រកាន់ ។ នេះមានន័យថា ការជឿជាក់និងការសហការគ្នាទៅវិញទៅមករវាងអន្តរជាតិនិងកម្ពុជា



...ៗ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ជូនសិស្សានុសិស្ស

ត្រូវបានបែកបាក់ ។ ទាំងនេះបានចោទជាសំណួរចំពោះការប្តេជ្ញាខាងនយោបាយដើម្បីស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ ។

ការស្ទង់មតិ (ឆ្នាំ២០០៤ និង ២០០៩) បង្ហាញថា ប្រជាជនកម្ពុជាចង់បានទម្រង់យុត្តិធម៌និងការពិតខ្លះៗ ទើបគេអាចរស់នៅដោយសន្តិភាពនិងភាពសុខសាន្ត ។ ត្រូវតែមានយុត្តិធម៌ដែលបានមកពីការទាមទារឲ្យអ្នកដែលទទួលខុសត្រូវចំពោះអំពើដ៏សាហាវឃោរឃៅនិងការសងជំងឺចិត្តជាទម្រង់ខ្លះ ។ ប៉ុល ពត, តាម៉ុក, សុន សេន និងអ្នកមួយចំនួនដែលជាជនដៃដល់បានស្លាប់ដោយមិនបានបង្ហាញពីការពិតមួយចំនួនដែលទាក់ទងនឹងរបបនេះ ។ ជនសង្ស័យទាំង៥នាក់ដែលត្រូវបានចោទប្រកាន់ត្រូវបានចាត់ទុកថាជាជនសង្ស័យចុងក្រោយសម្រាប់អាណត្តិរបស់អង្គជំនុំជម្រះដោយផ្អែកទៅលើការវិវត្តខាងផ្នែកនយោបាយថ្មីៗនេះ ។ តាមផ្លូវច្បាប់ ជនជាប់ឃុំឃាំងទាំង៥រូបនេះត្រូវបានចាត់ទុកថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឃោរឃៅដែលបានកើតឡើង ។ ការពន្យារពេលជាបន្តបន្ទាប់នៃដំណើរការបានចោទជាបញ្ហាមួយចំនួនថាតើជនទាំង៥នាក់នោះមានលទ្ធភាពភាពឈរនៅមុខតុលាការស្តាប់សាលក្រមរបស់ខ្លួនដែលឬទេ បើអ្នកទាំងនោះកំពុងប្រឈមមុខនឹងបញ្ហាសុខភាពនិងវ័យចំណាស់របស់ខ្លួន ។ វេជ្ជបណ្ឌិត គិលានុបដ្ឋាយិការ និង រថយន្តសង្គ្រោះបន្ទាន់បានប្រចាំការនៅក្នុងតុលាការរួមទាំងពេលចាប់ផ្តើមសវនាការ ។ នៅពេលដែលជនត្រូវចោទលើកដៃបង្ហាញថាខ្លួនមិនមានកម្លាំងឈរនៅចំពោះការកាត់សេចក្តី មេធាវីនឹងលើកហេតុផលពីបញ្ហាសុខភាពក្នុងពេលសវនាការ ។ អៀង ធីរិទ្ធ ឈឺនៅលើគ្រែនៅពេលដែលអង្គជំនុំជម្រះដំណើរការសវនាការបដិសេធការសុំនៅក្រៅឃុំនៅពេលថ្មីៗនេះ ។ វិធានផ្ទៃក្នុងបានចែងថា ជនរងគ្រោះនឹងទទួលបាននូវ «សំណងជំងឺចិត្តខាងផ្លូវចិត្តនិងជារូម» នៅពេលដែលសាលក្រមរបស់ចៅក្រមត្រូវបានសម្រេច ។ ប៉ុន្តែមេធាវីរបស់ជនរងគ្រោះទាំងអស់មិនយល់ស្របលើការផ្តល់ឲ្យដោយទាមទារឲ្យមានការសងជំងឺចិត្តជាបុគ្គលមិនមែនជាលក្ខណៈជារួមទេ ។ យ៉ាងណាមិញ ដោយសារធនធានមិនគ្រប់គ្រាន់ ហើយជនរងគ្រោះមានចំនួនច្រើន ដំណោះស្រាយនេះត្រូវបានគេទទួលស្គាល់ ។ វិធានផ្ទៃក្នុងក៏បានផ្តល់សិទ្ធិពេញលេញមួយដល់ការចូលរួមពីសំណាក់ជនរងគ្រោះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីមិនមែនគ្រាន់តែហៅមកជាសាក្សីនោះទេ ។ ខណៈពេលដែលបទបញ្ញត្តិនេះយោងតាមបញ្ញវន្តមួយចំនួន ហើយវាខុសប្លែកពីតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតក្នុងព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ការអនុវត្តហាក់បីដូចជាមានភាពខុសប្លែកពីគ្នា ។ ជនរងគ្រោះរាប់ពាន់នាក់បានដាក់សំណុំរឿងរបស់ខ្លួនដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែផ្ទុយទៅវិញមានតែបេក្ខជនមួយចំនួនតូចប៉ុណ្ណោះត្រូវបានទទួលស្គាល់ ។ ការធ្វើបែបនេះអាចកាត់បន្ថយតម្រូវការពិតប្រាកដរបស់ជនរងគ្រោះដែលមិនអាចដោះស្រាយនៅទីបញ្ចប់ ។ យ៉ាងណាមិញ ដោយសារកង្វះខាតធនធាននិងការពិចារណាផ្នែកបច្ចេកទេសដែលមានលក្ខណៈស្របច្បាប់ ការពន្យល់ធ្វើបែបនេះទំនងជាអាចទទួលយកបាន ។ ខណៈពេលដែលគោលបំណងចម្បងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺដើម្បីជួយជនរងគ្រោះ ប៉ុន្តែការស្ទង់មតិមួយបានបង្ហាញថា ៨៥ភាគរយនៃជនរងគ្រោះ

ទាំងអស់មិនមានការយល់ដឹងអ្វីសោះទាក់ទងនឹងដំណើរការរបស់អង្គជំនុំជម្រះ ។ តើយុត្តិធម៌នឹងសម្រេចបានយ៉ាងពេញលេញដែរឬទេ?

ជាសង្ខេប អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាចម្លល់មួយសម្រាប់មនុស្សគ្រប់រូបតំណាងឲ្យទីបញ្ចប់នៃរឿងនយោបាយរវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ ហើយក៏បានផ្តល់នូវគម្រោងការដ៏ចម្លែកតូចមួយសម្រាប់ការមើលត្រឡប់ថយក្រោយនិងការមើលឆ្ពោះទៅមុខ ។ សម្រាប់ជំរំនៃភាពយុត្តិធម៌ យ៉ាងហោចណាស់ជនរងគ្រោះទាំងអស់ទទួលបាននូវ «និមិត្តសញ្ញានៃភាពយុត្តិធម៌» និងការពិតដែលមានភាពលម្អៀង ។ សម្រាប់ជំរំដែលតំណាងឲ្យភាពត្រឹមត្រូវប្រហែលជាអាចទទួលបាននូវក្តីសង្ឃឹមដ៏តិចតួចដែលថាការពង្រឹងសមត្ថភាពនឹងត្រូវបានបំពាក់បំប៉នដល់ចៅក្រមនិងបុគ្គលិកកម្ពុជា ហើយដែលចៅក្រមកម្ពុជានឹងជួបនូវបញ្ហានៅពេលធ្វើការជាមួយចៅក្រមអន្តរជាតិ ។ ប៉ុន្តែសម្រាប់បុគ្គលមួយចំនួនដែលខិតខំស្វែងរកផលប៉ះពាល់នៃបទឧក្រិដ្ឋកម្មនៅថ្ងៃអនាគតនិងការគោរពសិទ្ធិមនុស្សនិងច្បាប់ហាក់បីដូចជាមិនទទួលបាននូវផលប្រយោជន៍អ្វីសោះពីតុលាការដែលផ្តល់ជាកំណត់ត្រាប្រវត្តិសាស្ត្រនៃការអនុវត្តរបស់រាជរដ្ឋាភិបាលបច្ចុប្បន្នដែលស្ថិតនៅក្រោមនយោបាយនៃការផ្តល់ការឧបត្ថម្ភ ។ ចុះចំពោះជនរងគ្រោះកម្ពុជាទាំងអស់ ជាពិសេសជនរងគ្រោះទាំង៨៥ភាគរយដែលមិនមានការយល់ដឹងអ្វីសោះពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តើជនរងគ្រោះទាំងនោះគួរតែមិនរាប់បញ្ចូលក្នុងសេចក្តីពិចារណាដែរឬយ៉ាងណា? ប្រាកដណាស់ គឺមិនមែនទេ ពីព្រោះថាអំពើប្រល័យពូជសាសន៍នេះមានលក្ខណៈធំធេងនិងមិនអាចវាស់វែងបាន ។ បទឧក្រិដ្ឋដែលមានលក្ខណៈធំបែបនេះមិនអាចដោះស្រាយបានដោយតុលាការតែម្នាក់ឯងនោះទេ ទោះបីជាយុត្តិធម៌និងដំណើរការដែលរំពឹងទុកត្រូវបានសម្រេចហើយក៏ដោយ ។

ដូចដែលលោក ចន ភល លីនដឺរិច (១៩៩៧) បានលើកឡើងពីសង្គមដែលត្រូវបានបែងចែកដាច់ដោយឡែកពីគ្នាបានបង្ហាញថា សង្គមណាដែលមានវិបត្តិជ្រៅ ភាពភ័យខ្លាចរយៈពេលយូរនឹងទទួលបានបទពិសោធន៍អំពើហិង្សាដោយផ្ទាល់ដែលរូបភាពរបស់ខ្មាំងសត្រូវស្ថិតនៅឋិតថេរក្នុងចិត្តរបស់គេ ប្រជាជនរបស់សង្គមនោះច្បាស់ជាងាយនឹងទទួលរងនូវការឈឺចាប់និងការបោកបញ្ឆោត ។ ក្នុងសេចក្តីស្ទង់មតិឆ្នាំ២០០៩ បង្ហាញថា ៩៣ភាគរយនៃប្រជាជនកម្ពុជាទាំងអស់សុទ្ធតែជាជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ស្ទើរតែគ្រប់គ្រួសារទាំងអស់បានបាត់បង់យ៉ាងហោចណាស់សមាជិកគ្រួសារម្នាក់ ។ សង្គមកម្ពុជាទទួលបទពិសោធន៍ដ៏ជូរចត់ជាពិសេសគឺអាការៈនៃការរបួសផ្លូវចិត្តដ៏ធ្ងន់ធ្ងរ ។ ផលប៉ះពាល់ផ្លូវចិត្តដ៏យូរអង្វែងនេះត្រូវបានស្តែងឲ្យឃើញច្បាស់នៅក្នុងអត្រាខ្ពស់ក្នុងការរងនូវភាពតានតឹងផ្លូវចិត្តដ៏ធ្ងន់ធ្ងរក្រោយពីទទួលបានបទពិសោធន៍ជីវិតក្នុងភាពភ័យខ្លាច ក៏ដូចជាភាពខុសប្រក្រតីផ្លូវចិត្តដទៃផ្សេងទៀតដែលត្រូវបានសន្មតថាជាលទ្ធផលនៃរបបខ្មែរក្រហម ។ លើសពីនេះ ការស្ទង់មតិថ្មីៗនេះបានបង្ហាញឲ្យឃើញថា ៦០-៧៥ភាគរយនៃជនរងគ្រោះទាំងអស់បានទទួលរងនូវភាពស្មុគស្មាញកម្រិតធ្ងន់ធ្ងរ ។ ធ្ងន់ធ្ងរជាងនេះទៅទៀត បុគ្គលទទួលរងនូវផលប៉ះពាល់ផ្លូវចិត្តដែលក្នុងចំណោមបុគ្គលទាំងនោះប្រហែលជាមានជនរងគ្រោះពីរបបខ្មែរក្រហមដែលមានលំនៅស្ថាននៅសហគមន៍ឆ្ងាយៗ ។ ភាគច្រើននៃទំនាក់ទំនងខុសប្រក្រតីកម្រិតធ្ងន់រវាងបុគ្គលនិងក្រុមនៅក្នុងសហគមន៍មានសក្តានុពលភាពក្នុងការបង្កនូវអស្ថិរភាព ប្រសិនបើឫសគល់នៃបញ្ហាមិនត្រូវបានដោះស្រាយឲ្យសមស្រប ។ បញ្ហាពិសេសដូចជា អំពើហិង្សាក្នុងគ្រួសារ ការញៀនថ្នាំ ក្មេងស្ទាវបានលេចឡើងជាបញ្ហាចម្បងក្នុងសហគមន៍កម្ពុជាជាច្រើនដែលរួមជាមួយនឹងបញ្ហានៃភាពក្រីក្រផងដែរ ។ ការសិក្សាស្រាវជ្រាវថ្មីមួយបានបង្ហាញឲ្យឃើញថា ភាគច្រើននៃជនរងគ្រោះដែលទទួលរងនូវវិបត្តិផ្លូវចិត្តមានបំណងធ្វើការសងសឹក ។ អ្នកតំណាងភាគច្រើន (៧១ភាគរយ) នៃជនរងគ្រោះនៅក្នុងការស្ទង់មតិមួយផ្សេងទៀតមានបំណងចង់ឃើញមេដឹកនាំខ្មែរក្រហមទទួលរងនូវភាពឈឺចាប់ ហើយ៣៧ភាគរយមានបំណងធ្វើការសងសឹក និង ៤០ភាគរយទៀតមានបំណងចង់សងសឹកដែរ ប្រសិនបើឱកាសអំណោយផល ។ ដូច្នេះ ប្រជាជនកម្ពុជាមិនអាចជីករណ្តៅកប់បំបាត់ការពិតបានទេ ។ ភាពព្រងើយកន្តើយដ៏យូរក្នុងការមិននិយាយពិភាក្សានិងការមិនទាន់ដាក់បញ្ចូលកម្មវិធីសិក្សាអំពើ

ប្រល័យពូជសាសន៍ រួមទាំងភាពសាហាវឃោរឃៅទាំងប៉ុន្មាន ដោយសារតែសង្គ្រាមតាមតំបន់ដែលស្ថិតនៅក្នុងស្ថានភាពនយោបាយពិតប្រាកដបានផ្តល់នូវផលអវិជ្ជមានដ៏ធ្ងន់ធ្ងរលើយុវជនជំនាន់ក្រោយ ។ ក្មេងជំនាន់ក្រោយពិបាកនឹងជឿថា សកម្មភាពឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅបែបនេះអាចកើតឡើងនៅក្នុងប្រវត្តិសាស្ត្ររបស់គេ ។ ឥឡូវនេះ សង្គ្រាមត្រូវបានបញ្ចប់ ហើយកម្មាភិបាលខ្មែរក្រហមទាំងអស់បានក្លាយជាសមាជិកពេញលេញនៅក្នុងសហគមន៍និងកំពុងតែស្វែងរកនូវជីវភាពរស់នៅមួយដែលមានលក្ខណៈសាមញ្ញដូចជនរងគ្រោះដែរ ។ ជាមួយគ្នានេះ សកម្មភាពប្រចាំថ្ងៃរបស់កម្មាភិបាលខ្មែរក្រហមក្នុងការរកប្រាក់ចំណូលផ្តល់នូវម្ហូបអាហារ និងតម្រូវការមូលដ្ឋានដូចជា សេវាថែទាំសុខភាព ចំណេះដឹងបានក្លាយជាសកម្មភាពមួយធម្មតាដូចជនរងគ្រោះរបស់គេដែរ ។ កម្មាភិបាលខ្មែរក្រហមទាំងនោះរីករាយនឹងការប្រាស្រ័យទាក់ទងប្រចាំថ្ងៃដោយផ្ទាល់ជាមួយនឹងជនរងគ្រោះ ។ ប៉ុន្តែ កំហឹងនិងវិបត្តិផ្លូវចិត្តដែលធ្វើឲ្យមានរបួសធ្ងន់ធ្ងរឬជម្លោះមិនចេញមុខរបស់ជនរងគ្រោះក្នុងកាលៈទេសៈខ្លះអាចនឹងបង្កទៅជាអំពើហិង្សា ប្រសិនបើគ្មានយន្តការដោះស្រាយដ៏សមស្រប ។

ផ្អែកលើសច្ចភាព ការពិភាក្សាដែលផ្អែកលើសហគមន៍មានសារសំខាន់ក្នុងការដោះស្រាយបញ្ហាសង្គមនៅក្នុងស្ថានភាពក្រោយជម្លោះសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀតបានផ្តល់នូវកិច្ចខិតខំប្រឹងប្រែងនិងសកម្មភាពដទៃជាច្រើនទៀតនៅក្នុងដំណើរការដោះស្រាយបញ្ហានេះ ហើយជាក់ស្តែងក្រុមអង្គការក្រៅរដ្ឋាភិបាលទាំងអស់នេះសមនឹងទទួលបាននូវការកោតសរសើរដ៏ខ្ពង់ខ្ពស់ ។ ប៉ុន្តែ វេទិកាសាធារណៈដែលផ្អែកលើសហគមន៍ត្រូវការយ៉ាងចាំបាច់នូវទម្រង់ផែនការនិងទំហំធំជាងនេះ ។ តម្រូវការនេះពាក់ព័ន្ធជាមួយនឹងអ្នកដើរតួជាច្រើន ជាពិសេសពីសំណាក់រាជរដ្ឋាភិបាលនិងជនរងគ្រោះផ្ទាល់ ។ នេះគឺជាការផ្តល់ឱកាសដល់ជនរងគ្រោះដើម្បីចូលរួមឲ្យកាន់តែសកម្មជាងមុន ។ បុគ្គលខ្លះប្រហែលជាហៅដំណើរការនេះថា ជាការលាតត្រដាងការពិតឬបេសកកម្មស្វែងរកការពិតដែលឆ្ពោះទៅរកការផ្សះផ្សាជាតិ ។ ការចូលរួមពីសំណាក់ជនរងគ្រោះនៅក្នុងដំណើរការនេះពិតជាមានសារសំខាន់ក្នុងការធានាឲ្យបាននូវភាពជោគជ័យ ។ ការចូលរួមរបស់ជនរងគ្រោះមានន័យថា សំឡេងរបស់ជនរងគ្រោះត្រូវបានដឹងឮ ហើយចំណាប់អារម្មណ៍របស់គេត្រូវបានស្តាប់ ហើយលទ្ធផលនឹងត្រូវបានទទួលស្គាល់ដោយមានការពេញចិត្តពីជនរងគ្រោះផ្ទាល់ ។ ដូច្នេះ ការចូលរួមពីសំណាក់ជនរងគ្រោះពិតជាមានប្រយោជន៍ក្នុងការផ្តល់នូវភាពត្រឹមត្រូវរបស់ច្បាប់ដល់ដំណើរការស្វែងរកយុត្តិធម៌និងដើម្បីធ្វើឲ្យដំណើរការនេះត្រូវទទួលស្គាល់បានដោយសង្គមទាំងមូល ។ ការបង្កើតជាវេទិកាពិភាក្សាសាធារណៈផ្អែកលើសហគមន៍គឺដើម្បីផ្តល់នូវកន្លែងមួយសម្រាប់ជនរងគ្រោះក្នុងការបើកកិច្ចសន្ទនា ហើយយ៉ាងហោចណាស់ការព្រមទទួលស្គាល់បានធ្វើឲ្យជនរងគ្រោះមានអារម្មណ៍ថាធូរស្បើយ ខណៈពេលដែលភាពឈឺចាប់របស់គេត្រូវបានឮជាផ្លូវការ សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះត្រូវបានគោរពតាមរយៈវិប្បដិសារីរបស់ឧក្រិដ្ឋជន ហើយចំណងមិត្តភាពដែលប្រេះស្រាំត្រូវបានផ្សះផ្សាឡើងវិញ ចំណែកឯការពិតក៏ត្រូវបានស្វែងរកឃើញ ហើយយុវជនជំនាន់ក្រោយអាចនឹងចូលរួមនិងសិក្សាអំពីព្រឹត្តិការណ៍ទាំងនេះបានផងដែរ ។ យន្តការនេះត្រូវបានទទួលស្គាល់យ៉ាងទូលាយពីសំណាក់ប្រទេសដែលមានជម្លោះពីមុន ។ ចំណុចចាប់ផ្តើមដ៏សមរម្យសម្រាប់វេទិកាសាធារណៈដែលផ្អែកលើសហគមន៍គឺវត្តនៃព្រះពុទ្ធសាសនាដែលមានការចូលរួមពីព្រះសង្ឃ ។ អ្នកប្រាជ្ញភាគច្រើនដូចជា ឆេនល័រ (២០០៨) អ៊ីឃីសុន (២០០៥) ឡាំប៊ីន (២០០៨) រួមជាមួយនឹងបញ្ញវន្តដទៃជាច្រើនទៀតស្នើសុំឲ្យមានសកម្មភាពវិនិច្ឆ័យបែបនេះ បន្ថែមក្នុងតុលាការឧក្រិដ្ឋកម្មសម្រាប់ជនរងគ្រោះកម្ពុជា ។ ក៏មានការស្នើសុំពី ហេនណា អេរេន, ចន រ៉ូស, និង ចន ដូ លីដឺរេច ទៅកាន់លោកសាស្ត្រាចារ្យច្បាប់ឈ្មោះ ខៃ អេមបោស, គ្រីស្ទីន បេល និងសាស្ត្រាចារ្យដទៃទៀតទទួលស្គាល់យុទ្ធសាស្ត្រទាំងនេះថាមានសារសំខាន់ ហើយស្នើឲ្យប្រើយុទ្ធសាស្ត្រទាំងពីរនេះនៅក្នុងស្ថានភាពដែលកើតក្រោយជម្លោះ ។ សំខាន់ជាងនេះទៅទៀត អង្គការសហប្រជាជាតិបានទទួលយកនិងបានណែនាំឲ្យប្រើយុទ្ធសាស្ត្រទាំងពីរនេះជាមួយគ្នាជាជាងធ្វើការជ្រើសរើសមួយៗ ។ **ឌីរ័ត្ន ជួង**



លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា





លោក គ្លីនថ៍ វិល្លៀម សុន ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាម









# ចាំថ្ងៃស្អែក

*(តចប់)*

**ទឹកចិត្តម្ដាយ**

*ហេតុអ្វីបានជាអង្គការដោះលែង សុធា ឲ្យរួចផុតពីមន្ទីរឃុំឃាំង? តាមពិតទៅ វាមិនមែនជាទឹកចិត្តល្អរបស់អង្គការឡើយ ព្រោះ សុធា អាចរស់រានមានជីវិតបានដោយសារតែពលិកម្មរបស់ម្ដាយ សុធា គឺអ្នកគ្រូ សាម៉េត ។ ដោយសារអ្នកគ្រូ សាម៉េត មានសំឡេងពីរោះ គាត់ក៏ទទួលបានការចាត់តាំងពីអង្គការថ្នាក់លើ ឲ្យធ្វើជាអ្នកចម្រៀងប្រចាំតំបន់ភូមិភាគ ។ ក្នុងរយៈពេលមួយខែម្ដង អង្គការខាងភូមិភាគបានរៀបចំការប្រគំតន្ត្រីដែលមានសុទ្ធតែបទចម្រៀងបម្រើឲ្យមាគ៌ាបដិវត្តន៍ មហាលោតផ្លោះ មហាអស្ចារ្យ សម្រាប់ផ្ដល់ការកម្សាន្តសប្បាយដល់ប្រជាជន ។ ប៉ុន្តែ បទចម្រៀងទាំងនោះធ្វើឲ្យប្រជាជនមិនសប្បាយចិត្តទេ ព្រោះមិនអាចកាត់បន្ថយការនឿយហត់និងការស្រេកឃ្លានបាន ។ នៅពេលម្ដាយ សុធា ក្លាយជាអ្នកចម្រៀងរបស់អង្គការ គាត់ក៏មានរបបហូបចុកប្រសើរជាងប្រជាជនធម្មតា ។ ពេលនោះ ហើយដែលសម្រស់របស់គាត់បានទាក់ទាញសមមិត្ត ស៊ឹម ជាអង្គការថ្នាក់ភូមិភាគឲ្យស្រឡាញ់គាត់ រួចក៏បានជួយប្រាប់ដំណឹងដល់អ្នកគ្រូ សាម៉េត ថាកូនប្រុសរបស់គាត់កំពុងតែជាប់ឃុំក្នុងមន្ទីរសន្តិសុខវត្តព្រៃខ្លា ហើយនឹងត្រូវស្លាប់ដោយការដាក់ទណ្ឌកម្មរបស់អង្គការជាមិនខាន ។ បន្ទាប់មក ក៏ស្រាប់តែមានដំណឹងមួយទៀតថា អង្គការកំពុងស៊ើបប្រវត្តិរូបរបស់គាត់និងលោកស័ក្តិបី កែវ ហៀង ជាប្ដីរបស់គាត់ ។ ដូច្នេះ ដើម្បីរក្សាជីវិតកូនប្រុស ជីវិតខ្លួនឯង ព្រមទាំងប្ដីដែលបានបាត់ដំណឹង គាត់ក៏ស្ម័គ្រចិត្តរៀបការជាមួយសមមិត្ត ស៊ឹម ទោះជាមានឈ្មោះអាស្រូវថាក្បត់នឹងប្ដីក៏ដោយ ។*

**ការប្រេះឆា**

*មនុស្សជាច្រើនបានសម្លឹងមកគាត់ដោយក្រសែភ្នែកពេបជ្រាយ ពេលដែលគាត់យល់ព្រមរៀបការជាមួយសមមិត្ត ស៊ឹម ប៉ុន្តែប្រជាជនទាំងនោះមិនបានដឹងទេថា គាត់ធ្វើនោះគឺដើម្បីរក្សាជីវិតកូនរបស់គាត់ឡើយ ។ ដោយសារតែខ្មែរក្រហមសម្លាប់ប្រជាជនមិនរើសមុខ ដូច្នេះនរណាដែលរៀបការជាមួយកម្មាភិបាលខ្មែរក្រហម អ្នកនោះនឹងក្លាយជាអ្នកដែលប្រជាជនស្អប់ខ្ពើម ដែលសូម្បីតែលោកយាយ ហេង ក៏មានការអន់ចិត្តដែរ នៅពេលកូនប្រសាស្រីក្បត់ចិត្តកូនប្រុសរបស់គាត់ក្នុងពេលដែលគាត់មិនដឹងច្បាស់ថាកូនគាត់រស់ឬស្លាប់ ។ ភាពប្រេះឆានេះចាប់ផ្ដើមមាននៅក្នុងចិត្តរបស់គាត់ ទោះបីជាគាត់ទាំងពីរធ្លាប់ឆ្លងកាត់ការលំបាកនិងការស្លាប់ជាមួយគ្នាយ៉ាងណាក៏ដោយ ។ អ្នកទាំងពីរគ្មានឱកាសជួបមុខគ្នាទេ ព្រោះលោកយាយ ហេង រស់នៅក្នុងភូមិព្រៃស្មៀត ចំណែកអ្នកគ្រូ សាម៉េត រស់នៅក្នុងមន្ទីររបស់អ្នកចម្រៀងអង្គការ ។ អ្នកគ្រូ សាម៉េត មិនហ៊ានបកស្រាយពីការពិតនេះប្រាប់ទៅលោកយាយ ហេង ឡើយ ព្រោះទោះបីសមមិត្ត ស៊ឹម ជាកម្មាភិបាលខ្មែរក្រហមក៏ពិតមែនមែន ប៉ុន្តែគាត់ក៏មិនអាចជួយដោយបើកចំហបានទេ ដោយសារនៅមានអង្គការថ្នាក់លើដែលធំជាងគាត់ទៀត ។*

*ក្រោយពី សុធា ត្រូវបានដោះលែង អង្គការមិនបានបង្ខំឲ្យ សុធា ធ្វើការដូចកាលពីពេលមុនទៀតទេ ។ ដូច្នេះ សុធា មានអារម្មណ៍ថាខ្លួនមានសេរីភាពច្រើនជាងមុន ទទួលបានរបបបបរច្រើនជាងពេលធម្មតា និងមិនត្រូវអង្គការបន្ទោសទៀត ទោះជាទៅធ្វើពលកម្មយឺតក៏ដោយ ។ សុធា មិនដូចជាកូនប្រជាជនថ្មីដទៃទៀតដែលត្រូវធ្វើពលកម្មស្ទើរគ្មានពេលសម្រាក ទទួលរបបអាហារតិច និងទទួលការស្ដីបន្ទោសដោយពាក្យថា ជាប់កម្ទេលខ្មាំងនិងពាក្យអសុរោះឡើយ ។*

*ថ្ងៃមួយលោកយាយ ហេង ស្រាប់តែប្រាប់ សុធា ឲ្យទៅលេងជាមួយម្ដាយដែលរស់នៅក្នុងមន្ទីរអង្គការថ្នាក់លើ ។ ទៅដល់ទីនោះភ្លាម ស្ត្រីវ័យកណ្ដាល២-៣នាក់ដែលធ្លាប់ស្គាល់ សុធា ក៏បានលើកដៃចង្អុលទៅអង្រឹងមួយ រួចប្រាប់ថា ម៉ែរបស់ឯងជិតរៀបការជាមួយសមមិត្ត ស៊ឹម ដែលនឹងក្លាយជាពុកថ្មីរបស់ឯង*

ហើយ ដូច្នេះឯងត្រូវរៀនហៅសមមិត្ត ស៊ីម ថា «ពុក» ឲ្យហើយទៅ ហើយពេលនេះម៉ែឯងកំពុងដេកនៅក្នុងអង្រឹងមួយនោះ ។ ក្រោយពីពាក្យទាំងនេះ សុធា មានអារម្មណ៍ខឹងនឹងម្ដាយជាខ្លាំង រួចក៏បានដើរទៅរកម្ដាយទាំងទឹកមុខមួហ្មង និងសម្លឹងមិនព្រិចភ្នែក ទៅកាន់អង្រឹងដែលម្ដាយសម្រាក ។ ពេលកំពុងដើរ សុធា ហាក់ដូចជាមិនសូវចាប់អារម្មណ៍ជាមួយសម្ដីអ្នកផ្សេងដែលហៅហូបផ្លែឈើទេ ទោះបីជាឃ្លានយ៉ាងណាក៏ដោយ ។ ពេលដើរមកជិតម្ដាយ សុធា បានឃើញកាន់តែច្បាស់ថា ម្ដាយរបស់គេស្លៀកសំពត់ខ្មៅយ៉ាងស្អាតជាមួយនឹងក្រមាបង់កពណ៌ក្រហមថ្មីកំពុងសម្រាកនិងដេកគ្នាយ៉ាងសប្បាយនៅក្នុងអង្រឹងមួយដែលចងទន្ទឹមនឹងអង្រឹងរបស់សមមិត្ត ស៊ីម ។ ដោយសារឃើញ សុធា នៅឈរវេរាមិនហ៊ានចូលទៅជិត អ្នកគ្រូ សាម៉ែត ក៏បានបក់ដៃហៅ សុធា ឲ្យចូលមក ។ ទោះបីជាអ្នកគ្រូ សាម៉ែត មិនបានប្រាប់ឲ្យ សុធា ហៅសមមិត្ត ស៊ីម ថាពុកក៏ដោយ ប៉ុន្តែ សុធា ហាក់បីដូចជាតូចចិត្តនឹងខ្លួនឯង ដោយមិននិយាយអ្វីទាំងអស់ គ្រាន់តែឱនមុខចុះខំប្រឹងទប់ទឹកភ្នែក ។ នៅថ្ងៃនោះ សុធា មានអារម្មណ៍ថា ម្ដាយរបស់ខ្លួនមិនសូវនិយាយស្ដីទៅកាន់គេដូចកាលមុនទៀតទេ ហើយប្រយោគមួយឃ្លាដែល សុធា ចាំមិនភ្លេចនោះ គឺ «កុំមកកាន់ទីនេះទៀត» ។ ពេលនោះហើយដែល សុធា គិតថា គេគ្មានម្ដាយទៀតទេ ។

នៅកន្លែងដែលអ្នកគ្រូ សាម៉ែត រស់នៅ មានកាំភ្លើងវែងខ្លី រថយន្តសម្រាប់កងទ័ព ផ្លែឈើជាច្រើនមុខដាក់គរនៅលើតុវែង អង្រឹងចងខ្វាត់ខ្វែងជាច្រើននៅតាមប្រឡោះសសរ និងមនុស្សស្លៀកពាក់ខោអាវខ្មៅបង់កក្រមាថ្មី និងពាក់ស្បែកជើងកង់ឡាន ។ ជាមួយនឹងចលនាដើរនិងអង្គុយមានភាពរហ័សរហួនខុសពីអ្នកភូមិដែលមើលទៅដូចជាមនុស្សគ្មានកម្លាំង សុធា សង្កេតឃើញថា មនុស្សប្រុសទាំងនោះមានទឹកមុខគួរឲ្យខ្លាច បើសម្លឹងចំនរណាប្រៀបដូចជាចង់នឹងសម្លាប់អ្នកនោះ ។ ពេលងាកមុខទៅជ្រុងម្ខាងទៀត សុធា ស្រាប់តែឃើញមានមនុស្សប្រុស២នាក់ស្លៀកពាក់ខោអាវខ្មៅកំពុងចម្អិនអាហារ ដោយបុរសទីមួយកំពុងហាន់ថ្លើមដ៏ក្រហមរងាលមួយដុំធំ ចំណែកបុរសទីពីរវិញកំពុងតែឆាសាច់នៅក្នុងខ្ទះគ្លោត ។ បន្ទាប់មក បុរសដែលកំពុងឆាសាច់បានងាកមុខមកសួរបុរសដែលកំពុងហាន់ថ្លើមថា «ហេតុអ្វីក៏ឆាសាច់មនុស្សដុះខ្លាំងជាងសាច់ឆ្កែឬសាច់ឆ្មាយ៉ាងនេះ?» ។ បុរសទីពីរបានលើកថ្លើមក្រហមប្រឡាក់ឈាមដែលហាន់រួចដាក់ចូលទៅក្នុងខ្ទះដែលអ្នកទីមួយកំពុងឆា ហើយនិយាយតបវិញថា «ប្រហែលជាសាច់និងថ្លើមរបស់មនុស្សមានជាតិអំបិលច្រើនទេដឹង ទើបវាដុះយ៉ាងនេះ» ។ ពេលកំពុងគិតពីបញ្ហានេះ ក៏ស្រាប់តែមានស្ត្រីវ័យកណ្ដាល ២-៣នាក់ដែលរស់នៅទីនោះញញឹមដាក់ រួចនិយាយរាក់ទាក់ហៅហូបផ្លែឈើ ។ នៅពេលនោះ ក៏មានស្ត្រីម្នាក់ផ្សេងទៀតបានឃាត់ សុធា ឲ្យនៅហូបបាយជាមួយ «ឯងនៅហូបបាយនៅទីនេះហើយ ព្រោះថ្ងៃនេះមានម្ហូបឆ្ងាញ់ៗហូបច្រើនណាស់ ដែលនៅភូមិឯងមិនធ្លាប់មានធ្វើ» ។ សុធា ដឹងច្បាស់ថា មុខម្ហូបទាំងនេះគឺធ្វើពីសាច់និងថ្លើមរបស់មនុស្ស ដែលវាគួរឲ្យខ្លាចនិងខ្ពើមបំផុត ប៉ុន្តែមិនអាចនិយាយបាន ។ ស្របពេលជាមួយគ្នា ម្ដាយរបស់ សុធា បានដើរមកជិត រួចនិយាយដោយសំឡេងតិចៗថា «កូនទៅផ្ទះវិញទៅ ហើយឈប់មកទីនេះទៀត ព្រោះកន្លែងនេះមិនល្អសម្រាប់កូនទេ» ។ គ្រាន់តែនិយាយចប់ គាត់ក៏ដើរត្រឡប់ទៅរកអង្រឹងវិញភ្លាម ។ ចំណែកស្ត្រីប៉ុន្មាននាក់ទៀតនៅតែបន្តហៅ សុធា ឲ្យហូបផ្លែឈើ និងអាហារនេះទៀត ដែលទង្វើនេះហាក់ដូចជាចង់បង្ហាញឲ្យអ្នកដទៃឃើញថា អង្គការយកចិត្តទុកដាក់មកលើក្មេងជាខ្លាំង ។ ពេលកំពុងលាម្ដាយត្រឡប់មកកាន់ភូមិវិញ ស្ត្រីទាំងនោះក៏បានប្រែកផ្លែឈើឲ្យ សុធា យកមកហូបនៅផ្ទះ ។

## ជីវិតថ្មី

នៅចុងឆ្នាំ១៩៧៧ ពេលដែលមានអាយុប្រហែលជា៧-៨ ឆ្នាំ ទើប សុធា ដឹងថា ប្រធានកងស្ត្រី ប្រធានកងកុមារ និងប្រធានភូមិចាស់ត្រូវបានអង្គការដកចេញ ដោយអ្នកខ្លះត្រូវចាប់ខ្លួន ខ្លះទៀតត្រូវយកទៅរៀនសូត្រ ឬដកហូតអំណាចឲ្យក្លាយទៅជាប្រជាជនធម្មតាវិញ ។ នៅក្នុងភូមិហាក់ដូចជាមានសភាពស្ងប់ស្ងាត់ ប៉ុន្តែតាមពិតគឺយកមនុស្សទៅសម្លាប់ ។ យ៉ាងណាមិញ នៅក្នុងភូមិព្រៃស្លៀត ពួកនិរតីដែលមកគ្រប់គ្រងថ្មីក៏បានដាក់ផែនការឲ្យប្រជាជនធ្វើពលកម្មកាន់តែច្រើន ចំណែករបបអាហារវិញកាន់តែតិចជាងមុន ដែលជាហេតុធ្វើឲ្យប្រជាជនរងទុក្ខវេទនា និងអត់ឃ្លានបំផុត ។ ក្រោយមកទៀត ខ្មែរក្រហមក៏បានជ្រើស

រើសយកគ្រួសារណាដែលជាប់និន្នាការជាទាហាន គ្រូបង្រៀន ប៉ូលិស កងរាជអាវុធហត្ថ មន្ត្រីរាជការ និងអ្នកដែលអង្គការធ្លាប់កសាងឬអ្នកជាប់កម្ពែលប្រតិកិរិយាឲ្យផ្លាស់ទៅរស់នៅស្រុកអូររាំង ។ ដោយសារតែឃើញអង្គការដឹកប្រជាជនទាំងរទេះយកទៅបែបនេះ ធ្វើឲ្យប្រជាជននៅក្នុងភូមិព្រៃស្មៀតទាំងមូលមានការភ័យខ្លាចជាខ្លាំង រហូតដល់នាំគ្នាគិតថា សកម្មភាពបែបនេះគឺយកប្រជាជនទៅសម្លាប់ ។ ជាមួយនឹងការផ្លាស់ប្រជាជនចេញពីភូមិ អង្គការក៏បានដាក់ផែនការឲ្យប្រជាជនធ្វើការកាន់តែច្រើន ថែមទាំងផ្តល់របបបបរកាន់តែតិចទៅ ដែលធ្វើឲ្យប្រជាជនបាក់កម្លាំងនិងមានជំងឺគ្រប់ៗគ្នា ។ ដូច្នេះ ដើម្បីបំបាត់ការស្រេកឃ្លានប្រជាជនមួយចំនួនក៏នាំគ្នាលួចគាស់មើមត្រាវឬមើមដំឡូងយកមកស្ងោរហូបបន្ថែម ខ្លះទៀតតវ៉ាជាមួយអង្គការដើម្បីការពារខ្លួន ព្រោះមិនអាចធ្វើការគ្រប់តាមផែនការកំណត់ ដែលទាំងអស់នេះសុទ្ធតែជាកំហុសនាំឲ្យអង្គការយកទៅកសាងនិងធ្វើឲ្យចំនួនមនុស្សនៅក្នុងភូមិទាំងអស់កាន់តែតិចទៅៗ ។

មិនយូរប៉ុន្មាន អ្វីដែលលោកយាយ ហេង បារម្ភបានមកដល់មែន ។ នៅវេលាម៉ោងប្រហែលជា៣រសៀល ពេលដែលគាត់កំពុងត្បាញកន្ទេលក្នុងមណ្ឌលយាយៗ មេកងបានមកប្រាប់គាត់ថា គាត់មានឈ្មោះត្រូវផ្លាស់ទីលំនៅនៅថ្ងៃស្អែក ប៉ុន្តែ សុធា មិនអាចទៅជាមួយគាត់បានទេ ។ ពេលនោះ លោកយាយ ហេង នៅស្ងៀមមិននិយាយអ្វីទាំងអស់ គ្រាន់តែមកដល់ក្នុងផ្ទះក្លាមស្រវាឱបចៅ ព្រោះខ្លាចទៅហើយមិនអាចត្រឡប់មកវិញ ។ ទន្ទឹមនឹងនោះ លោកយាយ ហេង ក៏ត្រេកអរនៅក្នុងចិត្តដែរ ព្រោះ សុធា មិនបានទៅជាមួយ ។ បន្ទាប់មក លោកយាយ ហេង បានលួងលោម សុធា ថា គាត់ប្រហែលជាមិនស្លាប់ទេ ហើយបើមាននិស្ស័យគាត់នឹងអាចជួបវិញ ។ នៅយប់នោះ ជីដូននិងចៅនាំគ្នាអង្គុយនិយាយទាំងហូរទឹកភ្នែករហូតទល់ភ្លឺ ។

ពេលនោះ លោកយាយ ហេង មានមន្ទិលសង្ស័យថា ប្រហែលជាកូនប្រសាររបស់គាត់មានចំណែកពាក់ព័ន្ធនៅក្នុងរឿងនេះហើយ ដោយម្តាយរបស់ សុធា ជាអ្នករាយការណ៍ប្រាប់សមមិត្ត ស៊ីម ។ ចំណុចដែលធ្វើឲ្យលោកយាយ ហេង ហ៊ានសន្និដ្ឋានបែបនេះ គឺដោយសារអង្គការមិនឲ្យ សុធា ផ្លាស់ទីលំនៅទៅជាមួយគាត់ ។ លោកយាយ ហេង មានការតូចចិត្តបំផុត ដោយគិតថាហេតុអ្វីបានជាកូនប្រសាររបស់គាត់រាយការណ៍សម្លាប់គាត់បែបនេះ ។ មួយសន្ទុះក្រោយមក គាត់ក៏ពិចារណាថា នេះប្រហែលជាកូនប្រសាគាត់ជួយ សុធា ឲ្យរួចផុតពីស្លាប់ រួចក៏ប្រាប់កុំឲ្យ សុធា ខឹងនឹងម្តាយរបស់ខ្លួន ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ក្នុងចិត្តរបស់លោកយាយ ហេង នៅតែគិតថា អ្នកគ្រូ សាម៉េត គឺជាមូលហេតុនៃការផ្លាស់ទីលំនៅរបស់គាត់ ។

មុនពេលចាកចេញ លោកយាយ ហេង បាននិយាយផ្តាំផ្ញើអ្នករួមការងារជាមួយគ្នាឲ្យជួយមើលថែចៅរបស់គាត់ផង ព្រោះគាត់គ្មានសង្ឃឹមថាអាចនៅរស់ឃើញមុខចៅតទៅទៀតទេ ។ ពេលដែលរទេះមកដល់នៅពេលថ្ងៃ ចម្ងាយប្រហែលជាង៣០០ម៉ែត្រពីខ្ទម ម្តាយរបស់ សុធា ក៏បានមកជូនដំណើរលោកយាយ ហេង ប៉ុន្តែអ្នកទាំងពីរនាក់មិនសូវនិយាយរកគ្នាទេ ពីព្រោះពេលលោកយាយ ហេង និយាយទៅកាន់ចៅ ម្តាយរបស់ សុធា ងាកមុខចេញ ។ ចំណែក សុធា វិញ គិតតែពីយំឈរសម្លឹងមើលដំណើរជីដូនទាំងខ្លោចផ្សាក្នុងចិត្ត ។ លោកយាយបានប្រាប់ សុធា ឲ្យឈប់យំនិងត្រឡប់ទៅផ្ទះវិញ ព្រោះខ្លាចអង្គការមកឃើញ ។

ក្រោយពីលោកយាយ ហេង ចាកចេញបានប៉ុន្មានថ្ងៃ ស្រាប់តែលោកយាយ ហេង បានមកដល់ផ្ទះវិញ ។ សុធា ត្រេកអរជាខ្លាំង រួចក៏រត់ទៅឱបលោកយាយ ហេង ។ មូលហេតុដែលលោកយាយ ហេង អាចវិលត្រឡប់មកវិញ គឺដោយសាររទេះដែលដឹកអ្នកផ្លាស់ទីលំនៅមិនគ្រប់ចំនួន អង្គការសម្រេចឲ្យនៅរង់ចាំលើកក្រោយវិញ ។ ពេលនោះ អ្នកគ្រូ សាម៉េត និងលោកយាយ ហេង មិនហ៊ាននិយាយរកគ្នាឡើយ ទោះបីជាគាត់ខឹងនឹងកូនប្រសាក៏ដោយ ។ យប់នោះ អ្នកគ្រូ សាម៉េត ក៏ត្រឡប់ទៅអង្គភាពរបស់គាត់វិញ ។

ថ្ងៃផ្លាស់ទីលំនៅលើកទីពីរមកដល់ លោកយាយ ហេង ឈរនៅក្បែររទេះសម្លឹងមករកកូនប្រសាទាំងទ្រូងអួលណែននិងអាណិតចៅដែលគ្មានទីពឹង ប្រសិនបើគ្មានគាត់ ព្រោះកូនប្រសារបស់គាត់បាននិយាយថា មិនយក សុធា ទៅរស់នៅជាមួយទេ ។ ចំណែក អ្នកគ្រូ សាម៉េត មិននិយាយអ្វីមកកាន់លោកយាយ ហេង ដូចពេលដែលគាត់ត្រូវផ្លាស់ទីលំនៅដោយខកជើងរទេះនោះទេ ។

លោកយាយ ហេង គ្រាន់តែនិយាយទៅកាន់ម្តាយរបស់ សុធា ដោយពាក្យអរអាក់រអួលថា «នាងត្រូវចិញ្ចឹមកូនឲ្យបានល្អដូចជាខ្ញុំចិញ្ចឹមគេណា»។ ម្តាយរបស់ សុធា មិនឆ្លើយតបទៅលោកយាយ ហេង ទេ តែគាត់ងក់ក្បាល ដោយកាន់ដៃរបស់ សុធា យ៉ាងណែន។ បន្ទាប់មក លោកយាយ ហេង បាននិយាយមកកាន់ម្តាយរបស់ សុធា ទាំងសម្តីរដាក់រដុបម្តងទៀតថា «នាងយកកូនទៅចុះ កុំឲ្យគេយំ ខ្ញុំមិនចង់ឲ្យនរណាយំ ពេលខ្ញុំចេញដំណើរទេ»។ ក្រោយពីពាក្យសម្តីនេះ អ្នកគ្រូ សាម៉េត បានប្រឡេះដៃកូនចេញពីជីដូន និងខំប្រឹងខ្ទប់មាត់ សុធា មិនឲ្យយំ។ បន្ទាប់មក អ្នកគ្រូ សាម៉េត បានអូសដៃ សុធា ត្រឡប់មកផ្ទះវិញ។

នៅប្រហែលជាពាក់កណ្តាលអធ្រាត្រ ក្រោយពីភ្លៀងខ្យល់បានស្ងប់ ត្រចៀករបស់ សុធា ស្រាប់តែឮសូរហាក់ដូចជាមានសំឡេងបញ្ជាក់ថា អ្នកផ្លាស់ទីលំនៅបានវិលមកវិញ។ មួយសន្ទុះក្រោយមក សុធា បានរត់យ៉ាងលឿនចេញទៅខាងក្រៅផ្ទះ ទោះជាអ្នកគ្រូ សាម៉េត ព្យាយាមឃាត់យ៉ាងណាក៏ដោយ ព្រោះវាជាពេលយប់ដែលកងឈ្លបចុះមកតាមដាននៅតាមផ្ទះរបស់ប្រជាជនដើម្បីស៊ើបរកខ្មាំង។ ប៉ុន្តែ សុធា មិនស្តាប់ម្តាយទេ ដោយរត់ចេញទៅក្រៅរកមើលថាតើមានលោកយាយ ហេង ត្រឡប់មកវិញទេ។

ពេលមកដល់ទីដៅ ភ្នែករបស់ សុធា ខំសំឡឹងរកមើលលោកយាយ ហេង គ្រប់ទីកន្លែង។ ក្រោយពីឃើញច្បាស់ សុធា ក៏បានរត់ទៅឱបគាត់ទាំងទឹកភ្នែក។ លើកនេះ លោកយាយ ហេង អាចត្រឡប់មកវិញ គឺដោយសាររទេះបរទៅដល់ពាក់កណ្តាលផ្លូវស្រាប់តែមានខ្យល់ព្យុះនិងភ្លៀងជាខ្លាំង ដែលធ្វើឲ្យគោមិនអាចដើរទៅមុខបាន។

## បដិវត្តន៍រលំ

ពេលខែកត្តិកឈានចូលមកដល់ ក្លិនប្រហើរនៃស្រូវពណ៌ស្វាបសេក និងពណ៌មាសបានក្រអូបសាយភាយចេញពីវាលស្រែ ដែលធ្វើឲ្យប្រជាជននៅភូមិព្រៃស្មៀតត្រូវប្រញាប់ប្រញាល់ច្រូតស្រូវដែលទុំក្នុងវាលស្រែ ដើម្បីឲ្យទាន់តាមផែនការរបស់អង្គការដែលបានកំណត់។ នៅរដូវច្រូតកាត់ក្នុងខែមករា ឆ្នាំ១៩៧៩ ពេលដែលកំពុងកើបអាចម៍គោនៅពេលព្រឹកព្រលឹម សុធា ស្រាប់តែឮសូរផ្គរលាន់យ៉ាងខ្លាំង នៅជិតៗភូមិ។

មិនយូរប៉ុន្មាន ពេលដែលកំពុងធ្វើការទៅតាមមុខព្រួញដែលអង្គការបានកំណត់ ស្រាប់តែប្រជាជននាំគ្នាភ្ញាក់ផ្អើលរត់ពីកន្លែងធ្វើពលកម្មរៀងៗខ្លួនត្រឡប់មកកាន់ផ្ទះដែលគេរស់នៅវិញ។ ពេលនោះ សុធា បានឃើញកងទ័ពខ្មែរក្រហមរត់ទៅទិសខាងលិចរបៀបដូចជាប្រញាប់ប្រញាល់និងភ័យខ្លាច ដោយខ្លះរត់ជាក្រុមតូចៗមានគ្នា៥នាក់និងខ្លះទៀតមានគ្នា៧នាក់ឬលើសពីនេះ ដោយមានខោអាវប្រឡាក់សុទ្ធតែដី ដែលបញ្ជាក់ឲ្យឃើញថាកងទ័ពខ្មែរក្រហមប្រយុទ្ធចាញ់ភាគីម្ខាងទៀត ហើយបាក់ទ័ព ទើបរត់គេចមកលាក់ខ្លួននៅតាមភូមិនានា រហូតធ្វើឲ្យអ្នកភូមិជ្រួលច្របល់។ ប៉ុន្មានថ្ងៃក្រោយមក ក៏មានកងទ័ពវៀតណាមដែលនិយាយខ្មែរមិនច្បាស់បានចូលមកដល់ភូមិព្រៃស្មៀត ហើយសួរអ្នកភូមិថា «ពុកម៉ែមានឃើញកងទ័ពខ្មែរក្រហមទេ?» ដោយសារតែមិនទាន់ដឹងច្បាស់អំពីសភាពការណ៍ស្រុកទេស គ្មានប្រជាជនណាម្នាក់ហ៊ានឆ្លើយថាឃើញឡើយ ទោះបីជាឃើញកងទ័ពខ្មែរក្រហមនៅសម្ងំលាក់ខ្លួននៅក្នុងភូមិក៏ដោយ។ ក្នុងរយៈពេលនោះ នៅក្នុងភូមិព្រៃស្មៀតទាំងមូលមានភាពច្របូកច្របល់យ៉ាងខ្លាំង ដោយសារប្រជាជននាំគ្នាដេញចាប់មាន់ទានិងកើបស្រូវអង្ករពីជង្រុកយកមកទុកក្នុងផ្ទះរៀងៗខ្លួន។

ពេលដែលឃើញសភាពការណ៍នៅក្នុងភូមិមានភាពធូររលុងបន្តិច លោកយាយ ហេង ក៏មានគំនិតយក សុធា ទៅផ្ញើលោកយាយម្នាក់ដែលជាមនុស្សធ្លាប់រាប់អានគ្នាពីមុន ព្រោះគាត់ត្រូវធ្វើដំណើរទៅរកបងប្អូននិងកូនៗរបស់គាត់ផ្សេងទៀតឲ្យមករស់ជុំគ្នានៅក្នុងភូមិព្រៃស្មៀត នៅស្រុកបាភ្នំ(?) ខេត្តកំពង់ចាម។ រទេះគោមួយបានបរមកដល់មុខផ្ទះ អ្នកគ្រូ សាម៉េត ក៏បានបង្ខំឲ្យ សុធា ឡើងរទេះ រួចនិយាយថា នេះជាបញ្ញើរបស់សមមិត្ត ស៊ីម ហើយក្នុងនាមគាត់ជាម្តាយ គាត់មានសិទ្ធិនាំទៅរស់នៅក្នុងស្រុកកំណើតរបស់គាត់នៅភូមិព្រែកក្របស្នារខាងលិច។ ភ្លាមនោះ សុធា បានសុំម្តាយឲ្យនៅរង់ចាំជួបជីដូនសិន ប៉ុន្តែម្តាយ សុធា មិនអនុញ្ញាតទេ ដោយប្រាប់ថា គាត់ត្រូវកងទ័ពវៀតណាមចាប់យកទៅបាត់ហើយ។ ទីបំផុត សុធា ក៏យល់ព្រមទៅ ព្រោះមិនហ៊ានប្រកែកជាមួយសម្តីរបស់ម្តាយនិងការចាត់តាំងរបស់

សមមិត្ត ស៊ឹម ។

ពេលកំពុងគិត កងឈ្លបម្នាក់បានប្រាប់ សុធា ឲ្យយកទឹកត្នោតនិងអាហារដែលដាក់នៅក្នុងស្នូកយកមកហូប ។ គ្រាន់តែឃើញទឹកត្នោតផ្អែមមួយបំពង់ អំបុកស្រូវថ្មីមួយកូនល្អី បាយអង្ករស្រូវថ្មីមួយកញ្ចប់ សុធា លេបទឹកមាត់ ហើយខំសម្លឹងមើលកញ្ចប់អាហារដោយក្តីរំភើប ព្រោះវាពិតជាឆ្ងាញ់ខ្លាំងណាស់សម្រាប់រយៈពេលជាងពាន្លាំមកហើយមិនដែលបានហូបបែបនេះទេ ។ សុធា ហូបបាយបណ្តើរ ទឹកភ្នែកហូរបណ្តើរ នឹកស្រមៃដល់ជីដូនអង្គុយទល់មុខនិងកំពុងពិសាបាយរួមជាមួយ ។ ពេលរទេះចូលមកដល់ក្នុងភូមិ កងឈ្លបម្នាក់បានប្រាប់ សុធា ថា យើងបានមកដល់ភូមិព្រែកតាសរហើយ ។ ពេលក្រឡេកឃើញខ្ទម សុធា កាន់តែនឹកដល់ជីដូនកាន់តែខ្លាំងឡើង ព្រោះជាទីកន្លែងដែលធ្លាប់រស់នៅជាមួយគ្នា ។ រទេះបានចតនៅកណ្តាលវាលស្រែក្នុងយប់ងងឹត រួចនាំ សុធា បន្តដំណើរដោយថ្មើរជើងទៅក្នុងភូមិព្រែកក្រូចខាងជើងនិងខាងកើត ដើម្បីរកទូកឆ្លងទៅកាន់ភូមិព្រែកក្រូចខាងលិច ។ ការធ្វើដំណើរពិតជាពិបាកខ្លាំងណាស់ ព្រោះដីមានសភាពរអិលក្នុងភូមិមានសភាពស្ងាត់ជ្រងំមិនសូវមានមនុស្សធ្វើដំណើរ ហើយថែមទាំងគ្មានទូកឆ្លងទៅត្រើយម្ខាងទៀត ។ សុធា មានការព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនណាស់ នៅពេលដែលបានឮកងឈ្លបនោះសម្រេចចិត្តថាត្រូវតែហែលឆ្លងកាត់ទន្លេតូចទាំងយប់អធ្រាត្រ ។ ពេលនោះ សុធា រារែកចិត្តជាខ្លាំង ប៉ុន្តែមិនហ៊ានប្រឆាំងនឹងបញ្ជារបស់កងឈ្លបនោះទេ ។

ក្រោយពីកងឈ្លបហែលយោង សុធា រហូតដល់ត្រើយម្ខាងទាំងយប់ងងឹត សុធា ក៏បានដើរតាមកងឈ្លបចូលទៅក្នុងភូមិព្រែកក្រូចខាងលិច រួចចូលទៅសម្រាកនៅក្នុងវត្តមួយដែលមានសភាពស្ងាត់ជ្រងំដែលជាស្រុកកំណើតរបស់ម្តាយ ។ ព្រលឹមឡើង កងឈ្លបនិង សុធា បានចាកចេញពីកុដិ ។ ពេលនោះ សុធា ស្រាប់តែឃើញមានស្នាមឈាមនៅជាប់ជញ្ជាំងកុដិដូចជានៅថ្មីៗ ព្រមទាំងធុំក្លិនស្អុយដូចជាសត្វអ៊ីស្លាប់ ។ ភ្លាមនោះ សុធា ក៏ឃើញផ្នូរខ្មោចជាច្រើនដែលទើបនឹងកប់ថ្មីៗ ហើយជឿជាក់ថាក្លិនស្អុយជះចេញពីផ្នូរទាំងនោះ ។ បន្ទាប់មក សុធា ក៏ឃើញសាកសពមនុស្សអណ្តែតជាច្រើននៅក្នុងទន្លេ ។ សុធា ដើររកមនុស្សនៅក្នុងភូមិដើម្បីសួររកញាតិសន្តាននិងជីដូនជីតាខាងម្តាយ ។ ប៉ុន្តែមិនមាននរណាម្នាក់ដឹងថា ពួកគាត់នៅរស់ឬក៏ស្លាប់ឡើយ ។

កងឈ្លបចេះតែបន្តដំណើរទៅមុខ ដើម្បីសួរព័ត៌មានពីគ្រួសាររបស់ម្តាយ សុធា ។ ពេលមកដល់ដីឡូត៍របស់យាយ យ៉ិន អ្នកទាំងពីរក៏បានជួបស្ត្រីមេម៉ាយម្នាក់ឈ្មោះ មីង ដូរ មានអាយុប្រមាណ៤០ឆ្នាំ មានកូនប្រុសម្នាក់ ។ បន្ទាប់មក មីង ដូរ នោះបានប្រាប់ថា គាត់បានស្គាល់លោក យាយយ៉ិន និង លោកតាទុយ ជាជីដូនជីតាខាងម្តាយរបស់ សុធា ដែរ ប៉ុន្តែគាត់មិនដឹងថាអ្នកទាំងពីររស់នៅទីណាឡើយ ។ សុធា មិនដឹងថា កងឈ្លបនិយាយអ្វីខ្លះជាមួយស្ត្រីនោះទេ តែកងឈ្លបបានប្រាប់ថា ស្ត្រីនេះស្គាល់លោកយាយលោកតារបស់ខ្លួន ដូច្នេះ សម្រេចឲ្យ សុធា រស់នៅជាមួយស្ត្រីនេះជាបណ្តោះអាសន្ន ដើម្បីរង់ចាំជួបគាត់ទាំងពីរនៅទីនេះ ។ ដោយសារមិនអាចប្រកែកបាន សុធា ចាំបាច់ត្រូវតែធ្វើតាមបញ្ជារបស់កងឈ្លប ។ ក្រោយមក និរសាររបស់សមមិត្ត ស៊ឹម ក៏លា សុធា ដើម្បីវិលត្រឡប់ទៅភូមិព្រៃស្នៀតវិញ ។

**ជីវិតក្មេងកំព្រា**

ជីវភាពរស់នៅរបស់ សុធា មិនសូវជាល្អទេ ពីព្រោះអ្នកមីង ដូរ មិនចង់ឲ្យ សុធា រស់នៅជាមួយ ។ ដោយសារមួយថ្ងៃហើយមួយថ្ងៃទៀត នៅតែមិនឃើញលោកតាលោកយាយ ឬបងប្អូនរបស់ សុធា ធ្វើដំណើរមកដល់ភូមិព្រែកក្រូចខាងលិច ដូច្នេះ សុធា ខិតខំធ្វើការងារគ្រប់បែបយ៉ាងជំនួសកូនប្រុសរបស់អ្នកមីង ដូរ ដែលមានអាយុច្រើនជាង សុធា ប្រហែលជា៣-៤ឆ្នាំ ទាំងកិច្ចការក្នុងផ្ទះនិងក្រៅផ្ទះ ដូចជារែកទឹកជាច្រើនអម្រែកដាក់ពាង ពុះឧស និងជួយធ្វើចម្ការជារៀងរាល់ថ្ងៃ ដើម្បីឲ្យអ្នកមីង ដូរ ចូលចិត្ត ។ លើសពីនេះទៅទៀត សូម្បីតែការងារស្រាលៗដូចជាដាំបាយ លាងចាន ក៏ សុធា ធ្វើដែរ ។ ប៉ុន្តែការហូបចុកវិញ សុធា មិនដែលហូបបានឆ្អែតម្តងណាទេ ។ ទោះបីជារស់នៅឆ្ងាយពីក្រុមគ្រួសារក៏ដោយ ក៏នៅក្នុងចិត្តរបស់ សុធា តែងតែគិតទៅដល់ជីដូននិងសម្តីម្តាយក្នុងពេលពួនក្នុងលេណដ្ឋានដើម្បីគេចពីគ្រាប់ផ្លោង ។ «គង់មានថ្ងៃស្អែកដែលបានស្រួល ហូបឆ្ងាញ់ ជួបសាច់ញាតិ» ។

រស់នៅបានមួយរយៈពេលខ្លី អ្នកមីង ដូរ ក៏បានមកប្រាប់ថា គាត់គ្មានបាយចិញ្ចឹមទៀតទេ ព្រោះគាត់ក្រដែរ ។ ដូច្នេះ សុធា

ត្រូវដើររើសឈ្នួលធ្វើចម្ការឲ្យអ្នកភូមិដើម្បីដូរយកបាយ ពេលខ្លះដើរបាញ់ចាបយកមកបរិភោគដែលធ្វើឲ្យអ្នកស្រុកលួចនិយាយតិះដៀលថាជាក្មេងចិត្តអាក្រក់ គ្មានមេត្តាសត្វ មិនចេះធ្វើបុណ្យទើបបុណ្យមិនជួយ នាំឲ្យកំព្រាព្រាត់ប្រាសគ្រួសារបែបនេះ ។ លើសពីនេះទៅទៀត មានពាក្យប្រមាថពីមនុស្សនៅក្នុងភូមិថាជាកូនអត់ម៉ែ កូនអនាថា ទៀតផង ។ ប៉ុន្តែក៏មានអ្នកភូមិខ្លះដែលធ្លាប់ស្គាល់ជីដូនជីតាខាងម្តាយរបស់ សុធា មានចិត្តអាណិតប្រណីឲ្យស្នាក់នៅក្នុងផ្ទះនិងឲ្យបាយហូប១-២ថ្ងៃដែរ ។ សុធា នៅចាំបានថា មានពេលខ្លះទៀត ពេលដែលមានអ្នកផ្សេងបានមកប្រាប់អ្នកដែលឲ្យបាយដល់ សុធា ថាជាក្មេងខ្វាត់ព្រាត់ គ្មានសាច់ញាតិមិនគួរណាឲ្យបាយហូបទេ ព្រោះដូចពាក្យចាស់ថាឈើកោងវល្លិព័ទ្ធមនុស្សខ្វាត់ព្រាត់កុំយកខ្លួនបៀត ។ ដោយសារតូចចិត្តនឹងពាក្យទាំងនោះ សុធា តែងតែទៅអង្គុយយំតែម្នាក់ឯងនៅក្នុងវត្តធម្មយុត្តិបុប្ផារាម ឬ លើកដៃបួងសួងនឹកគុណបុណ្យព្រះរតនត្រ័យសុំឲ្យបារមីព្រះអង្គជួយ ដែលវត្តនេះមានព្រះពុទ្ធរូបនៅសេសសល់ខ្លះពីរបបខ្មែរក្រហមដូចជា អង្គខ្លះដាច់ព្រះហស្តម្ខាង អង្គខ្លះទៀតខ្វាក់ព្រះនេត្រម្ខាង ឬក៏បាត់ព្រះកេស ដោយសារអង្គការបំផ្លាញនិងនៅតាមជញ្ជាំងនិងក្តារក្រាលនៃសាលាឆាន់ប្រឡាក់សុទ្ធតែឈាមជាមួយនឹងខោអាវខ្មៅមានស្នាមប្រឡាក់ឈាមដែរ ។ ពេលខ្លះ ពួអ្នកភូមិនិយាយថាជាកន្លែងដែលអង្គការយកប្រជាជនមកវាយធ្វើបាបនិងសម្លាប់នៅទីនេះ ។

មួយរយៈក្រោយមក សុធា ក៏បានចូលរៀននៅសាលាដូចជាក្មេងដទៃ ក្រោយពីប្រជាជនក្នុងភូមិនាំគ្នាបោសសម្អាតសាលាឆាន់ដើម្បីធ្វើជាបន្ទប់រៀន ។ ពេលនោះ ស្រាប់តែមានអ្នកគ្រូឈ្មោះ នាង អាយុប្រមាណ២៥ឆ្នាំ មានសន្តានចិត្តល្អបានប្រាប់ សុធា ថា សុធា ជាក្មេងធំហើយ និងមានអាយុសមល្មមដែលត្រូវចូលរៀនហើយ មិនគួរមិនទៅរៀននោះទេ ។ បន្ទាប់មកអ្នកគ្រូ នាង ក៏បានប្រាប់ទៀតថា គាត់នឹងនាំ សុធា ទៅចុះឈ្មោះចូលរៀននៅសាលា ហើយផ្តល់សម្លៀកបំពាក់សម្រាប់ទៅរៀនទៀត ។ នៅពេលនោះហើយដែល សុធា បានចូលរៀនជាមួយក្មេងដទៃនៅក្នុងភូមិ ។ ប៉ុន្តែ សុធា ក៏ត្រូវប្រឈមមុខនឹងការខ្វះលុយទិញសម្ភារៈសិក្សាមួយចំនួនដែរ ។ ដូច្នេះ ដើម្បីដូរយកបាយនិងបានទៅរៀនផង សុធា ត្រូវឆ្លៀតទៅជួយធ្វើការងារផ្ទះឲ្យអ្នកភូមិ ទោះជាការងារលំបាកក៏ សុធា មិនរួញរាដែរ ។ ការរស់នៅត្រូវចល័ត យប់ខ្លះសម្រាកនៅផ្ទះរបស់មីង ផូវ យប់ខ្លះទៀតនៅផ្ទះអ្នកភូមិផ្សេងទៀត ។

## ជួបលោកយាយយ៉ិន

ថ្ងៃមួយនាចុងឆ្នាំពេលដែលកំពុងសិក្សានៅក្នុងថ្នាក់ទី១ សុធា ស្រាប់តែបានជួបលោកយាយ យ៉ិន ដែលជាជីដូនខាងម្តាយ ដោយគាត់បានមកដល់ភូមិព្រែកក្របខាងលិចតែម្នាក់ឯងគត់ក្នុងសភាពជាមនុស្សមានជំងឺធ្ងន់ធ្ងរនិងគ្មានទ្រព្យសម្បត្តិជាប់នឹងខ្លួន ក្រៅពីបង្វេចខោអាវចាស់មួយកញ្ចប់ប៉ុណ្ណោះ ។ សុធា ត្រេកអរជាខ្លាំង ទោះជាបានជួបគាត់ក្នុងសភាពបែបនេះក៏ដោយ ព្រោះបានបែកគាត់អស់រយៈពេលច្រើនឆ្នាំមកហើយ ។ គាត់មានប្រសាសន៍ប្រាប់ទាំងទឹកភ្នែកថា គ្រួសារខាងម្តាយរបស់ សុធា ត្រូវបានខ្មែរក្រហមសម្លាប់អស់ហើយ គ្មាននរណាម្នាក់នៅរស់ទេ ក្រៅពីគាត់ម្នាក់ ។ ក្រោយពីឮសម្តីនេះ សុធា រន្ធត់ចិត្តជាខ្លាំង ព្រោះបានបាត់បង់មនុស្សជាទីពឹងអស់ ។

ការវិលត្រឡប់របស់លោកយាយយ៉ិន ក៏បានធ្វើឲ្យអ៊ំស្រីដែលរស់នៅលើដីរបស់គាត់និងអ្នកធ្វើចម្ការនៅលើដីមួយចំណែករបស់គាត់មានចិត្តអាណិតផ្តល់ជាជម្រកឲ្យគាត់សម្រាប់ស្នាក់នៅដែរ ។ ប៉ុន្តែ សុធា មិនបានមករស់នៅជាមួយជីដូន ព្រោះតែគិតថាមិនអាចបន្ថែមបន្ទុកដល់ម្ចាស់ផ្ទះម្នាក់ថែមទៀតទេ ដោយសុខចិត្តរស់ក្រោមការសុំជ្រកកោនរបៀបចល័តតាមតែក្តីមេត្តាពីអ្នកស្រុកអ្នកភូមិដូចពេលមុន ។ ប៉ុន្តែ សុធា នៅតែព្យាយាមទៅលេងលោកយាយ យ៉ិន តាមលទ្ធភាពដែលអាចធ្វើបាននៅរៀងរាល់ពេលទំនេរពីការរៀនសូត្រនិងជួយការងារអ្នកស្រុកក្នុងការយកបាយហូប ។ សុធា អាចរកប្រាក់បានដោយសារតែ សុធា ជាក្មេងដែលរៀនពូកែទទួលបានចំណាត់ថ្នាក់លេខមួយជារៀងរាល់ខែ ដូច្នេះ សុធា អាចជួយបង្រៀនកូនអ្នកភូមិប៉ុន្មាននាក់ទៀតដើម្បីយកលុយនិងជួយគិតលុយអ្នកភូមិនៅពេលលក់ដំណាំឲ្យទៅឈ្មួញ ព្រោះអ្នកភូមិខ្លះ មិនចេះបូកលេខ ។

ពេលចូលរៀននៅថ្នាក់ទី២ សុធា ត្រូវបានផ្លាស់មករៀននៅសាលាបឋមសិក្សាភូមិធំដែលឋិតនៅប្រហែលជា៩គីឡូម៉ែត្រ

ពីសាលារៀនចាស់ ។ ដោយសារតែហូបមិនឆ្អែតនិងត្រូវដើរឆ្ងាយទៅសាលារៀន សុធា តែងតែឆ្លៀតបេះផ្លែឈើដែលដុះនៅតាមផ្លូវយកមកហូបដើម្បីសម្រន់ការស្រេកឃ្លាន ជាពិសេសនៅក្នុងបរិវេណវត្តធម្មយុត្តិបុប្ផារាមដែលសម្បូរទៅដោយផ្លែឈើទំលុ ។

ភាពជាក្មេងកំព្រាមិនមានចំណីអាហារហូបឆ្អែត បណ្តាលឲ្យ សុធា ទៅជាក្មេងដែលស្គមស្គាំង រូបរាងតូចជាងសិស្សដទៃនៅក្នុងថ្នាក់រៀននិងត្រូវមិត្តភក្តិនិយាយដៀមដាមថាជាកូនអនាថាជាមនុស្សក្ររហាម មនុស្សធ្វើបុណ្យមិនល្អ ទើបត្រូវកំព្រា ដែលពេលខ្លះពាក្យទាំងនេះបានបន្តទៅជាជម្លោះទៀតផង ។ ប៉ុន្តែ សុធា ក៏ទទួលបានការស្រឡាញ់រាប់អានពីមិត្តភក្តិដែលខ្លួនធ្លាប់បង្រៀនដែរ ។

## ថ្ងៃចុងក្រោយរបស់លោកយាយយ៉ិន

នៅថ្ងៃមួយវេលាម៉ោងជាងដប់ព្រឹក ពេលដែល សុធា កំពុងតែស្ពាយកាតាបដើរចេញពីសាលា ស្រាប់តែសំឡេងបងស្រីម្នាក់ឈ្មោះ ឡៃ បានស្រែកហៅ សុធា ក្នុងសភាពភិតភ័យជាខ្លាំង ។ ពេលងាកទៅមើល គាត់ក៏បានស្ទុះមករកជាមួយទឹកមុខតក់ស្លុត ហើយនិយាយប្រាប់ថា លោកយាយ យ៉ិន បានស្លាប់ហើយ ។ ពេលឮដូច្នេះ សុធា ហាក់ដូចជាភាន់ភាំង ដោយនិយាយអ្វីមិនចេញ ថែមទាំងមិនដឹងថា បង ឡៃ បានដើរហួសទៅមុខបាត់ ។ បន្តិចក្រោយមក សុធា ក៏ប្រញាប់ប្រញាល់រត់យ៉ាងលឿនដើម្បីមកមើលយាយ យ៉ិន ។ មកដល់ផ្ទះ សុធា ឃើញទ្វារចំហនិងមិនមានមនុស្សសូម្បីម្នាក់ រួចក៏ស្ទុះចូលទៅក្នុងផ្ទះសំដៅទៅរកកន្លែងដែលជីដូនសម្រាន្ត ។ សុធា មានការតក់ស្លុតជាខ្លាំងពេលបានឃើញលោកយាយ យ៉ិន សម្រាន្តនៅលើគ្រែឫស្សីមានស្រមោចរោមភ្នែកនិងមុខរបស់គាត់ពាសពេញ ។ ទឹកភ្នែក សុធា ស្រក់មកដោយមិនដឹងខ្លួន រួចយកដៃទាំងពីរស្រវាឱបសាកសពគាត់ ។

បន្ទាប់មក អ្នកភូមិបាននាំគ្នាមកចូលរួមរំលែកទុក្ខ តែគ្មានពិធីបុណ្យទានអ្វីទាំងអស់ ព្រោះ សុធា មិនមានប្រាក់សម្រាប់ធ្វើបុណ្យជូនគាត់ ដោយមនុស្សក្នុងភូមិខ្លះមានសន្តានចិត្តល្អ បានផ្តល់ក្រណាត់សដល់ សុធា ដើម្បីឲ្យបានស្លៀកពាក់កាន់ទុក្ខជូនលោកយាយ យ៉ិន ។ បន្ទាប់ពីរុំសាកសពរួច សុធា ក៏ដើរខាងមុខសែងសាកសពរួមជាមួយមនុស្សប៉ុន្មាននាក់ទៀតទៅកាន់ព្រៃខាងក្រោយផ្ទះ ។

## កិត្តិយសក្មេងកំព្រា

ប្រហែលជាខែមករា ឬខែកុម្ភៈ ឆ្នាំ១៩៨០ ពិធីដ៏ធំមួយបានប្រារព្ធឡើងនៅក្នុងសាលាបឋមសិក្សាភូមិធំ ។ ពេលនោះឪពុកម្តាយនិងអាណាព្យាបាលរបស់សិស្សានុសិស្សរាប់រយនាក់មានសម្លៀកបំពាក់យ៉ាងស្អាតអង្គុយផ្ទាល់ដីនៅក្រោមម្លប់ស្វាយធំមួយខាងមុខវេទិកា ព្រមទាំងមានភ្ញៀវកិត្តិយសដែលមានបណ្តាស័ក្តិដូចជា មន្ត្រីដែលមកពីសាលាស្រុក ក្រសួងអប់រំសាលាសង្កាត់ក្នុងស្រុក និងជនបរទេសមួយចំនួនដែលមកពីអង្គការអ៊ុយនីសេហ្វជាគណៈអធិបតីក្នុងកម្មវិធីនេះ ។ ចំណែកនៅចំហៀងម្ខាងទៀតលើស្មៅក្រោមម្លប់ដើមស្វាយមានសុទ្ធតែសិស្សានុសិស្សអង្គុយផ្ទាល់ដីត្រៀបត្រាក្នុងឯកសណ្ឋានសិស្ស ។ បន្ទាប់មក សំឡេងអ្នកចាត់តាំងកម្មវិធីលាន់រំពងតាមឧគ្ឃោសនសព្ទប្រកាសហៅឈ្មោះ សុធា ដែលទទួលបានចំណាត់ថ្នាក់លេខមួយប្រចាំសាលាក្នុងចំណោមសិស្សជាង៣០០នាក់ឡើងសម្តែងមតិចាប់អារម្មណ៍តំណាងឲ្យសិស្សពូកែប្រចាំសាលារៀន ។ សុធា ឈានជើងទាំងញ័រជាមួយនឹងក្តីរំភើបដើរទៅកាន់ទីកន្លែងដែលមានមីក្រូ ។ ភ្លាមនោះ ស្នូរទះដៃកងរំពងនិងភ្នែកមនុស្សរាប់រយគូក្រឡេកមើល សុធា ពោរពេញដោយការកោតសសើរជាមួយនឹងជំនួយឧបត្ថម្ភពីពីអង្គការអ៊ុយនីសេហ្វដូចជា សៀវភៅ ប៊ិច ខ្មៅដៃកាតាប និងម្សៅទឹកដោះគោ ។

សុធា ក៏នៅចាំបានថា ពេលនោះ សុធា ស្ថិតនៅក្នុងក្រុមកុមារឈានមុខដែលជាក្រុមកុមារមានគោលជំហរល្អនិងជាក្មេងល្អលើបីចំណុចធំៗ ៖ កូនល្អ សិស្សល្អ និងមិត្តល្អ ដែលថ្ងៃអនាគតអាចក្លាយជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិ ។ ក្រៅពីរៀនសូត្រនៅក្នុងថ្នាក់ ក្រុមកុមារឈានមុខមានតួនាទីបន្ថែមដូចជាហាត់ដើរឲ្យត្រូវចង្វាក់ភ្លេង លេងភ្លេង ច្រៀងចម្រៀងកុមារឈានមុខដែលជាបទបណ្តុះចិត្តឲ្យក្មេងមានឆន្ទៈស្រឡាញ់មាតុភូមិហ៊ានធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីផលប្រយោជន៍ប្រទេសជាតិរៀនតែងកំណាព្យ ធ្វើពលកម្មជួយសង្គម ដោយដាំដើមឈើ

បោសសម្អាតភូមិ ដែលនាំឲ្យប្រជាជនឲ្យស្គាល់ពីសុខភាព និង អនាម័យ ។ លើសពីនេះ សុធា តម្រូវឲ្យវាយស្គរធំមួយដើរដឹកនាំ ក្រុមកុមារឈានមុខទាំងឡាយឲ្យត្រូវតាមចង្វាក់ភ្លេងនៅរៀងរាល់ ពេលចូលរួមក្នុងពិធីបុណ្យជាតិធំៗ ។ ដោយសារ សុធា ជាសិស្ស គំរូ សុធា តែងតែដាក់ពិន័យចំពោះក្មេងណាដែលហាត់មិនបានល្អ ដែលពេលខ្លះធ្វើឲ្យក្មេងដទៃច្រណែនគ្រប់គ្នា ។

**អាយុមិនអស់**

ប្អូនប្រាំឆ្នាំកន្លងមកហើយ ដែល សុធា ត្រូវរស់នៅក្នុងភាព ជាក្មេងអនាថា ជ្រកកោនក្នុងដំបូលផ្ទះមនុស្សចិត្តបុណ្យបីបួននាក់ និងការប្រើងប្រែងធ្វើការងារសព្វបែបយ៉ាង ។ ស្រាប់តែថ្ងៃមួយ វេលាដែល សុធា កំពុងតែកាប់ដីដើម្បីជួយដាំត្រសក់នៅចម្ការ របស់អ្នកភូមិម្នាក់ឈ្មោះ បងសុក ក៏មានក្មេងម្នាក់បានមកប្រាប់ ថាលោកយាយ ហេង បានមករក ។ សុធា សប្បាយចិត្តជាខ្លាំង រួចក៏រត់ទៅរកលោកយាយ ហេង ទាំងសោមនស្សរីករាយ ។ គ្រាន់តែបានជួបមុខចៅសម្លាញ់ភ្លាម លោកយាយ ហេង ស្រវា ឱបចៅកម្សត់ទាំងទឹកភ្នែកនិងអាណិតចៅដែលរស់នៅតែលតោល ពឹងផ្អែកលើអ្នកស្រុកតាមតែគេមេត្តា ។

បន្ទាប់មក លោកយាយ ហេង បាននិយាយរឿងរ៉ាវដែល កងទ័ពវៀតណាមបានមករំដោះប្រទេសកម្ពុជានៅខែមករា ដែល កាលណោះគាត់បានមករកបងប្អូននិងកូនៗរបស់គាត់ដល់ស្រុក ចម្ការលើ ។ ប៉ុន្តែ អ្នកស្គាល់គ្នាប្រាប់គាត់ថា បងប្អូនរបស់គាត់ត្រូវ អង្គការយកទៅរៀនសូត្រ ហើយខ្លះទៀតត្រូវអង្គការផ្លាស់ទី លំនៅដោយគ្មានដំណឹងថាទៅទីណាឲ្យប្រាកដ ។ ចំណែកកូនរបស់ គាត់ត្រូវអង្គការចាប់យកទៅដាក់នៅក្នុងមន្ទីរឃុំឃាំង ចុងក្រោយ អង្គការយកទៅសម្លាប់ចោល និង រដ្ឋា ជាកូនទីប្រាំវិញត្រូវកងទ័ព ខ្មែរក្រហមចាប់រំលោភ ដោយសម្រាតសម្លៀកបំពាក់ និងវាយ ធ្វើបាបយ៉ាងអនុស្សធម៌ ។ លោកយាយបន្តទៀតថា សាច់ញាតិ របស់គាត់ទាំងអស់គ្មាននរណាមានជីវិតនៅរស់ក្រោយពីរបប កម្ពុជាប្រជាធិបតេយ្យឡើយ ។ ទោះជារឿងនេះធ្វើឲ្យលោក យាយ ហេង រន្ធត់ចិត្តក៏ដោយ ក៏គាត់នៅតែខំប្រឹងរស់និងព្យាយាម ធ្វើដំណើរមករក សុធា នៅភូមិព្រៃស្មៀតដែរ ។

ចំពោះព័ត៌មានឪពុករបស់ សុធា វិញ លោកយាយបាន ប្រាប់ថា មានអ្នកភូមិម្នាក់ឈ្មោះ យ៉ាន បានមកប្រាប់គាត់អំពី ដំណឹងរបស់លោកស័ក្តិបី កែវ ហៀង ថា នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ជាទិវាជ័យជម្នះរបស់កងទ័ពខ្មែរក្រហម ឪពុករបស់ សុធា បានទម្លាក់អាវុធនិងដោះឯកសណ្ឋានជាទាហានចោល ដើម្បី រត់មកភូមិព្រៃកតាសរតាមការណាត់គ្នារវាងគាត់និងអ្នកគ្រូ សាម៉េត ។ ប៉ុន្តែ ពេលមកដល់ភូមិព្រៃកតាសរ គាត់បែរជាត្រូវ គណៈកងក្នុងភូមិព្រៃកតាសរបង្ខំឲ្យឡើងរទេះគោជាមួយប្រជាជន ថ្មីជាច្រើននាក់ទៀត ដើម្បីផ្លាស់ទីលំនៅទៅស្រុកពារាំង ខេត្ត ព្រៃវែង ។ ដោយសារលោក កែវ ហៀង គិតជានិច្ចថា ខ្មែរមិន សម្លាប់ខ្មែរទេ ហើយសង្គ្រាមក៏បានចប់ទៅហើយដែរ ដូច្នេះគាត់ មិនចាំបាច់រត់គេចទេ ព្រោះគាត់មិនអាចជាអ្នកដែលប្រឆាំងនឹង បដិវត្តន៍ខ្មែរក្រហមបានទេ ។ ប៉ុន្តែ គំនិតស្មោះត្រង់និងការ ស្រឡាញ់ជាតិមាតុភូមិទើបធ្វើឲ្យជីវិតរបស់គាត់ត្រូវលាចាក លោកទៅវិញ ។ ក្រោយពីស្ដាប់ការរៀបរាប់រួច សុធា ឈឺចាប់ ជាខ្លាំង ព្រោះក្រុមគ្រួសារដែលមានមនុស្សជាង៣០នាក់បាន បាត់បង់ជីវិតនិងបាត់ខ្លួនអស់គ្មានសល់ ។

បន្ទាប់មក លោកយាយ ហេង ក៏បានប្រាប់ថា គាត់នឹងនាំ សុធា ទៅរស់នៅជាមួយគាត់នៅភូមិព្រៃកតាសរ ។ ដោយសារ ទម្លាប់ក្នុងការរស់នៅជាមួយនឹងការប្រឹងប្រែងដោយខ្លួនឯង និង មិនចង់ដាក់បន្ទុកដល់ជីដូនដែលកាន់តែចាស់ជរាទៅ សុធា ក៏បាន បដិសេធមិនព្រមទៅរស់នៅជាមួយ ។ ប៉ុន្តែ ពេលដែលទំនេរពីការ សិក្សា សុធា តែងតែទៅសួរសុខទុក្ខគាត់ដែរ ។

**ប៉ាល់ ខណ្ឌារក្ស**







ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 113, May 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.